**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៧៥ សហវ.ប្រក.អគពដ

# ប្រកាស
# ស្តីពី
# ពន្ធលើប្រាក់ចំណូល

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីកម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._** គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រាក់ចំណូល ដែលត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស វៀរលែងតែអ្នកជាប់ពន្ធតូច។

**ប្រការ២ ._** វិសាលភាព

ពន្ធលើប្រាក់ចំណូលអនុវត្តលើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស និងអ្នកជាប់ពន្ធអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

**ប្រការ៣ ._** និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- អ្នកជាប់ពន្ធ សំដៅដល់ បុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធដែលក្នុងនោះរួមមាន រូបវន្តបុគ្គល និងនីតិបុគ្គល។

២- អ្នកជាប់ពន្ធនិវាសនជន ពេលណាប្រើជាមួយរូបវន្តបុគ្គល សំដៅដល់ រូបវន្តបុគ្គលណាម្នាក់ដែលមានលក្ខណវិនិច្ឆ័យចាប់ពីមួយឡើងទៅក្នុងចំណោមលក្ខណវិនិច្ឆ័យទាំងបីដូចខាងក្រោម៖

- ក- មាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិឬជួល ឬភតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន... ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅឬកាន់កាប់។
- ខ- មានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា  តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅដោយផ្អែកទៅលើកត្តានានា ដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់។
- គ- មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជា ១ថ្ងៃពេញ។

ក្នុងករណីដែលមានភាពមិនច្បាស់លាស់ក្នុងការវិនិច្ឆ័យតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌ ក និង វាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ វត្តមានរបស់រូបវន្តបុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ គ នៃកថាខណ្ឌនេះ គឺជាលក្ខខណ្ឌចុងក្រោយសម្រាប់កំណត់ភាពជានិវាសនជនរបស់រូបវន្តបុគ្គល។

៣- អ្នកជាប់ពន្ធនិវាសនជន ពេលណាប្រើជាមួយនីតិបុគ្គល សំដៅដល់ អង្គភាពដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រង ឬដែលមានទីកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤- នីតិបុគ្គល សំដៅដល់ សហគ្រាស ឬអង្គភាពនានា ដែលប្រកបអាជីវកម្មទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ នីតិបុគ្គល រួមបញ្ចូលផងដែរនូវស្ថាប័នរាជរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ អង្គការមិនស្វែងរកចំណេញ សមាគម គណបក្សនយោបាយ និងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជនដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ នីតិបុគ្គល ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនសហកម្មសិទ្ធិ ឬសហគ្រាសឯកបុគ្គល។

៥-គ្រឹះស្ថានអចិន្ត្រៃយ៍ សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ គ្រឹះស្ថានអចិន្ត្រៃយ៍ រួមបញ្ចូលផងដែរនូវបណ្តាញឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ គ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវបានចាត់ទុកថាជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ គ្រឹះស្ថានអចិន្ត្រៃយ៍ មានជាអាទិ៍៖

ក- ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង។

ខ- សាខារបស់សហគ្រាសបរទេស ឬភ្នាក់ងារ។

គ- ការិយាល័យរបស់សហគ្រាសបរទេស។

ឃ-ឃ្លាំង រោងចក្រ រោងជាង កសិដ្ឋាន ឬកន្លែងដាំដុះ។

ង- កន្លែងយករ៉ែ អណ្តូងប្រេងកាតឬឧស្ម័នធម្មជាតិ កន្លែងយកថ្មឬធនធានធម្មជាតិផ្សេងទៀត។

ច- ការដ្ឋាន កន្លែងសាងសង់ គម្រោងការសាងសង់ឬគម្រោងការផ្គុំដំឡើង និងសកម្មភាពតាមដានពិនិត្យដែលជាប់ទាក់ទិននឹងទីកន្លែងឬគម្រោងការទាំងនោះ ក្នុងករណីដែលទីកន្លែងសាងសង់ឬគម្រោងការឬសកម្មភាពទាំងនោះមានរយៈពេលលើសពី ១៨២ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ខែណាមួយ។

ឆ- ការផ្តល់សេវាដែលក្នុងនោះមានទាំងសេវាទីប្រឹក្សាផង ធ្វើឡើងដោយនិយោជិត ឬបុគ្គលិកផ្សេងទៀតរបស់សហគ្រាសបរទេស ក្នុងករណីដែលសកម្មភាពទាំងនោះបានប្រព្រឹត្តទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលសរុបលើសពី ១៨២ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ខែណាមួយ។

ជ- សកម្មភាពអាជីវកម្ម (រួមបញ្ចូលទាំងប្រតិបត្តិការឧបករណ៍ធុនធ្ងន់) សម្រាប់ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានធម្មជាតិ សម្រាប់មួយលើកឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ៩០ថ្ងៃក្នុងអំឡុងពេល ១២ខែណាមួយ។

ឈ-បន្ថែមលើសេចក្តីដូចមានចែងក្នុងវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ជ នៃកថាខណ្ឌនេះ បុគ្គលណាមួយត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលបុគ្គលនោះបំពេញលក្ខខណ្ឌចាប់ពីមួយឡើងទៅក្នុងចំណោមលក្ខខណ្ឌទាំងបីដូចខាងក្រោម៖

- មាននិងប្រើជាប្រចាំនូវសិទ្ធិអំណាចក្នុងការចុះកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមសហគ្រាសបរទេសណាមួយ ឬបំពេញតួនាទីចម្បងក្នុងការសម្របសម្រួល ដើម្បីឈានដល់ការចុះកិច្ចសន្យា
- កាន់កាប់ជាប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជានូវស្តុកទំនិញ ហើយបុគ្គលនោះតែងធ្វើការបញ្ជូន ឬផ្គត់ផ្គង់ទំនិញចេញពីស្តុកនោះ ក្នុងនាមសហគ្រាសបរទេសណាមួយ
- ធ្វើការប្រមូលបុព្វលាភឬធ្វើការធានារ៉ាប់រង លើកលែងតែការធានារ៉ាប់រងបន្តនូវហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមសហគ្រាសបរទេសណាមួយ។

ញ-ក្នុងការអនុវត្ត រដ្ឋបាលសារពើពន្ធត្រូវវិនិច្ឆ័យទៅតាមករណីដោយឡែកនីមួយៗទៅតាមព្រឹត្តិការណ៍ជាក់ស្តែងនៃករណីនីមួយៗថាតើមាន ឬគ្មានគ្រឹះស្ថានអចិន្ត្រៃយ៍ លើកលែងតែការអនុវត្តនូវប្រការទាំងឡាយនៃកិច្ចព្រមព្រៀងអន្តរជាតិ។

៦-ក្រុមហ៊ុនមូលធន សំដៅដល់ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

៧-សហគ្រាស សំដៅដល់ គ្រឹះស្ថាន ឬអង្គភាពដែលរូបវន្តបុគ្គលឬនីតិបុគ្គលប្រកបអាជីវកម្ម។

៨-អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់ បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងទទួលបាននូវប្រាក់ចំណូលប្រភពកម្ពុជា។

៩-ភាគលាភ សំដៅដល់ ចំណែកជាសាច់ប្រាក់ឬជាទ្រព្យដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែការបែងចែកមូលធននានាក្នុងពេលជម្រះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភឬមិនមែនជាភាគលាភ ត្រូវផ្អែកតាមលក្ខខណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមានឬគ្មានប្រាក់ចំណូលសុទ្ធក្នុងឆ្នាំចរន្តឬពីឆ្នាំមុនៗឡើយ។

១០-ធនាគារ សំដៅដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអង្គភាពណាមួយដែលធ្វើប្រតិបត្តិការក្រោមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការដូចខាងក្រោម៖

ក- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជនដោយមានកម្រៃ រាប់បញ្ចូលទាំងឥណទានកតិសន្យាហិរញ្ញវត្ថុ។

ខ- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន។

គ- ប្រព្រឹត្តិកម្ម និងការដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុឬជារូបិយបណ្ណ។

១១-ប្រាក់ចំណូលដុល សំដៅដល់ ប្រាក់ចំណូលដែលបានមកពីប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមទាំងចំណូលបន្ទាប់បន្សំ និងចំណូលផ្សេងៗដែលមិនទាន់កាត់កងចំណាយ។

១២-ប្រាក់ចំណូលសុទ្ធ សំដៅដល់ លទ្ធផលបានមកពីការយកប្រាក់ចំណូលដុលកាត់កងនូវចំណាយនានាដែលអនុញ្ញាតដោយបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

១៣-ប្រាក់ចំណូលជាប់ពន្ធ សំដៅដល់ ប្រាក់ចំណូលសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលប្រកបអាជីវកម្មឬនៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល សួយសារ និងសំណងផ្សេងៗ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុឬទ្រព្យសកម្មវិនិយោគរាប់ទាំងអចលនទ្រព្យ។

## ជំពូកទី២
## របបកំណត់ពន្ធ និងវិធានគណនេយ្យ

**ប្រការ៤ .-** របបកំណត់ពន្ធ

របបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជាជារបបស្វ័យប្រកាសដែលតម្រូវឱ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធដោយខ្លួនឯង។

**ប្រការ៥ .-** វិធានគណនេយ្យ

១-អនុលោមតាមវិធានគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះត្រូវបានទូទាត់ ឬមិនទាន់ទូទាត់ក្តី។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវចំណាយរបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិនដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

២-ចំពោះប្រតិបត្តិការដែលគិតតម្លៃជារូបិយបណ្ណបរទេស ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

ក- ត្រូវកត់ត្រាចូលក្នុងបញ្ជីគណនេយ្យជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជានាថ្ងៃធ្វើប្រតិបត្តិការ។

ខ- ក្នុងករណីមានប្រព័ន្ធធានាការប្តូរប្រាក់ ឥណទេយ្យឬបំណុលត្រូវប្តូរជាប្រាក់រៀលលើមូលដ្ឋាននៃអត្រាប្តូរប្រាក់នាពេលកំណត់ដែលបានចែងក្នុងកិច្ចសន្យា។

គ- ប្រសិនបើឥណទេយ្យឬបំណុលបានកើតឡើង និងត្រូវបានទូទាត់នៅក្នុងការិយបរិច្ឆេទតែមួយនោះ ចំនួនលម្អៀងដែលបានពិនិត្យឃើញរវាងតម្លៃនាពេលកើតឡើងនិងកត់ចូលបញ្ជី និងតម្លៃនាពេលទូទាត់សង គឺជាការខាតឬចំណេញពីការប្តូរប្រាក់ ដែលត្រូវកត់ត្រាជាចំណាយហិរញ្ញវត្ថុឬចំណូលហិរញ្ញវត្ថុនៃការិយបរិច្ឆេទ។

ឃ-នាពេលបញ្ចប់ការិយបរិច្ឆេទ ឥណទេយ្យឬបំណុលជារូបិយបណ្ណបរទេស ត្រូវវាយតម្លៃតាមអត្រាប្តូរប្រាក់នាថ្ងៃបិទការិយបរិច្ឆេទ។ លម្អៀងដែលកើតចេញមកពីការវាយតម្លៃនេះត្រូវកត់ត្រាជាការខាតឬចំណេញពីការប្តូរប្រាក់។



ឋ

ង- នៅក្នុងការិយបរិច្ឆេទបន្ទាប់ នៅពេលទូទាត់ឥណទេយ្យ ឬបំណុលពាក់ព័ន្ធនឹងការខាតឬចំណេញពីការប្តូរប្រាក់ ត្រូវកត់ត្រាតាមប្រាក់លម្អៀងរវាងតម្លៃរបស់វានៅពេលទូទាត់ និងតម្លៃរបស់វានាពេលបិទនៃការិយបរិច្ឆេទមុន។

ច- ចំពោះសាច់ប្រាក់ជារូបិយបណ្ណបរទេសដែលសហគ្រាសមាននៅចុងការិយបរិច្ឆេទ សហគ្រាសត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធានដែលបានចែងសម្រាប់ឥណទេយ្យឬបំណុលដូចមានចែងក្នុងវាក្យខណ្ឌ ឃ នៃកថាខណ្ឌនេះ។

**ប្រការ៦ ._** ការកែតម្រូវក្រៅគណនេយ្យ

តាមវិធានគណនេយ្យ ប្រាក់ចំណូលសុទ្ធឬខាត គឺជាសមតុល្យនៃគណនីលទ្ធផលនៃការិយបរិច្ឆេទ ប៉ុន្តែដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារបានកំណត់ផ្សេង ដូចនេះការកែតម្រូវក្រៅគណនេយ្យត្រូវបានធ្វើឡើងតាមការបញ្ចូលមកវិញឬកាត់ចេញនូវចំណូលនិងចំណាយ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ៥៤ នៃប្រកាសនេះ។

## ជំពូកទី៣
## វិធានទូទៅស្តីពីប្រាក់ចំណូលជាប់ពន្ធ

### ផ្នែកទី១
### ឆ្នាំជាប់ពន្ធ និងប្រាក់ចំណូលជាប់ពន្ធ

**ប្រការ៧ ._** ឆ្នាំជាប់ពន្ធ

អនុលោមតាមមាត្រា៨ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះនីតិបុគ្គល៖

ក- ពន្ធលើប្រាក់ចំណូល ត្រូវបានគណនាចេញពីលទ្ធផលគណនេយ្យដែលសម្រេចបានក្នុងឆ្នាំប្រតិទិននីមួយៗ (ថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ)។ សហគ្រាសដែលអនុវត្តឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់។

ខ- សហគ្រាសដែលត្រូវបានគ្រប់គ្រងដោយនីតិបុគ្គលអនិវាសនជនអាចស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន។ សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មី ត្រូវអនុវត្តដូចខាងក្រោម៖

- ការិយបរិច្ឆេទអន្តរកាល៖
  - ចំពោះសហគ្រាសចាស់ គឺបន្តអនុវត្តចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំជាប់ពន្ធដែលការស្នើសុំបានធ្វើឡើងរហូតដល់ថ្ងៃមុនថ្ងៃចាប់ផ្តើមនៃឆ្នាំជាប់ពន្ធថ្មី

    **ឧទាហរណ៍ទី១៖**

    នៅក្នុងឆ្នាំ២០២៤ សហគ្រាសបានស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដែលចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។ ដូចនេះ ការិយបរិច្ឆេទអន្តរកាល ត្រូវចាប់ផ្តើមពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។ ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតសម្រាប់សហគ្រាសនេះ គឺចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា។
  - ចំពោះសហគ្រាសបង្កើតថ្មី គឺគិតពីថ្ងៃចាប់ផ្តើមធ្វើអាជីវកម្ម រហូតដល់ថ្ងៃមុនថ្ងៃចាប់ផ្តើមនៃឆ្នាំជាប់ពន្ធថ្មីដែលបានស្នើសុំ

    **ឧទាហរណ៍ទី២៖**

    សហគ្រាសត្រូវបានបង្កើតថ្មីនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។ សហគ្រាសថ្មីនេះស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដែលចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។ ដូចនេះការិយបរិច្ឆេទអន្តរកាល ត្រូវចាប់ផ្តើមពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។ ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតសម្រាប់សហគ្រាសនេះ គឺចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា។

**ឧទាហរណ៍ទី៣៖**

ក្នុងករណីសហគ្រាសត្រូវបានបង្កើតថ្មីនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤។ សហគ្រាសថ្មីនេះ ស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដែលចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។ ដូចនេះ ការិយបរិច្ឆេទអន្តរកាល ត្រូវចាប់ផ្តើមពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។ ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតសម្រាប់សហគ្រាសនេះ គឺចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា។

- ការិយបរិច្ឆេទបន្ត៖ ឆ្នាំជាប់ពន្ធថ្មី គឺជារយៈពេល ១២ខែ បន្ទាប់ពីដំណាច់ការិយបរិច្ឆេទអន្តរកាល

**ឧទាហរណ៍ទី៤៖**

បន្តពីឧទាហរណ៍ទី១ ឧទាហរណ៍ទី២ និងឧទាហរណ៍ទី៣ ខាងលើ ការិយបរិច្ឆេទបន្ត (ឆ្នាំជាប់ពន្ធថ្មី) ត្រូវចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦។

- ទាយជ្ជទានឱ្យដល់វិលស់សម្រាប់ការិយបរិច្ឆេទអន្តរកាល ត្រូវបានគណនាតាមសមាមាត្រនៃចំនួនថ្ងៃនៃការិយបរិច្ឆេទអន្តរកាល ធៀបទៅនឹងចំនួន ៣៦៥ថ្ងៃ នៃឆ្នាំ

**ឧទាហរណ៍ទី៥៖**

សហគ្រាសមានការិយបរិច្ឆេទអន្តរកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។ ក្នុងករណីនេះចំនួនថ្ងៃគិតរំលស់មាន ១៨២ថ្ងៃ។ ទាយជ្ជទានឱ្យដល់វិលស់ក្នុងមួយឆ្នាំពេញស្មើនឹង ៤២ ០០០ ០០០ រៀល។ ដូច្នេះ ទាយជ្ជទានឱ្យដល់វិលស់សម្រាប់ការិយបរិច្ឆេទអន្តរកាល៖

$$= \frac{៤២\ ០០០\ ០០០ \times ១៨២}{៣៦៥} = ២០\ ៩៤២\ ៤៦៦ \text{ រៀល។}$$

- ការយោងការខាតបង់សម្រាប់ការិយបរិច្ឆេទអន្តរកាល ត្រូវគិតស្មើមួយឆ្នាំ
- សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដូចមានចែងក្នុងវាក្យខណ្ឌនេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖
  - លិខិតបញ្ជាក់ពីក្រុមហ៊ុនដើមដែលនៅបរទេសអំពីការប្រើប្រាស់ឆ្នាំជាប់ពន្ធថ្មីខុសពីឆ្នាំប្រតិទិន
  - លិខិតបញ្ជាក់ពីសវនករឯករាជ្យរបស់ក្រុមហ៊ុនដើមដែលនៅបរទេស អំពីការប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន
  - ច្បាប់ចម្លងនៃលក្ខន្តិកៈក្រុមហ៊ុនរបស់សហគ្រាស ដែលអាចបញ្ជាក់បាននូវអត្តសញ្ញាណរបស់ក្រុមហ៊ុនដើមនៅបរទេស។
- សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មី ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចខាងក្រោម៖
  - ក្នុងរយៈពេល ៣ខែ បន្ទាប់ពីដំណាច់ការិយបរិច្ឆេទអន្តរកាល
  - ក្នុងរយៈពេល ៣ខែ ក្រោយដំណាច់ឆ្នាំជាប់ពន្ធថ្មី។

គ- ប្រសិនបើមានលទ្ធផលគណនេយ្យច្រើនតៗគ្នាក្នុងឆ្នាំប្រតិទិនណាមួយ លទ្ធផលគណនេយ្យទាំងឡាយត្រូវបូកបញ្ចូលគ្នាធ្វើជាមូលដ្ឋានគិតពន្ធលើប្រាក់ចំណូល។

ឃ-ចំពោះសហគ្រាសថ្មីដែលចាប់ផ្តើមប្រកបអាជីវកម្ម លទ្ធផលគណនេយ្យត្រូវគិតចាប់តាំងពីថ្ងៃដែលចាប់ផ្តើមប្រកបអាជីវកម្មមកទល់នឹង៖

- ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំប្រតិទិនសម្រាប់សហគ្រាសដែលប្រើឆ្នាំប្រតិទិនជាឆ្នាំជាប់ពន្ធ
- ថ្ងៃដំណាច់ឆ្នាំជាប់ពន្ធសម្រាប់សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន។

ង- ចំពោះសហគ្រាសដែលផ្អាកឬបញ្ឈប់សកម្មភាពអាជីវកម្ម លទ្ធផលគណនេយ្យចុងក្រោយត្រូវគិត៖

- ចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃផ្អាកឬបញ្ឈប់សកម្មភាពជាស្ថាពរសម្រាប់សហគ្រាសដែលប្រើប្រាស់ឆ្នាំប្រតិទិនជាឆ្នាំជាប់ពន្ធ
- ចាប់ពីដើមឆ្នាំជាប់ពន្ធចរន្តរហូតដល់ថ្ងៃផ្អាក ឬបញ្ឈប់សកម្មភាពជាស្ថាពរសម្រាប់សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន។

២-ចំពោះរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនសហកម្មសិទ្ធិ ពន្ធលើប្រាក់ចំណូលត្រូវបានគណនាចេញពីប្រាក់ចំណូលសរុបដែលសម្រេចបានក្នុងឆ្នាំប្រតិទិននីមួយៗ។

**ប្រការ៨ ._** ប្រភពចំណូល

១-អនុលោមតាមមាត្រា៣៣ នៃច្បាប់ស្តីពីសារពើពន្ធ ដោយមិនមានការកម្រិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជា រួមមាន៖

ក- ការប្រាក់ដែលបង់ដោយអ្នកជាប់ពន្ធនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ខ- ភាគលាភដែលបានបែងចែកដោយអ្នកជាប់ពន្ធនិវាសនជន។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ៖

- ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃប្រាក់ចំណូលរក្សាទុកទៅក្នុងដើមទុនរបស់សហគ្រាស ដោយមានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់សហគ្រាស និងភស្តុតាងច្បាស់លាស់អំពីការកែប្រែមូលធនដោយមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច មិនត្រូវបានចាត់ទុកថាជាបែងចែកភាគលាភទេ។ ប្រសិនបើពេលណាមួយសហគ្រាសដកដើមទុនបែងចែកឱ្យភាគហ៊ុនិក ការដកដើមទុននោះត្រូវបានចាត់ទុក ជាការបែងចែកភាគលាភចំពោះចំណែកដើមទុនដែលបានមកពីប្រាក់ចំណូលរក្សាទុក។ ប្រាក់ចំណូលរក្សាទុកត្រូវបានចាត់ទុកថាបែងចែកភាគលាភឱ្យទៅអ្នកចូលហ៊ុនទាំងស្រុងផងដែរ នៅពេលដែលសហគ្រាសបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ
- ក្នុងករណីមានការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនក្នុងដើមទុន ឬមូលធនរបស់សហគ្រាសដែលមានប្រាក់ចំណូលរក្សាទុក ប្រាក់ចំណូលរក្សាទុកដែលជាប់ទាក់ទិននឹងភាគហ៊ុនដែលបានផ្ទេរ ទោះបីបានបង្វែរឬមិនបានបង្វែរចូលក្នុងដើមទុនឬមូលធនក៏ដោយ ត្រូវចាត់ទុកថាបានបែងចែកជាភាគលាភ។

គ- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ឃ-ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេស ដែលបានទូទាត់ដោយអ្នកជាប់ពន្ធនិវាសនជន។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ៖

- សេវាគ្រប់គ្រង សំដៅដល់ សេវាដែលមានចរិតគ្រប់គ្រងទាំងឡាយដែលបានធ្វើឡើងដើម្បីបំពេញមុខងារគ្រប់គ្រងក្នុងការប្រកបអាជីវកម្ម មានជាអាទិ៍ ការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល ការគ្រប់គ្រងភ្នាក់ងារលក់
- សេវាបច្ចេកទេស សំដៅដល់ សេវាទាំងឡាយដែលមានចរិតជាបច្ចេកទេសដែលតម្រូវឱ្យមានជំនាញឬចំណេះដឹងបច្ចេកទេសក្នុងការអភិវឌ្ឍឬបង្កើតធាតុចូលនានានៅក្នុងអាជីវកម្ម មានជាអាទិ៍ សេវាវិទ្យាសាស្ត្រ រូបសាស្ត្រ គីមីសាស្ត្រ វេជ្ជសាស្ត្រ ទន្តសាស្ត្រ ឱសថសាស្ត្រ នីតិសាស្ត្រ ជាពសាស្ត្រ បសុសាស្ត្រ សិល្បៈ អប់រំសិក្សាធិការ វិស្វកម្ម ស្ថាបត្យកម្ម ការសិក្សាស្រាវជ្រាវ គណនេយ្យ សេដ្ឋកិច្ច សុខុមាលភាព ថាមពល បរមាណូ រួមទាំងសេវាពិគ្រោះយោបល់។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ សេវាពិគ្រោះយោបល់ សំដៅដល់ សេវាផ្តល់ប្រឹក្សាដោយអ្នកជំនាញ ឬអ្នកដែលមានវិជ្ជាជីវៈទាក់ទិននឹងសេវាបច្ចេកទេសដូចមានចែងក្នុងវាក្យខណ្ឌនេះ
- ចំណាយបន្ទាប់បន្សំគាំទ្រដល់ការផ្គត់ផ្គង់សេវាគ្រប់គ្រងនិងសេវាបច្ចេកទេស និងទូទាត់ឱ្យទៅអ្នកផ្គត់ផ្គង់សេវាគ្រប់គ្រងនិងសេវាបច្ចេកទេសនោះ ត្រូវចាត់ទុកថាជាផ្នែកមួយនៃសេវាគ្រប់គ្រងនិងសេវាបច្ចេកទេស។

ង- ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យឬអចលនទ្រព្យ ក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ច- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបីដែលបានទូទាត់ដោយបុគ្គលនិវាសនជនឬបុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ សួយសារចំពោះទ្រព្យសកម្មអរូបី សំដៅដល់៖

- ការអនុញ្ញាតឱ្យប្រើប្រាស់នូវសិទ្ធិបោះពុម្ពផ្សាយនិងលក់ស្នាដៃអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬសិទ្ធិប្រហាក់ប្រហែល (រួមទាំងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងផ្សាយខ្សែអាត់សំឡេងឬវីដេអូ...) ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអាជីវកម្ម ម៉ាកឬពាណិជ្ជនាម គំនូរ គំរូប្លង់ គម្រោង រូបមន្ត ការសម្ងាត់អំពីវិធីផលិត... ជារួមគឺអ្វីៗទាំងអស់ដែលជាកម្មសិទ្ធិអរូបី ឬសិទ្ធិផ្សេងៗ

- ចំណេះដឹង ឬចំណេះធ្វើ ឬព័ត៌មានទាក់ទិននឹងបទពិសោធន៍ផ្សេងៗក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន បច្ចេកទេស...

- ការផ្ទេរសិទ្ធិលើចំណេះឬព័ត៌មាន ដូចមានរៀបរាប់ក្នុងវាក្យខណ្ឌនេះ

- ការផ្តល់យោបល់ ឬការផ្តល់សេវាទាក់ទិននឹងការអនុវត្ត ឬការប្រើប្រាស់សិទ្ធិដូចមានចែងក្នុងវាក្យខណ្ឌនេះ។

សួយសារចំពោះទ្រព្យសកម្មអរូបី រួមបញ្ចូលផងដែរនូវការទូទាត់រាល់អត្ថប្រយោជន៍ផ្សេងៗពីភាគកម្មក្នុងធនធានរ៉ែ ក្រៅពីប្រាក់ចំណូលសុទ្ធបានមកពីអាជីវកម្មលើធនធាននេះ និងភាគលាភ។

ឆ- ផលចំណេញពីការលក់ចលនទ្រព្យឬអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃចលនទ្រព្យឬអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬចំណេញមូលធនពីទ្រព្យសកម្មហិរញ្ញវត្ថុនិងទ្រព្យសកម្មវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬចំណេញមូលធនពីការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនក្នុងដើមទុនផ្ទាល់របស់សហគ្រាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជ- បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ឈ-ផលចំណេញពីការលក់ចលនទ្រព្យដែលជាចំណែកនៃទ្រព្យសកម្មអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ញ-ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រាក់ចំណូលរបស់អ្នកជាប់ពន្ធអនិវាសនជន ដែលបានមកពីការផ្គត់ផ្គង់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលនឹងសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ដែលអ្នកជាប់ពន្ធអនិវាសនជននោះបានផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ប្រាក់ចំណូលណាមួយដែលមិនត្រូវបានកំណត់ថាជាប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវបានចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស។

៣-ក្នុងករណីដែលគ្មានព័ត៌មានគ្រប់គ្រាន់ដើម្បីកំណត់ប្រភពចំណូលដូចមានចែងក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីសារពើពន្ធ ឬប្រសិនបើវិធាននានាដែលអនុលោមតាមមាត្រា៣៣ នៃច្បាប់ស្តីពីសារពើពន្ធ ឬលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដទៃទៀត ពុំអាចឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ។

**ប្រការ៩**.- ប្រាក់ចំណូលជាប់ពន្ធ

១-ប្រាក់ចំណូលជាប់ពន្ធដូចមានចែងក្នុងមាត្រា៧ នៃច្បាប់ស្តីពីសារពើពន្ធ គឺជាប្រាក់ចំណូលសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទដែលសហគ្រាសសម្រេចបាន រួមបញ្ចូលទាំងតម្លៃលើសបានមកពីការលក់ចំណែកនានា នៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្មឬនៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល និងសួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង។ ប្រាក់ចំណូលជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគដែលរូបវន្តបុគ្គលឬនីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ការប្រកបអាជីវកម្មណាមួយទោះបីច្បាប់អនុញ្ញាតឬមិនអនុញ្ញាតក្តី មិនអាចរួចផុតពីការបង់ពន្ធលើប្រាក់ចំណូលឡើយ។

២-ប្រាក់ចំណូលជាប់ពន្ធកើតចេញពីការកាត់កងគ្នារវាងចំណូលដុល និងចំណាយទាំងអស់ដែលកើតចេញពីប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាសក្នុងរយៈពេលកំពុងដំណើរការឬនៅពេលបញ្ចប់អាជីវកម្ម។ តាមគោលការណ៍គណនេយ្យ ប្រាក់ចំណូលជាប់ពន្ធគឺជាសមតុល្យនៃគណនីលទ្ធផលដែលសម្រេចបានពីប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាស។ ប្រតិបត្តិការទាំងនេះ អាចទាក់ទងដោយផ្ទាល់នឹងសកម្មភាពរបស់សហគ្រាស ឬអាចមិនទាក់ទងដោយផ្ទាល់នឹងសកម្មភាពរបស់សហគ្រាស ដែលអាចប្រព្រឹត្តទៅក្នុងលក្ខណៈជាគោលដើមឬក្នុងលក្ខណៈបន្ទាប់បន្សំ។ ប្រតិបត្តិការទាំងនេះ មានជាអាទិ៍៖

ក- ការផ្គត់ផ្គង់ទំនិញឬសេវា ឬប្រតិបត្តិការដទៃទៀត (ជំនួញដើងសា ការងារយកកម្រៃជើងសា សម្បទានសិទ្ធិនៃទ្រព្យអរូបី...)។

ខ- ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្ម។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ ការបញ្ចេញ សំដៅដល់ប្រតិបត្តិការឬព្រឹត្តិការណ៍ណាមួយដែលនាំដល់ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្មរបស់សហគ្រាស មានជាអាទិ៍ ការលក់ ការដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ឧបហារិត (ការដាក់បញ្ចូលជាដើមទុន) ការដោះដូរ ការផ្តល់ជាអំណោយ ការដកចេញនូវទ្រព្យសកម្ម...។

គ- ចំពោះសហគ្រាសនីតិបុគ្គល ឬសហគ្រាសឯកបុគ្គល ត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធនូវ៖

- តម្លៃលើសនៃទ្រព្យសកម្មដែលបានលក់
- ទ្រព្យសកម្មដែលមិនបានលក់នាថ្ងៃផ្អាកសកម្មភាព (ទ្រព្យសកម្មរយៈពេលវែង ស្តុកទំនិញ វត្ថុធាតុដើម ការងារកំពុងដំណើរការ...) ត្រូវចាត់ទុកថាជាការយកវិញរបស់ម្ចាស់សហគ្រាស (ផ្ទេរពីទ្រព្យសកម្មអាជីវកម្មទៅទ្រព្យឯកជន)។ ទ្រព្យសម្បត្តិទាំងនេះ ត្រូវវាយតម្លៃតាមតម្លៃទីផ្សារ។

៣-ប្រាក់ចំណូលជាប់ពន្ធ គឺជាចំនួនលម្អៀងរវាងតម្លៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទនិងនាពេលបើកនៃរយៈពេលជាប់ពន្ធ។

ក- ប្រាក់ចំណូលជាប់ពន្ធ គឺជាចំនួនលម្អៀងរវាងតម្លៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទនិងនាពេលបើកនៃរយៈពេលមួយដែលលទ្ធផលក្នុងរយៈពេលនោះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់គិតពន្ធ ដោយត្រូវដកចេញនូវឧបហារិត និងបូកចូលនូវរាល់ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការកាត់យកមុនដែលម្ចាស់សហគ្រាសបានធ្វើនៅក្នុងគ្រា។ និយមន័យនេះបានបង្ហាញឱ្យឃើញថា នៅក្នុងប្រាក់ចំណូលជាប់ពន្ធក៏មានផងដែរនូវផលចំណេញទាំងឡាយដែលបានកើតឡើងក្នុងកាលៈទេសៈណាមួយ ដែលសហគ្រាសមិនបានធ្វើប្រតិបត្តិការ ដូចជា ករណីតម្លៃលើសដែលបានកើតឡើងក្នុងពេលដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ក្នុងពេលរឹបអូស ឬក្នុងពេលមានព្រឹត្តិការណ៍ដែលនាំដល់ការទទួលប្រាក់សំណងជានារ៉ាប់រង។

ខ- ទ្រព្យសកម្មសុទ្ធ គឺជាតម្លៃពិតនៃទ្រព្យសកម្មសរុប ដកផលបូកនៃខ្ទង់នានាខាងគណនីបំណុលដែលក្នុងនោះមានឥណទេយ្យតតិយជន (បំណុលរយៈពេលវែងឬខ្លី) និងសំវិធានធនដែលបានបង្កើតឡើងដោយស្របច្បាប់។

- ទ្រព្យសកម្មសរុប រួមមានខ្ទង់សំខាន់ៗដូចខាងក្រោម៖
  - ទ្រព្យសកម្មរយៈពេលវែង មានជាអាទិ៍ ដីធ្លីរបស់សហគ្រាស ការរៀបចំតុបតែងដីធ្លីរបស់សហគ្រាស អគារ សំណង់របស់សហគ្រាស រោងចក្រ មូលនិធិពាណិជ្ជកម្ម ចំណាយបង្កើតសហគ្រាសដំបូង (ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍ និងចំណាយលើទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត៖ ចំណាយទាំងនេះមិនបង្កើតបានជាតម្លៃពិតប្រាកដនៃទ្រព្យសកម្មទេ)
  - ទ្រព្យសកម្មរយៈពេលខ្លី មានជាអាទិ៍ ស្តុក (ទំនិញ វត្ថុធាតុដើមនិងសម្ភារផ្គត់ផ្គង់ផ្សេងៗ ការងារកំពុងដំណើរការ ផលិតផលសម្រេច...) បណ្ណបណ្តាក់ទុនផ្សេងៗ ប្រាក់នៅធនាគារ ប្រាក់ក្នុងបេឡា...។
- ឥណទេយ្យនៃតតិយជន៖ គឺជាបំណុលពិតប្រាកដនិងជាស្ថាពរទាំងគោលការណ៍ និងទាំងទឹកប្រាក់បំណុលដែលបានចុះកិច្ចសន្យាសម្រាប់តម្រូវការអាជីវកម្ម និងដែលផ្សារភ្ជាប់នឹងការគ្រប់គ្រងធម្មតារបស់សហគ្រាស
- សំវិធានធន៖ ខ្ទង់ទាំងនេះត្រូវតែបានបង្កើតឡើងដោយស្របច្បាប់។



ᠠ

គ- ឧបហារិត៖ ឧបហារិតទោះជាប្រាក់ឬជាវត្ថុក្តី មិនមែនជាប្រាក់ចំណូលជាប់ពន្ធទេ។ ឧបហារិតដោយម្ចាស់សហគ្រាសឯកបុគ្គលនៅក្នុងករណីដែលមានសក្ខីកម្មត្រឹមត្រូវនោះ ត្រូវកាត់កងពីចំនួនលម្អៀងរវាងតម្លៃទ្រព្យសកម្មពិតនាពេលបិទនិងនាពេលបើកនៃរយៈពេលជាប់ពន្ធ។

ឃ-ការដកយកប្រើប្រាស់ផ្ទាល់ខ្លួន ឬការកាត់យកមុនរបស់ម្ចាស់សហគ្រាស មានជាអាទិ៍៖

- ការដកយកនូវវត្ថុធាតុដើម ផលិតផលសម្រេច ទំនិញ សេវា... សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស និងគ្រួសារ (ម្ហូបអាហារ សំលៀកបំពាក់ បរិក្ខារប្រើប្រាស់ក្នុងផ្ទះ សម្ភារ និងសេវាផ្សេងៗរបស់ម្ចាស់សហគ្រាសសំណង់...)
- ការប្រើប្រាស់ដែលជាតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសនូវទ្រព្យសកម្មរបស់សហគ្រាស (ផ្ទះ រថយន្ត...)។

ង- ការលក់ឱ្យភាគហ៊ុនិកនូវទំនិញឬសេវាតាមថ្លៃទាបជាងថ្លៃធម្មតា (ថ្លៃដំហោងដៃឬថ្លៃទីផ្សារ) ដែលអនុវត្តចំពោះអតិថិជនទូទៅ។

ច- ត្រូវបានកំណត់ជាប្រាក់ចំណូលជាប់ពន្ធផងដែរចំពោះ៖

- ការលុបចោលបំណុល
- ការកាត់បន្ថយបំណុល ដែលម្ចាស់បំណុលបានផ្តល់ឱ្យសហគ្រាស
- គណនីទុនម្ចាស់ទ្រព្យនិងបំណុលទាំងឡាយដែលគ្មានការពិត ឬគ្មានភស្តុតាងបញ្ជាក់
- ការបង្កើតឡើងវិញខាងទ្រព្យសកម្មនូវខ្ទង់ដែលមិនបានកត់ត្រា។

ឆ- រាល់ការប្រែប្រួលនៃទ្រព្យសកម្មសុទ្ធ ត្រូវបានអនុញ្ញាតឱ្យមានការកែតម្រូវលើរាល់ការខុសឆ្គង ដែលមាននៅក្នុងតារាងតុល្យការនៅពេលបញ្ចប់ការិយបរិច្ឆេទណាមួយ ហើយប្រសិនបើការកែតម្រូវនាំឱ្យមានការកើនឡើងខាងគណនីទ្រព្យសកម្ម ឬមានការថយចុះខាងគណនីបំណុល តម្រូវឱ្យមានការកំណត់ឡើងវិញនូវប្រាក់ចំណូលជាប់ពន្ធនៃការិយបរិច្ឆេទនោះ។ អ្នកជាប់ពន្ធមានសិទ្ធិកែតម្រូវតារាងតុល្យការនាពេលបើកការិយបរិច្ឆេទបន្តបន្ទាប់ដែលស្ថិតក្នុងរយៈពេលនៃអាជ្ញាយុកាលកែតម្រូវ លើកលែងតែតារាងតុល្យការនាពេលបើកនៃការិយបរិច្ឆេទដំបូង។

**ប្រការ១០ .–** ប្រាក់ចំណូលលើកលែងពន្ធ

ប្រាក់ចំណូលលើកលែងពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលរបស់ស្ថាប័នរាជរដ្ឋាភិបាល។

២-ប្រាក់ចំណូលរបស់៖

ក- អង្គការណាមួយ ដែលត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

ខ- សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់សមាគមទាំងនោះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬបវន្តបុគ្គល។

៣-ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមប្រការ៤៥ ប្រការ៤៩ និងប្រការ៥២ នៃប្រកាសនេះ ត្រូវបានបង់រួចរាល់។

៤- ក្នុងករណីប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការនេះ ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬបវន្តបុគ្គល ប្រាក់ចំណូលទាំងនោះត្រូវបានកំណត់ឱ្យជាប់ពន្ធឡើងវិញ។

៥-ក្នុងករណីសមាគមឬអង្គការដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការនេះ មានសកម្មភាពខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀតដែលមិនទាក់ទិនដល់គោលដៅឬមុខងារជាមូលដ្ឋាននៃការលើកលែងពន្ធរបស់ខ្លួន ប្រាក់ចំណូលដែលបានមកពីសកម្មភាពមិនទាក់ទិនទាំងនោះ ត្រូវជាប់ពន្ធតាមប្រការ៤៩ នៃប្រកាសនេះ។

## ផ្នែកទី២
## វិធានទូទៅស្តីពីស្តុក ការងារកំពុងដំណើរការ និងទ្រព្យសកម្មអាជីវកម្ម

**ប្រការ១១ ._** និយមន័យនៃស្តុក

១- ស្តុកកើតចេញពីទ្រព្យសកម្មទាំងអស់ជាកម្មសិទ្ធិរបស់សហគ្រាស គឺទ្រព្យសកម្មដែលចូលរួមក្នុងវដ្តនៃអាជីវកម្មរបស់សហគ្រាស ដើម្បី៖

ក- លក់ក្នុងសភាពដើម ឬលក់ក្រោយការកែច្នៃ ឬក្រោយការផលិត ឬ

ខ- ប្រើប្រាស់អស់ក្នុងដំណាក់កាលប្រើប្រាស់ដំបូង។

២-ស្តុករួមមាន៖

ក- ទំនិញ សម្ភារផ្គត់ផ្គង់ (វត្ថុធាតុដើម សម្ភារប្រើប្រាស់ សម្ភារវេចខ្ចប់...) និងផលិតផល (ផលិតផលពាក់កណ្តាលសម្រេច ផលិតផលសម្រេច កាកសំណល់ ឬវត្ថុធាតុសម្រាប់យកទៅកែច្នៃឡើងវិញ)។

ខ- ការងារកំពុងដំណើរការ៖ គឺជាទ្រព្យសកម្ម ឬសេវា ដែលកំពុងកកើតឡើងនៅក្នុងដំណើរការផលិតកម្ម។

៣-ត្រូវចាត់ទុកជាស្តុកផងដែរនូវរាល់ផលិតផលឬទំនិញឬវត្ថុធាតុដើមដែលជាកម្មសិទ្ធិរបស់សហគ្រាស ទោះបីស្ថិតនៅក្នុងឬនៅក្រៅទីតាំងផ្ទាល់របស់សហគ្រាសក៏ដោយ។

៤-នៅពេលធ្វើសារពើភណ្ឌ ប្រសិនបើផលិតផលឬទំនិញឬវត្ថុធាតុដើមដែលសហគ្រាសមិនទាន់បានទទួលមានភាពប្រាកដប្រជាថាជាកម្មសិទ្ធិរបស់សហគ្រាសហើយនោះ ត្រូវតែឆ្លុះបញ្ចាំងក្នុងស្តុក និងត្រូវកត់ត្រាចូលតារាងតុល្យការនៃការិយបរិច្ឆេទ។

៥- ផលិតផលឬទំនិញឬវត្ថុធាតុដើម ដែលស្តុកទុកនៅក្នុងឃ្លាំងនានានៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា ឬដែលបានប្រគល់ឱ្យអ្នកក្រៅថែទាំ ឬជាបញ្ញើ ឬជាការដាក់ធានា ឬជាការឱ្យខ្ចី ត្រូវតែឆ្លុះបញ្ចាំងក្នុងទ្រព្យសកម្មនៃសហគ្រាសដែលនៅតែជាម្ចាស់កម្មសិទ្ធិ។

៦- ត្រូវបានចាត់ទុកជាស្តុក ប្រសិនបើផលិតផលឬទំនិញបានបំពេញលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

ក- ផលិតផលឬទំនិញឬវត្ថុធាតុដើម ជាកម្មសិទ្ធិរបស់សហគ្រាសនាថ្ងៃធ្វើសារពើភណ្ឌ ទោះបីផលិតផលឬទំនិញមិនស្ថិតក្នុងឃ្លាំងរបស់សហគ្រាសក៏ដោយ។

ខ- ផលិតផលឬទំនិញឬវត្ថុធាតុដើម មានគោលដៅទុកសម្រាប់លក់ទៅវិញក្នុងសភាពដើម ឬបន្ទាប់ពីកែច្នៃរួច ឬទុកសម្រាប់ផលិត (គឺចំណែកនៃទ្រព្យសកម្មរយៈពេលខ្លីរបស់សហគ្រាសដែលមិនអាចធ្វើជាទ្រព្យសកម្មរយៈពេលវែងបាន)។

៧-ទ្រព្យសកម្មកំពុងដំណើរការ គឺជាទ្រព្យសកម្មកំពុងប្រព្រឹត្តទៅឬកំពុងដំណើរការនិងមិនទាន់ត្រូវបានបញ្ចប់នាពេលបញ្ចប់ការិយបរិច្ឆេទ។ ទ្រព្យសកម្មកំពុងដំណើរការច្រើនកើតមាននៅក្នុងសហគ្រាសសំណង់ សហគ្រាសសាធារណការ និងបណ្តាសហគ្រាសដែលអនុវត្តការងារ ដោយឧបករណ៍ធុនធ្ងន់ និងដែលប្រើរយៈពេលវែងក្នុងដំណើរការឬផលិត។

៨-សហគ្រាសមិនត្រូវឆ្លុះបញ្ចាំងក្នុងស្តុកទេ នូវទ្រព្យដែលបានប្រគល់ តែមិនទាន់ចេញវិក្កយបត្រ។

៩-គណនីស្តុក និងគណនីផលិតផលកំពុងផលិត អាចត្រូវបានបែងចែកជា៖

ក- គណនីវត្ថុធាតុដើម និងសម្ភារផ្គត់ផ្គង់៖ កត់ត្រានូវវត្ថុនិងវត្ថុធាតុបានកែច្នៃតិចឬច្រើន ដែលសម្រាប់បញ្ចូលក្នុងធាតុផ្សំនៃផលិតផលកំពុងកែច្នៃឬផលិត។

ខ- គណនីផ្គត់ផ្គង់ផ្សេងៗ៖ កត់ត្រានូវវត្ថុនិងវត្ថុធាតុបានកែច្នៃតិចឬច្រើន ដែលប្រើប្រាស់អស់នៅពេលប្រើដំបូង ឬប្រើប្រាស់អស់ដោយឆាប់រហ័សក្នុងការផលិតឬកែច្នៃ និងមិនចូលក្នុងធាតុផ្សំនៃផលិតផលដែលបានផលិតឬកែច្នៃ ឬប្រើប្រាស់ក្នុងអាជីវកម្មជាសំបកវេចខ្ចប់។ គណនីនេះ រួមមាន៖

- វត្ថុធាតុប្រើប្រាស់
- សម្ភារផ្គត់ផ្គង់ប្រើប្រាស់៖
  - គ្រឿងឆេះ
  - សម្ភារថែទាំ

- សម្ភារផ្គត់ផ្គង់រោងជាង និងរោងចក្រ
- សម្ភារផ្គត់ផ្គង់ឃ្លាំង
- សម្ភារផ្គត់ផ្គង់ការិយាល័យ។

- សំបកវេចខ្ចប់៖
  - សំបកវេចខ្ចប់មិនប្រមូលវិញ
  - សំបកវេចខ្ចប់ប្រមូលវិញដែលមិនអាចកត់ភិនភាគបាន។

គ- គណនីកំពុងដំណើរការសម្រាប់ផលិតផល៖ កត់ត្រាផលិតផលកំពុងផលិត និងការងារកំពុងដំណើរការ។

ឃ-គណនីកំពុងដំណើរការសម្រាប់សេវា៖ កត់ត្រាការសិក្សាស្រាវជ្រាវ និងការផ្គត់ផ្គង់សេវា ដែលមិនទាន់ចប់ និងដែលអនុវត្តតាមកិច្ចសន្យាមួយដែលមិនបានគ្រោងទុកនូវការផ្ទេរកម្មសិទ្ធិជាបណ្តើរៗ ឬកត់ត្រាការសិក្សាស្រាវជ្រាវ និងការផ្គត់ផ្គង់សេវាដែលបានចប់ហើយតែកិច្ចសន្យាបានចែងថាទាល់តែមានការយល់ព្រមរបស់អតិថិជនលើតម្លៃទើបការងារនេះក្លាយជាឥណទេយ្យបាន។

ង- ស្តុកផលិតផល រួមមាន៖
- ផលិតផលពាក់កណ្តាលសម្រេច គឺផលិតផលដែលបានដល់ដំណាក់កាលបង្កើយណាមួយ ប៉ុន្តែត្រូវទុកសម្រាប់បញ្ចូលក្នុងដំណាក់កាលថ្មីមួយទៀតនៃវដ្តនៃផលិតកម្ម
- ផលិតផលសម្រេច គឺផលិតផលដែលបានដល់ដំណាក់កាលបង្កើយជាស្ថាពរក្នុងវដ្តនៃផលិតកម្ម
- កាកសំណល់ គឺជាកាកសំណល់ពីផលិតកម្មដែលអាចលក់បាន (កម្ទេចកំណាត់ កម្ទេចឈើ កម្ទេចលោហធាតុ កម្ទេចក្រដាស...) ឬជាវត្ថុធាតុប្រមូលបាន ដូចជាបំណែក និងវត្ថុធាតុផ្សេងៗដែលប្រមូលបាននៅពេលដែលទ្រព្យសកម្មរយៈពេលវែងណាមួយត្រូវបានឈប់ប្រើប្រាស់ ឬត្រូវបានរុះរើដោះបំបែក។ វត្ថុធាតុទាំងនេះ ទុកសម្រាប់ប្រើប្រាស់ក្នុងវដ្តនៃអាជីវកម្ម ឬទុកសម្រាប់លក់។

ច- ស្តុកទំនិញ គឺជាទំនិញដែលសហគ្រាសទិញដើម្បីលក់ទៅវិញដោយមិនបាច់កែច្នៃ។

ឆ- ស្តុកកំពុងនៅតាមផ្លូវ៖
- វត្ថុធាតុសម្ភារផ្គត់ផ្គង់ឬទំនិញដែលមិនទាន់បានទទួលបញ្ចូលឃ្លាំង ប៉ុន្តែបានក្លាយជាកម្មសិទ្ធិរបស់សហគ្រាសរួចហើយ
- ផលិតផលឬទំនិញបញ្ចេញពីឃ្លាំងកំពុងប្រគល់ឱ្យអតិថិជន ប៉ុន្តែនៅជាកម្មសិទ្ធិរបស់សហគ្រាសនៅឡើយ
- វត្ថុធាតុសម្ភារផ្គត់ផ្គង់ផលិតផលឬទំនិញទុកនៅកន្លែងលក់ដែលស្ថិតនៅក្រៅទីស្នាក់ការ ឬផ្ញើទុកនៅតតិយជន។

**ប្រការ១២ ._** ការវាយតម្លៃស្តុក

ការវាយតម្លៃស្តុក អាចត្រូវបានអនុវត្តតាមវិធីដូចខាងក្រោម៖

១-ការវាយតម្លៃតាមបរិយាទានលទ្ធកម្ម (ថ្លៃដើមទំនិញដែលទទួលបាន) តាមថ្លៃទិញពិតដែលផ្សំឡើងដោយ៖

ក- ថ្លៃទិញតាមវិក្កយបត្រ។ ការចុះថ្លៃ ការបន្ថយថ្លៃ ឬការបង្វិលតម្លៃដែលពាក់ព័ន្ធនឹងការទិញ ដែលអ្នកផ្គត់ផ្គង់បានយល់ព្រមផ្តល់ឱ្យត្រូវកាត់ចេញពីថ្លៃទិញ។

ខ- ចំណាយបន្ទាប់បន្សំពាក់ព័ន្ធផ្ទាល់នឹងការទិញឬការផ្គត់ផ្គង់ដែលក្នុងនោះ មានជាអាទិ៍ ការដឹកជញ្ជូន សោហ៊ុយឆ្លងកាត់ ប្រាក់កម្រៃឬកម្រៃជើងសា ការលើកឬដាក់ទំនិញ ពន្ធគយនិងពន្ធអាករផ្សេងទៀត លើកលែងតែអាករលើតម្លៃបន្ថែមដែលអាចស្នើសុំជាឥណទានវិញបាន។ ចំណាយទូទៅនៃការផ្គត់ផ្គង់ និងចំណាយក្នុងការស្តុក មិនត្រូវគិតបញ្ចូលក្នុងបរិយាទានលទ្ធកម្មទេ។ ការខាតឬការខ្ចះខ្ចាយជាយថាហេតុព្រមទាំងចំណាយហិរញ្ញវត្ថុផង ក៏មិនត្រូវគិតបញ្ចូលក្នុងបរិយាទាននេះដែរ។

២-ការវាយតម្លៃតាមបរិយាទានផលិតកម្ម (ថ្លៃដើមផលិតផល) ដែលត្រូវផ្សំឡើងដោយ៖

ក- បរិយាទានលទ្ធកម្មនៃវត្ថុធាតុដើម ឬសម្ភារផ្គត់ផ្គង់ ដែលបានប្រើប្រាស់សម្រាប់ផលិតកម្ម។

ខ- ចំណាយដោយផ្ទាល់ដើម្បីនាំផលិតផលទៅដល់ទីកន្លែង និងតាមលក្ខខណ្ឌដែលផលិតផលនោះស្ថិតនៅជាក់ស្តែង។ សហគ្រាសអាចបូកបញ្ចូលនូវចំណាយមិនផ្ទាល់ក្នុងលក្ខខណ្ឌដែលចំណាយនោះអាចបញ្ចូលដោយសមហេតុសមផលទៅក្នុងបរិយាទានផលិតកម្មនៃស្តុក។

គ- មិនត្រូវគិតបញ្ចូលក្នុងបរិយាទានផលិតកម្មទេនូវចំណាយរដ្ឋបាលទូទៅ ចំណាយស្តុកផលិតផល ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍ និងចំណាយហិរញ្ញវត្ថុ។

៣- ការកំណត់បរិយាទានបញ្ចេញនៃស្តុក៖

ក- ចំពោះទំនិញ ឬផលិតផលដែលមានលក្ខណៈដាច់ដោយឡែកពីគ្នា បរិយាទាននៃស្តុក ត្រូវកំណត់តាមបរិយាទានបញ្ចូលនៃស្តុកទំនិញ ឬផលិតផលនីមួយៗនោះ។

ខ- ចំពោះទំនិញ ឬផលិតផលដែលអាចដោះដូរគ្នាបាន និងដែលមិនមានលក្ខណៈដាច់ដោយឡែកពីគ្នា ត្រូវបានអនុញ្ញាតឱ្យប្រើវិធីពីរយ៉ាងដូចខាងក្រោមនេះ សម្រាប់កំណត់បរិយាទាននៃស្តុក៖

- បរិយាទានមធ្យមភាគសមតា ដែលមានពីររបៀបដូចខាងក្រោម៖
  - បរិយាទានមធ្យមភាគសមតាប្រចាំខែ៖ ក្នុងនេះ បរិយាទានឯកតានៃស្តុកក្នុងខែណាមួយ ត្រូវស្មើនឹងផលបូកនៃបរិយាទាននៃស្តុកដើមខែ និងបរិយាទានចូលនៃការទិញឬផលិតកម្មទាំងអស់នៅក្នុងខែនោះ ចែកនឹងផលបូកនៃបរិមាណស្តុកដើមខែ និងបរិមាណនៃការទិញឬការផលិតទាំងអស់នៅក្នុងខែនោះ។ បរិយាទានឯកតាដែលបានគណនាឃើញនេះ ត្រូវយកទៅប្រើប្រាស់សម្រាប់វាយតម្លៃទំនិញចេញទាំងអស់នៅក្នុងខែនោះ
  - បរិយាទានមធ្យមភាគសមតាក្រោយពេលបញ្ចូលម្តងៗ៖ បរិយាទានឯកតានៃការបញ្ចេញស្តុកដែលបានធ្វើឡើងក្រោយការបញ្ចូលស្តុកណាមួយ ត្រូវស្មើនឹងផលបូកនៃបរិយាទានស្តុកដែលនៅសល់មុនការបញ្ចូលនិងបរិយាទាននៃការបញ្ចូល ចែកនឹងផលបូកនៃបរិមាណស្តុកដែលនៅសល់មុនការបញ្ចូល និងបរិមាណនៃការបញ្ចូល។ បរិយាទានឯកតាដែលបានគណនាឃើញនេះ ត្រូវយកទៅប្រើប្រាស់សម្រាប់វាយតម្លៃទំនិញចេញរហូតដល់មានការបញ្ចូលទំនិញថ្មីទៀត។
- វិធីចូលមុនចេញមុន (FIFO)៖ ទំនិញឬផលិតផលដែលចូលស្តុកមុនត្រូវបញ្ចេញមុន។
  - ក្នុងករណីសហគ្រាសប្រើប្រាស់វិធីគ្រប់គ្រងស្តុកតាមការិយបរិច្ឆេទ ស្តុកចុងក្រោយត្រូវវាយតម្លៃតាមបរិយាទានចូលនៃទំនិញឬផលិតផលដែលចូលក្រោយគេបំផុត
  - ក្នុងករណីសហគ្រាសប្រើប្រាស់វិធីចេញចូលជាអចិន្ត្រៃយ៍ ស្តុកចុងក្រោយត្រូវវាយតម្លៃតាមបរិយាទានទិញចូលជាក់ស្តែង។

**ប្រការ១៣ ._** ការវាយតម្លៃការងារកំពុងដំណើរការ

១- ការងារកំពុងដំណើរការ ត្រូវវាយតម្លៃតាមបរិយាទានផលិតកម្មដែលជាអាទិ៍ផ្សំឡើងដោយ៖

ក- បរិយាទាននៃសម្ភារដែលបានប្រើប្រាស់។

ខ- ចំណាយពលកម្ម។

គ- ចំណាយនានានៅការដ្ឋាន។

ឃ- មួយភាគនៃចំណាយទូទៅនៃស្នាក់ការកណ្តាល និងមួយភាគនៃរំលស់ដែលជាទូទៅច្រើនតែវាយតម្លៃតាមវិធីប៉ាន់ស្មាន។

២- សហគ្រាសមិនអាចយកមកគិតបញ្ចូលបានទេនូវចំណាយសុទ្ធសាធខាងពាណិជ្ជកម្ម និងខាងរដ្ឋបាល ព្រមទាំងចំណាយហិរញ្ញវត្ថុ។

**ប្រការ១៤ ._** ទ្រព្យសកម្មអាជីវកម្ម

១- ដោយហេតុថា តម្លៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទនិងពេលបើកការិយបរិច្ឆេទ ត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់គណនាប្រាក់ពន្ធ សហគ្រាសត្រូវកត់ត្រាទ្រព្យសកម្មអាជីវកម្មដែលជាចំណែកនៃទ្រព្យរបស់សហគ្រាសទៅតាមប្រភេទនីមួយៗឱ្យបានច្បាស់លាស់។

២-វៀរលែងតែដីនិងអគារដែលត្រូវអនុវត្តតាមវាក្យខណ្ឌ ខ នៃកថាខណ្ឌទី៥ នៃប្រការ៣៤ នៃប្រកាសនេះ ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសឯកបុគ្គល ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក- ម្ចាស់សហគ្រាសត្រូវញែកឱ្យដាច់ពីគ្នារវាងទ្រព្យសកម្មអាជីវកម្ម និងទ្រព្យឯកជនរបស់ម្ចាស់សហគ្រាស។ ការកត់ត្រាក្នុងតារាងតុល្យការបង្កើតជាលក្ខណវិនិច្ឆ័យខុសគ្នារវាងទ្រព្យសកម្មអាជីវកម្ម និងទ្រព្យឯកជន។

ខ- ម្ចាស់សហគ្រាសឯកបុគ្គល ពុំមានសិទ្ធិកត់ត្រាឬមិនកត់ត្រានូវចំណែកណាមួយនៃទ្រព្យសកម្មឬទុនម្ចាស់ទ្រព្យនិងបំណុលតាមការយល់ឃើញរបស់ខ្លួនឡើយ។

គ- ម្ចាស់សហគ្រាសឯកបុគ្គលត្រូវកត់ត្រាក្នុងតារាងតុល្យការនៃសហគ្រាសខ្លួននូវចំណែកទាំងអស់នៃទ្រព្យសកម្ម ព្រមទាំងទុនម្ចាស់ទ្រព្យនិងបំណុលដែលជាប់ទាក់ទិននឹងប្រតិបត្តិការអាជីវកម្មដូចខាងក្រោម៖

- រាល់ទ្រព្យសកម្មរយៈពេលវែងប្រើប្រាស់សម្រាប់ការធ្វើសកម្មភាពអាជីវកម្ម (មូលនិធិពាណិជ្ជកម្ម សម្ភារដឹកជញ្ជូន...) ត្រូវតែកត់ត្រាផងដែរក្នុងទ្រព្យសកម្មនៃតារាងតុល្យការនូវទ្រព្យសកម្មរយៈពេលវែងទាំងឡាយដែលប្រើប្រាស់ចម្រុះ (សម្រាប់ប្រើប្រាស់អាជីវកម្ម និងប្រើប្រាស់ផ្ទាល់ខ្លួន)
- រាល់ទ្រព្យសកម្មរយៈពេលខ្លីដែលទាក់ទិននឹងសកម្មភាពអាជីវកម្ម (ស្តុកទំនិញ ផលិតផល វត្ថុធាតុដើម ឥណទេយ្យ ប្រាក់ក្នុងដៃ...)
- ទុនម្ចាស់ទ្រព្យ និងបំណុលដែលទាក់ទិននឹងសកម្មភាពអាជីវកម្ម (ការខ្ចីបុលដើម្បីទិញទ្រព្យសកម្មរយៈពេលវែង បំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង...)។

ឃ-ម្ចាស់សហគ្រាសឯកបុគ្គល មិនត្រូវបានអនុញ្ញាតឱ្យកត់ត្រាក្នុងតារាងតុល្យការសហគ្រាសរបស់ខ្លួនទេនូវទ្រព្យដែលមិនទាក់ទិននឹងការធ្វើសកម្មភាពអាជីវកម្ម ក្នុងនោះ៖

- អចលនទ្រព្យឬចំណែកណាមួយនៃអចលនទ្រព្យដែលមិនបម្រើសកម្មភាពអាជីវកម្ម (ផ្ទះសម្រាប់ស្នាក់នៅ អគារសម្រាប់ស្នាក់នៅ...)
- ការឱ្យខ្ចីឬការខ្ចីបុល ដែលមិនទាក់ទិនដល់សកម្មភាពអាជីវកម្ម។

ដូច្នេះ តារាងតុល្យការនៃសហគ្រាសឯកបុគ្គល ត្រូវតែគូសបញ្ជាក់ឱ្យឃើញនូវរាល់ទ្រព្យដែលមានលក្ខណៈបម្រើអាជីវកម្មតាមចរិត តាមការដាក់ប្រើប្រាស់ ឬតាមគោលដៅ ដោយបង្ហាញតែតម្លៃទាំងនេះប៉ុណ្ណោះ។

ង- ការតម្រូវឱ្យមានការញែកដាច់ពីគ្នារវាងទ្រព្យសកម្មអាជីវកម្ម និងទ្រព្យឯកជន មានលក្ខណៈសំខាន់ណាស់ពីព្រោះ៖

- ចំណាយដែលជាមូលដ្ឋានសម្រាប់ការកំណត់ប្រាក់ចំណូលជាប់ពន្ធ ត្រូវតែជាចំណាយទាំងឡាយដែលទាក់ទិននឹងចំណែកនៃទ្រព្យសកម្មអាជីវកម្ម។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ ចំណាយទាំងឡាយដែលទាក់ទិននឹងទ្រព្យសកម្ម ប៉ុន្តែមិនបានកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការ មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ
- ការផ្ទេរទ្រព្យសកម្មអាជីវកម្មទៅទ្រព្យឯកជន ត្រូវបានចាត់ទុកថាជាការលក់ដែលបណ្តាលឱ្យមានតម្លៃលើសត្រូវជាប់ពន្ធ ឬតម្លៃខ្វះត្រូវកាត់ចេញពីប្រាក់ចំណូលជាប់ពន្ធ
- ប្រតិបត្តិការបញ្ច្រាស គឺការផ្ទេរទ្រព្យសកម្មពីទ្រព្យឯកជនទៅទ្រព្យសកម្មអាជីវកម្ម គឺជាឧបហារិត។ ឧបហារិតនេះ ត្រូវកត់ត្រាតាមតម្លៃពិតប្រាកដនាថ្ងៃដែលមានការផ្ទេរនេះ។

៣-ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសនីតិបុគ្គល ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក- ទ្រព្យសកម្មអាជីវកម្ម គឺជាទ្រព្យរបស់សហគ្រាស។ ជាគតិយុត្ត ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសនីតិបុគ្គល ត្រូវដាច់ដោយឡែកពីទ្រព្យរបស់អ្នកចូលហ៊ុនឬភាគហ៊ុនិក។

ខ- សម្រាប់សហគ្រាសដែលបង្កើតឡើងដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ទ្រព្យសកម្មនានាដែលអ្នកចូលហ៊ុនបានយល់ព្រមដាក់ជាកម្មសិទ្ធិរួម ត្រូវតែកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការ។

## ផ្នែកទី៣
## វិធានទូទៅស្តីពីចំណូលអាជីវកម្ម

**ប្រការ១៥ .-** គោលការណ៍ទូទៅនៃការទទួលស្គាល់ចំណូល

១- សហគ្រាសត្រូវអនុវត្តវិធានគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល សហគ្រាសត្រូវទទួលស្គាល់ចំណូលនៅក្នុងការិយបរិច្ឆេទដែលខ្ទង់ចំណូលបានកើតឡើង ទោះបីប្រាក់ចំណូលនោះត្រូវបានទូទាត់ឬមិនទាន់ទូទាត់ក្តី។

២- ចំពោះការផ្គត់ផ្គង់ទំនិញឬសេវា សហគ្រាសត្រូវកត់ត្រាជាចំណូលនៅពេលបានចេញវិក្កយបត្រប្រសិនបើវិក្កយបត្របានចេញមុនពេលបញ្ជូនទំនិញឬទទួលប្រាក់ ឬពេលបញ្ជូនទំនិញឬការបំពេញសេវា ឬពេលទូទាត់ប្រាក់។ ដោយឡែកសហគ្រាសដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ត្រូវអនុវត្តការទទួលស្គាល់ចំណូលតាមវិធានគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

៣- ក្នុងករណីទំនិញឬសេវាត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលណាមួយ សហគ្រាសត្រូវកត់ត្រាជាចំណូលនៅពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង ឬជាពេលដែលសេវាត្រូវបានបំពេញរួចរាល់។

៤- ក្នុងករណីទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ សហគ្រាសត្រូវកត់ត្រាជាចំណូលនៅពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាត្រូវបានបំពេញរួចរាល់។

៥- ចំពោះការផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួល ឬការផ្គត់ផ្គង់ទំនិញឬសេវាក្រោមកិច្ចសន្យា ឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើកឬការផ្គត់ផ្គង់សេវាជាប់បន្ត ទំនិញឬសេវាទាំងនោះត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះតែចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលដែលបានកំណត់ក្នុងកិច្ចសន្យា ឬរយៈពេលដែលច្បាប់បានកំណត់ ហើយសហគ្រាសត្រូវកត់ត្រាជាចំណូលនៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ នៅកាលបរិច្ឆេទណាមួយមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។

៦- ចំពោះភតិសន្យាហិរញ្ញវត្ថុ សហគ្រាសត្រូវកត់ត្រាជាចំណូលនៅកាលបរិច្ឆេទដែលកើតឡើងមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។

៧- ចំពោះសេវាខាងហិរញ្ញវត្ថុ វៀរលែងតែឥណទេយ្យដែលបានអនុញ្ញាតឱ្យធ្វើសំវិធានធនតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដែលធនាគារព្យួរទុកការប្រាក់ សហគ្រាសត្រូវកត់ត្រាជាចំណូលនៅកាលបរិច្ឆេទដែលបានទទួលការប្រាក់ ប្រាក់កម្រៃឬកម្រៃជើងសា ដូចមានចែងនៅក្នុងកិច្ចសន្យាផ្គត់ផ្គង់សេវាខាងហិរញ្ញវត្ថុ ឬកាលបរិច្ឆេទនៃការបង់ការប្រាក់ ប្រាក់កម្រៃឬកម្រៃជើងសា ប្រសិនបើការបង់ប្រាក់ត្រូវបានធ្វើឡើងមុនកាលបរិច្ឆេទដែលត្រូវបង់ប្រាក់។

៨- ចំពោះសហគ្រាសសំណង់ឬសហគ្រាសធ្វើសេវាសាងសង់ សហគ្រាសត្រូវកត់ត្រាជាចំណូលនៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ នៅកាលបរិច្ឆេទមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់តាមកិច្ចសន្យា និងកាលបរិច្ឆេទដែលតម្រូវឱ្យកត់ត្រា ជាចំណូលដែលត្រូវទទួលស្គាល់ក្នុងបញ្ជីគណនេយ្យស្របតាមវិធានគណនេយ្យនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**ប្រការ១៦ .-** លក្ខខណ្ឌបន្ថែមក្នុងការទទួលស្គាល់ចំណូល

ចំពោះការផ្គត់ផ្គង់ទំនិញ ការទទួលស្គាល់ចំណូលកើតឡើងនៅពេលផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ដែលក្នុងករណីទូទៅត្រូវកើតឡើងនៅពេលប្រគល់ទំនិញ។ ការផ្គត់ផ្គង់ទំនិញអាចធ្វើឡើងក្រោមលក្ខខណ្ឌដូចខាងក្រោម៖

១- ការផ្គត់ផ្គង់ក្រោមលក្ខខណ្ឌព្យួរកិច្ចសន្យា៖ ក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ ត្រូវចំណុះទៅនឹងការសម្រេចបាននូវព្រឹត្តិការណ៍អ្វីមួយក្នុងអនាគត។ ផ្ទុយទៅវិញ បើព្រឹត្តិការណ៍នោះមិនកើតឡើង កិច្ចសន្យានឹងត្រូវព្យួរទុករហូតដល់ពេលដែលព្រឹត្តិការណ៍កើតឡើងដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ និងធ្វើឱ្យខ្ទង់ចំណូលមានភាពអាចទារបាន។

២-ការផ្គត់ផ្គង់ក្រោមលក្ខខណ្ឌរំលាយកិច្ចសន្យា៖ ក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់ត្រូវបានធ្វើឡើងភ្លាមៗ ដូចគ្នានឹងការផ្គត់ផ្គង់តាមកិច្ចសន្យាសាមញ្ញដែរ ប៉ុន្តែកិច្ចសន្យាត្រូវលុបចោលវិញ ប្រសិនបើលក្ខខណ្ឌដែលបានគ្រោងទុកក្លាយទៅជាពិត។ ដូច្នេះប្រាក់ចំណូលត្រូវទទួលស្គាល់ក្នុងការិយបរិច្ឆេទដែលមានការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ឬសិទ្ធិប្រើប្រាស់។ ប្រសិនបើក្រោយមកលក្ខខណ្ឌរំលាយកិច្ចសន្យាក្លាយទៅជាពិត ការលុបចោលនូវការផ្គត់ផ្គង់ត្រូវទទួលស្គាល់ក្នុងការិយបរិច្ឆេទដែលលក្ខខណ្ឌបានក្លាយទៅជាពិត។

៣-ប្រាក់កាត់ទុកដើម្បីធានា៖ ចំពោះប្រាក់ដែលអ្នកទិញបានកាត់ទុកជាបណ្ដោះអាសន្នដើម្បីធានាលើគុណភាពការងារដែលបានផ្គត់ផ្គង់ អ្នកផ្គត់ផ្គង់ត្រូវគិតបញ្ចូលក្នុងលទ្ធផលនៃការិយបរិច្ឆេទចន្លោះនាពេលប្រគល់ទទួលការងារ ឬនាពេលដាក់ការងារឱ្យនៅក្រោមការទទួលខុសត្រូវរបស់ម្ចាស់កម្មសិទ្ធិនៃការងារនោះ។

៤-ប្រាក់កក់៖ ប្រាក់កក់ដែលអ្នកទិញបានបង់ជាមុននាពេលបញ្ជាទិញទំនិញឬសេវា ដែលជាចំណែកមួយនៃថ្លៃទិញទំនិញឬសេវា ហើយអ្នកផ្គត់ផ្គង់ត្រូវកត់ត្រាប្រាក់កក់នេះជាចំណូលនាថ្ងៃទទួលប្រាក់។

**ប្រការ១៧** ._ ចំណូលពីសកម្មភាពអាជីវកម្ម

ចំណូលពីសកម្មភាពអាជីវកម្ម គឺជាចំណូលដែលបានមកពីការផ្គត់ផ្គង់ទំនិញឬសេវាដែលជាសកម្មភាពអាជីវកម្មដែលមានបញ្ជាក់នៅលើបណ្ណបង់ពន្ធប៉ាតង់របស់សហគ្រាស។ ចំណូលពីសកម្មភាពអាជីវកម្ម រួមបញ្ចូលទាំងការទទួលស្គាល់ចំណូលដែលកើតអំពីការយកទំនិញឬសេវាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលណាម្នាក់ផងដែរ។ ចំណូលពីសកម្មភាពអាជីវកម្មដូចមានចែងក្នុងប្រការនេះ និងចំណូលបន្ទាប់បន្សំដូចមានចែងក្នុងប្រការ១៨ នៃប្រកាសនេះ គឺជាផលរបរដែលជាមូលដ្ឋានសម្រាប់គណនាប្រាក់រំដោះពន្ធលើប្រាក់ចំណូលឬពន្ធអប្បបរមា។

**ប្រការ១៨** ._ ចំណូលបន្ទាប់បន្សំ

ចំណូលបន្ទាប់បន្សំ គឺជាចំណូលទាំងឡាយដែលមិនមែនជាចំណូលពីសកម្មភាពអាជីវកម្មរបស់សហគ្រាស ប៉ុន្តែត្រូវគិតបញ្ចូលផងដែរទៅក្នុងប្រាក់ចំណូលរបស់សហគ្រាស។ ចំណូលបន្ទាប់បន្សំ មានជាអាទិ៍៖

១-ចំណូលពីការជួលអចលនទ្រព្យ ទោះបីជាអចលនទ្រព្យនោះចូលរួមឬមិនចូលរួមក្នុងសកម្មភាពអាជីវកម្មក្ដី។

២-អចលនទ្រព្យដាក់ឱ្យតតិយជនប្រើប្រាស់ដោយឥតគិតថ្លៃ ត្រូវកំណត់ថាសហគ្រាសបានទទួលចំណូលជាប់ពន្ធ ដែលមានទឹកប្រាក់ស្មើនឹងថ្លៃឈ្នួលតាមទីផ្សារនៃអចលនទ្រព្យ។

៣-អចលនទ្រព្យដាក់ឱ្យនិយោជិតប្រើប្រាស់ជាលក្ខណៈឯកជនដោយឥតគិតថ្លៃ ត្រូវកំណត់ថាសហគ្រាសបានទទួលចំណូលជាប់ពន្ធ ដែលមានទឹកប្រាក់ស្មើនឹងថ្លៃឈ្នួលតាមទីផ្សារនៃអចលនទ្រព្យ វៀរលែងតែអចលនទ្រព្យដែលដាក់ឱ្យកម្មករនិយោជិតប្រើប្រាស់ជារួមស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

៤-សួយសារ៖ ចំណូលបានមកពីអាជីវកម្មលើទ្រព្យសកម្មអរូបីផ្សេងៗ មានជាអាទិ៍ ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គំនូរ គំរូប្លង់ សិទ្ធិអាជីវកម្ម សញ្ញាផលិត វិធីធ្វើ។

៥-ចំណូលបន្ទាប់បន្សំដទៃទៀត មានជាអាទិ៍ ចំណូលពីការលក់កាកសំណល់ ការជួលសម្ភារអាជីវកម្ម ប្រាក់ចំណូលពីសំបកវេចខ្ចប់។

**ប្រការ១៩** ._ ចំណូលផ្សេងៗ

ក្រៅពីចំណូលពីសកម្មភាពអាជីវកម្មនិងចំណូលបន្ទាប់បន្សំ សហគ្រាសនៅមានចំណូលផ្សេងៗជាច្រើនទៀតដែលត្រូវបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធ មានជាអាទិ៍៖

១-ចំណូលពីមូលបត្រ ភាគហ៊ុន និងចំណូលភាគលាភ។

២-ចំណូលហិរញ្ញវត្ថុ (ចំណូលពីឥណទេយ្យ ប្រាក់ធានា គណនីបញ្ញើ គណនីចរន្ត...)។

៣-ប្រាក់ចំណូលពីសកម្មភាពដែលបានធ្វើឡើងសម្រាប់ជាប្រយោជន៍បុគ្គលិក។

៤- អំណោយនិងឧបត្ថម្ភធនៈ

ក- អំណោយនិងឧបត្ថម្ភធន ត្រូវគិតបញ្ចូលក្នុងចំណូលជាប់ពន្ធនៃការិយបរិច្ឆេទដែលបានទទួលអំណោយនិងឧបត្ថម្ភធនទាំងនេះ។ អំណោយនិងឧបត្ថម្ភធន មានជាអាទិ៍ៈ

- អំណោយផ្សេងៗ ទោះបានពីប្រភពណាក៏ដោយ
- ឧបត្ថម្ភធនសម្រាប់អាជីវកម្មដែលរដ្ឋ សមូហភាពសាធារណៈ តតិយជន... បានផ្តល់ឱ្យ (ប្រាក់ប៉ះប៉ូវសម្រាប់បំពេញថ្លៃ ឧបត្ថម្ភធនសម្រាប់សម្រាលបន្ទុកអាជីវកម្ម ឧបត្ថម្ភធនសម្រាប់ធានាលំនឹង...)។

ខ- ឧបត្ថម្ភធនវិនិយោគៈ

- ចំពោះឧបត្ថម្ភធនវិនិយោគសម្រាប់ទ្រព្យសកម្មថ្នាក់១ ដែលមានតម្លៃចាប់ពី ៤០ ០០០ ០០០ (សែសិបលាន) រៀល ឡើងទៅ សហគ្រាសមិនត្រូវកត់ត្រាជាចំណូលទាំងស្រុងសម្រាប់ឆ្នាំជាប់ពន្ធទេ។ ក្នុងករណីនេះ សហគ្រាសត្រូវកត់ត្រាឧបត្ថម្ភធនវិនិយោគមួយចំណែកម្តងៗ ជាចំណូលជាប់ពន្ធ។ សម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ ចំណែកដែលត្រូវកត់ត្រាជាចំណូលជាប់ពន្ធ ត្រូវមានទឹកប្រាក់ស្មើគ្នានឹងរំលស់នៃទ្រព្យសកម្មដែលបានទទួលឬដែលបានបង្កើតដោយសារឧបត្ថម្ភធនវិនិយោគក្នុងឆ្នាំជាប់ពន្ធដដែលនោះ

**ឧទាហរណ៍ទី៦ៈ**

ចំពោះទ្រព្យសកម្មក្នុងថ្នាក់១ ដែលមានអត្រារំលស់ស្មើភាគ ៥% និងដែលត្រូវបានទទួលមកដោយឧបត្ថម្ភធនក្នុងតម្លៃ ១០០ ០០០ ០០០ រៀល ចំណែកត្រូវកត់ត្រាជាចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ គឺត្រូវស្មើនឹង ៥ ០០០ ០០០ រៀល (លើកលែងតែឆ្នាំបញ្ចប់រំលស់)។

- សម្រាប់ទ្រព្យសកម្មដែលស្ថិតនៅក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ ឧបត្ថម្ភធនវិនិយោគត្រូវកត់ត្រាជាចំណូលជាប់ពន្ធទាំងស្រុង ដោយកាត់កងតាមតារាងរំលស់ដើម្បីកំណត់ចំនួនសមស្របសម្រាប់រំលស់ទ្រព្យសកម្មនៅឆ្នាំទីមួយដែលទ្រព្យទាំងនោះត្រូវបានដាក់ប្រើប្រាស់។

៥- ការសាងសង់ឬកែលម្អអចលនទ្រព្យដែលអ្នកជួលធ្វើឡើងដោយសោហ៊ុយផ្ទាល់ខ្លួន និងដោយមិនបានគិតថ្លៃពីសហគ្រាសវិញ ដែលនាំឱ្យមានការកើនឡើងនូវតម្លៃនៃអចលនទ្រព្យ។ កំណើននៃតម្លៃអចលនទ្រព្យដែលនៅសល់ត្រូវគិតបញ្ចូលទៅក្នុងប្រាក់ចំណូលជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធដែលអចលនទ្រព្យត្រូវបានប្រគល់មកវិញ។

៦- តម្លៃលើសពីការលក់ឬឈប់ប្រើប្រាស់ទ្រព្យសកម្មអាជីវកម្ម។

៧- សំណងធានារ៉ាប់រងៈ សំណងធានារ៉ាប់រងដែលសហគ្រាសបានទទួលក្រោយពេលកើតមានមហន្តរាយ (អគ្គិភ័យ ចោរកម្ម ការខូចខាតទ្រព្យសកម្មផ្សេងៗ...) ឬនៅក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងដែលបានចុះកិច្ចសន្យាសម្រាប់ជាប្រយោជន៍ដល់សហគ្រាស។ ប្រាក់សំណងនេះ ត្រូវកត់ត្រាក្នុងចំណូលជាប់ពន្ធរបស់សហគ្រាស។ ដោយឡែក ការខាតបង់និងចំណាយរបស់សហគ្រាសក្នុងការដាក់ឱ្យដំណើរការឡើងវិញនូវទ្រព្យសកម្មដែលខូចខាតត្រូវកត់ត្រាជាចំណាយ។

៨- សំណងផ្សេងៗ មានជាអាទិ៍ៈ

ក- សំណងចំពោះការកេណ្ឌប្រមូលយកទៅប្រើប្រាស់នូវមធ្យោបាយផ្សេងៗដូចជា កាណូតដែលរដ្ឋបានកេណ្ឌឱ្យទៅដឹកប្រជាជនពេលមានគ្រោះទឹកជំនន់...។

ខ- សំណងពីការលុបកិច្ចសន្យា។

គ- សំណងផ្តល់ឱ្យជាជំងឺចិត្ត។

ឃ-សំណងការខូចខាតដោយការធ្វើអាជីវកម្មប្រជែងគ្នាមិនស្មោះត្រង់។

៩- ការបន្ធូរបន្ថយនូវពន្ធអាករដែលកាលពីមុនបានកាត់ចេញពីប្រាក់ចំណូលជាប់ពន្ធៈ ប្រាក់បន្ធូរបន្ថយនេះ គឺជាចំណូលនៃការិយបរិច្ឆេទដែលសហគ្រាសបានទទួលផលប្រយោជន៍នេះ។

១០- ការបន្ថយបំណុលៈ ការបន្ថយបំណុលដែលអ្នកផ្គត់ផ្គង់ឬតតិយជនបានយល់ព្រមផ្តល់ឱ្យសហគ្រាស និងដែលបានធ្វើឱ្យមានការកើនឡើងនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស ត្រូវកត់ត្រាជាចំណូលនៃការិយបរិច្ឆេទដែលសហគ្រាសបានទទួលការយល់ព្រមបន្ថយនេះ។

# ផ្នែកទី៤
# វិធានទូទៅស្តីពីចំណាយ

**ប្រការ២០ ._** គោលការណ៍សម្រាប់ចំណាយអាជីវកម្ម

១- ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កង៖ គឺជាចំណាយសម្រាប់អាជីវកម្មដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ និងដែលមិនបញ្ចូលមកវិញនូវទ្រព្យសកម្ម ឬដែលគ្មានការលុបបំណុលណាមួយ។

២- ចំណាយបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ៖ ចំណាយក្នុងឆ្នាំជាប់ពន្ធណាមួយអាចកាត់កងបានតែក្នុងឆ្នាំជាប់ពន្ធនោះ។ ចំណាយដែលអាចកាត់កងបានត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ២១ នៃប្រកាសនេះ។ អ្នកជាប់ពន្ធមិនអាចរំកិលកាលបរិច្ឆេទកត់ត្រាចំណាយពីឆ្នាំជាប់ពន្ធមួយទៅឆ្នាំជាប់ពន្ធមួយទៀតបានឡើយ។ ដើម្បីកំណត់លទ្ធផលនៃឆ្នាំជាប់ពន្ធណាមួយ ត្រូវគិតបញ្ចូលតែហេតុការណ៍និងប្រតិបត្តិការទាំងឡាយណាដែលនាំឱ្យលទ្ធផលនោះសម្រេចបានតែប៉ុណ្ណោះ ដូចខាងក្រោម៖

ក- ចំណាយដែលទាក់ទិននឹងឆ្នាំជាប់ពន្ធមុនៗ៖ វៀរលែងតែចំណាយដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី២ នៃប្រការ២១ នៃប្រកាសនេះ ចំណាយណាមួយដែលបានកើតឡើង និងជាកម្មវត្ថុត្រូវកត់ត្រាជាចំណាយនៃឆ្នាំជាប់ពន្ធមុនណាមួយ មិនអាចយកមកកាត់កងក្នុងឆ្នាំជាប់ពន្ធចរន្តបានទេ។

ខ- ចំណាយមិនបានទូទាត់ក្នុងឆ្នាំជាប់ពន្ធ៖ ប្រសិនបើចំណាយមួយដែលស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២០ និងប្រការ២១ នៃប្រកាសនេះ ត្រូវជាចំណាយនៃឆ្នាំជាប់ពន្ធណាមួយ ប៉ុន្តែនៅពេលបិទបញ្ជីចំណាយនេះមិនទាន់បានទូទាត់នៅឡើយ សហគ្រាសត្រូវកត់ត្រាចំណាយនេះក្នុងគណនីត្រូវសង (ឈ្នួលផ្ទះមិនបានបង់ ពន្ធមិនបានបង់ក្នុងឆ្នាំជាប់ពន្ធ...)។ ក្នុងករណីមិនបានកត់ត្រាបែបនេះទេ ចំណាយនេះមិនអាចលើកយកទៅកត់ត្រាជាចំណាយនៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់បានឡើយ។

គ- ចំណាយនៃឆ្នាំជាប់ពន្ធបន្ទាប់៖ មិនត្រូវបានអនុញ្ញាតទេនូវការកត់បញ្ចូលទៅក្នុងឆ្នាំជាប់ពន្ធមួយនូវចំណាយដែលទាក់ទិននឹងឆ្នាំជាប់ពន្ធបន្ទាប់ៗ។

ឃ-ចំណាយទាំងឡាយដែលបានទូទាត់ជាមុន៖ ត្រូវកាត់ចេញតែពីចំណូលនៃឆ្នាំជាប់ពន្ធណាដែលចំណាយទាំងនោះបានកើតឡើងតែប៉ុណ្ណោះ។

៣-ចំណាយដើម្បីប្រកបអាជីវកម្ម៖ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែចំណាយណាមួយដែលបានធ្វើដើម្បីបម្រើអាជីវកម្ម ឬដើម្បីជាប្រយោជន៍នៃអាជីវកម្ម។ ដូច្នេះចំណាយណាដែលមិនផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងធម្មតា ឬដែលផ្តល់ប្រយោជន៍ដល់តតិយជន គឺមិនអាចកាត់កងបានទេ។ ចំណាយដែលមិនមែនជាចំណាយដើម្បីប្រកបអាជីវកម្ម មានជាអាទិ៍៖

ក- ចំណាយបម្រើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស (ចំណាយលំនៅឋាន ពន្ធផ្ទាល់ខ្លួន ចំណាយលើយានជំនិះប្រើប្រាស់ជាឯកជន សោហ៊ុយលើអ្នកបម្រើ លាភការផ្តល់ជូនម្ចាស់សហគ្រាសឯកបុគ្គល ឬសហព័ទ្ធ ប្រាក់កាត់យកផ្ទាល់ពីការទូទាត់របស់អតិថិជន...)។

ខ- ចំណាយលេចធ្លោ ឬស្តុកស្តម្ភហួសហេតុ ដែលគ្មានប្រយោជន៍ ឬមានប្រយោជន៍តិចតួចពេកដល់អាជីវកម្ម។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ ចំណាយស្តុកស្តម្ភហួសហេតុ សំដៅដល់ ចំណាយលើសពីតម្រូវការ ឬខ្ជះខ្ជាយហួសពីភាពសមហេតុសមផល ថ្លៃ ឬតម្លៃខ្ពស់មិនសមហេតុសមផល ឬលេចធ្លោហួសពេក។

៤-ចំណាយដែលមិនបញ្ចូលមកវិញនូវទ្រព្យសកម្មឬដែលគ្មានការលុបបំណុលណាមួយ៖ គឺជាចំណាយដែលបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស។ ដូចនេះ ចំណាយណាមួយដែលមិនបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស គឺមិនអាចកាត់កងបានទេ។ ចំណាយដែលមិនបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធ មានជាអាទិ៍៖

ក- ចំណាយដែលមិនមែនជាបន្ទុករបស់សហគ្រាសខ្លួនឯងផ្ទាល់។

ខ- ចំណាយដែលមានការបញ្ចូលមកវិញនូវចំណែកថ្មីមួយក្នុងទ្រព្យសកម្ម ឬដែលបណ្តាលឱ្យមានការកើនតម្លៃនៃចំណែកណាមួយនៃទ្រព្យសកម្ម។

គ- ចំណាយសម្រាប់បង្កើនអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មណាមួយ។

ឃ-ចំណាយដែលនាំឱ្យមានការលុបបំណុល (ការសងប្រាក់ខ្ចី ការទូទាត់ប្រាក់ជំពាក់អ្នកផ្គត់ផ្គង់...)។



៤

**ប្រការ២១ ._** គោលការណ៍សម្រាប់ចំណាយអាចកាត់កងបាន

១- សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ចំណាយនានាដូចមានចែងក្នុងប្រការ២០ នៃប្រកាសនេះ អាចអនុញ្ញាតឱ្យកាត់កងបាន លុះណាតែចំណាយទាំងនោះបំពេញនូវលក្ខខណ្ឌទាំងបី ដូចខាងក្រោម៖

ក- ហេតុការណ៍ដែលបណ្តាលឱ្យមានចំណាយបានកើតឡើង និងជាកាតព្វកិច្ចពិតប្រាកដរបស់សហគ្រាស មានន័យថា ភាពពិតរបស់ចំណាយនោះត្រូវបានបញ្ជាក់អះអាងដោយភស្តុតាងដែលអាចត្រួតពិនិត្យបាន (វិក្កយបត្រ ប្រតិវេទន៍គយ លិខិតឆ្លើយឆ្លងពាណិជ្ជកម្ម កិច្ចសន្យាខ្ចីប្រាក់ បណ្ណចំណាយ...)។

ខ- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលទាក់ទិននឹងចំណាយបានកើតឡើង៖

- ក្នុងករណីដែលចំណាយតម្រូវឱ្យមានការទូទាត់សងចំពោះការផ្គត់ផ្គង់ទ្រព្យសកម្ម ទំនិញឬសេវា លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចកើតឡើងនៅពេលដែលសហគ្រាសបានទទួលការផ្គត់ផ្គង់ទ្រព្យសកម្ម ទំនិញឬសេវា
- ក្នុងករណីដែលចំណាយបានកើតឡើងដោយសារសហគ្រាសបានប្រើប្រាស់ទ្រព្យសកម្ម ឬបានផ្គត់ផ្គង់ទំនិញឬសេវា លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចកើតឡើងនៅពេលដែលសហគ្រាសបានប្រើប្រាស់ទ្រព្យសកម្ម ឬនៅពេលដែលសហគ្រាសបានផ្គត់ផ្គង់ទំនិញឬសេវា
- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចត្រូវបានចាត់ទុកថាបានកើតឡើង នៅពេលដែលការទូទាត់ណាមួយដូចខាងក្រោមនេះ បានកើតឡើង៖
  - ការប៉ះប៉ូវឱ្យកម្មករ សំណងជំងឺចិត្ត ឬសំណងលើការបំពានកិច្ចសន្យា
  - ការបុះថ្លៃ ឬការបង្វិលសងវិញ
  - ប្រាក់រង្វាន់ផ្សេងៗ
  - សំណងលើការទទួលធានា ឬតាមកិច្ចព្រមព្រៀងផ្តល់សេវា
  - ប្រាក់ពន្ធនានាក្រៅពីឥណទានពន្ធបរទេស ពន្ធអប្បបរមា និងពន្ធលើប្រាក់ចំណូល។

គ- ចំណាយរបស់សហគ្រាសត្រូវបានកត់ត្រាច្បាស់លាស់ក្នុងបញ្ជីគណនេយ្យក្នុងឆ្នាំជាប់ពន្ធ ដោយត្រូវមានភស្តុតាងបញ្ជាក់ត្រឹមត្រូវអំពីចំនួនទឹកប្រាក់និងកាលបរិច្ឆេទ។

២-បន្ថែមលើលក្ខខណ្ឌទាំងបីដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ៖

ក- សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ដើម្បីអាចកាត់កងបាននូវចំណាយដែលមិនទាន់បានទូទាត់នៅដំណាច់ឆ្នាំជាប់ពន្ធ លុះណាតែចំណាយនោះ គឺជាបំណុលពិតប្រាកដរបស់សហគ្រាស។ ប្រសិនបើទឹកប្រាក់ដែលមិនបានទូទាត់មិនតំណាងឱ្យបំណុលពិតប្រាកដទេនោះ ការកាត់កងមិនត្រូវបានអនុញ្ញាតឡើយ។ ដើម្បីបញ្ជាក់នូវបំណុលពិតប្រាកដ ត្រូវតែមានកំហិតទារដោយម្ចាស់បំណុលជាមួយនឹងការរំពឹងដោយសមស្របថាបំណុលនឹងត្រូវទូទាត់ពិតប្រាកដដោយសហគ្រាស។

ខ- ចំពោះចំណាយប្រាក់បៀវត្សដែលត្រូវបើកឱ្យនិយោជិត សហគ្រាសអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចរន្ត ប្រសិនបើប្រាក់បៀវត្សនោះត្រូវបានបើកក្នុងអំឡុងពេល ១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់។ ក្នុងករណីចំណាយប្រាក់បៀវត្សដែលត្រូវបើកឱ្យនិយោជិតដូចមានចែងក្នុងវាក្យខណ្ឌនេះ មិនត្រូវបានទូទាត់ក្នុងរយៈពេល ១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់ ចំណាយនេះត្រូវបញ្ចូលជាចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធចរន្តវិញ។ ប៉ុន្តែប្រសិនបើមានការទូទាត់កើតឡើងក្រោយរយៈពេល ១៨០ថ្ងៃ ចំណាយត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ចំពោះតែការទូទាត់ដែលបានធ្វើឡើងក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះប៉ុណ្ណោះ។ គោលការណ៍ ១៨០ថ្ងៃ នេះមិនអនុវត្តចំពោះប្រាក់បម្រុងសម្រាប់សោធនរបស់និយោជិតឡើយ។

គ- ចំពោះចំណាយដែលត្រូវទូទាត់ឱ្យបុគ្គលទាក់ទិន សហគ្រាសអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចរន្ត ប្រសិនបើចំណាយនោះត្រូវបានបើកក្នុងអំឡុងពេល ១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់ លើកលែងតែចំណាយដែលអាចកាត់កងបាននៃសារពើភណ្ឌទ្រព្យជាមូលធន និងទ្រព្យដែលអាចរំលស់បាន។ ចំពោះចំណាយដែលត្រូវទូទាត់ឱ្យបុគ្គលទាក់ទិននិវាសនជនដែលមិនស្ថិតក្នុងរបបស្វ័យប្រកាស មិនត្រូវបានអនុញ្ញាតឱ្យកាត់កងមុនការទូទាត់ជាក់ស្តែងឡើយ។ ក្នុងករណីចំណាយដែលត្រូវទូទាត់ឱ្យបុគ្គលទាក់ទិនដូចមានចែងក្នុងវាក្យខណ្ឌនេះ

មិនត្រូវបានទូទាត់ក្នុងរយៈពេល ១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់ ចំណាយនេះត្រូវបញ្ចូលជាចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធចរន្តវិញ និងមិនត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទេ។

ឃ-ក្នុងករណីសហគ្រាសធ្វើការកែតម្រូវដោយខ្លួនឯង ដោយបញ្ចូលចំណាយដែលមិនបានទូទាត់មកជាចំណូលឆ្នាំជាប់ពន្ធចរន្តវិញ ដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃកថាខណ្ឌនេះ ក្នុងអំឡុងពេល ៣០ថ្ងៃក្រោយរយៈពេល ១៨០ថ្ងៃ សហគ្រាសមិនទទួលរងពន្ធបន្ថែមនិងការប្រាក់ទេ។ ក្នុងករណីសហគ្រាសមិនបានកែតម្រូវទាន់ពេលវេលា ពន្ធបន្ថែមនិងការប្រាក់ត្រូវចាប់ផ្តើមគិតពីខែបន្ទាប់ពីរយៈពេល ១៨០ថ្ងៃ។

**ប្រការ២២** ._ គោលការណ៍សម្រាប់ចំណាយមិនអាចកាត់កងបាន

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ក្រៅពីចំណាយដែលបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ២១ នៃប្រកាសនេះ ចំណាយផ្សេងទៀតទាំងអស់ គឺជាចំណាយមិនអាចកាត់កងបាន និងត្រូវបញ្ចូលមកជាចំណូលជាប់ពន្ធវិញ។

## ផ្នែកទី៥
## ចំណាយអាចកាត់កងបាន និងចំណាយមិនអាចកាត់កងបាន

**ប្រការ២៣** ._ ចំណាយបង្កើតសហគ្រាស

១- ចំណាយបង្កើតសហគ្រាស គឺជាចំណាយដែលបានចាយដើម្បីបង្កើតសហគ្រាស។ ចំណាយនេះមិនអាចកត់ត្រាបញ្ចូលក្នុងគណនីទ្រព្យសកម្មដទៃណាមួយទេ។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ចំណាយបង្កើតសហគ្រាសអាចត្រូវបានកាត់កងបានទាំងស្រុងក្នុងឆ្នាំជាប់ពន្ធដំបូង។ ប៉ុន្តែបើសហគ្រាសធ្វើការកាត់កងតាមការរំលស់វិញ ចំណាយទាំងនេះអាចធ្វើរំលស់ស្មើភាគក្នុងរយៈពេលមិនលើសពី ២ឆ្នាំជាប់ពន្ធបានទេ។ ចំណាយបង្កើតសហគ្រាស មានជាអាទិ៍៖

ក- ចំណាយបង្កើតសហគ្រាសនិងអភិវឌ្ឍន៍ដំបូង គឺជាចំណាយដែលទាក់ទិននឹងសកម្មភាពមុនពេលនិងនាពេលបង្កើតសហគ្រាស។ ចំណាយបង្កើតសហគ្រាសនិងអភិវឌ្ឍន៍ដំបូង មានជាអាទិ៍ ចំណាយសិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតសហគ្រាស ផ្សាយពាណិជ្ជកម្ម ដឹកនាំនិងត្រួតពិនិត្យការដ្ឋាន បណ្តុះបណ្តាលបុគ្គលិក បុរេហិរញ្ញប្បទាន និងជំនួយបច្ចេកទេស។

ខ- ចំណាយទាក់ទិននឹងលក្ខន្តិកៈរបស់ក្រុមហ៊ុន គឺជាចំណាយក្នុងពេលបង្កើតក្រុមហ៊ុន ពេលបន្ថែមឬបន្ថយមូលធនរបស់ក្រុមហ៊ុន ឬចំណាយដែលធ្វើឡើងក្នុងប្រតិបត្តិការប្រហាក់ប្រហែលណាមួយ (ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា...)។ ចំណាយទាក់ទិននឹងលក្ខន្តិកៈរបស់ក្រុមហ៊ុនមានជាអាទិ៍ ពន្ធប្រថាប់ត្រាលើលិខិតផ្សេងៗរបស់ក្រុមហ៊ុន (ឧបហារិត ការបង្កើនមូលធន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា...) ប្រាក់កម្រៃនៃការបង្កើតក្រុមហ៊ុន និងចំណាយធ្វើបែបបទស្របច្បាប់នៃប្រកាសនកិច្ច។

គ- ចំណាយក្នុងឱកាសចុះកិច្ចសន្យាខ្ចីបុល។

ឃ-ចំណាយក្នុងការទទួលទ្រព្យសកម្មរយៈពេលវែង ក្នុងនេះមានតែពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ កម្រៃជើងសា និងចំណាយលើលិខិតស្នាមតាមផ្លូវច្បាប់ប៉ុណ្ណោះ។ ឯចំណាយផ្សេងទៀត គឺជាចំណែកនៃបរិយាទាននៃទ្រព្យសកម្ម ឬជាចំណាយក្នុងឆ្នាំជាប់ពន្ធដែលចំណាយទាំងនោះបានកើតឡើង។

២- ចំណាយខាងក្រោមនេះ មិនកំណត់ថាជាចំណាយបង្កើតសហគ្រាសទេ៖

ក- ចំណាយដែលតែងតែកើតឡើងជាធម្មតាក្នុងឆ្នាំជាប់ពន្ធ(ចំណាយនៃការផ្សាយពាណិជ្ជកម្មទំនិញឬសេវា...)។

ខ- ចំណាយបបនកម្ម និងការផ្តុំដំឡើងដែលត្រូវបានគិតបញ្ចូលក្នុងតម្លៃទិញទ្រព្យសកម្មរយៈពេលវែងជាប់ពាក់ព័ន្ធ។

**ប្រការ២៤** ._ ការទិញ

១- ការទិញអាចបែងចែកជាបីប្រភេទដូចខាងក្រោម៖

ក- ការទិញដែលអាចស្តុកបាន ដូចជា គ្រឿងផ្គត់ផ្គង់ និងទំនិញ។

ខ- ការទិញមិនអាចស្តុកបានឬមិនបានស្តុក មានជាអាទិ៍ ទឹក អគ្គិសនី ប្រេងឥន្ធនៈនិងប្រេងរំអិល សម្ភារផ្គត់ផ្គង់តូចតាចសម្រាប់ការិយាល័យ ឧបករណ៍តូចតាចដែលត្រូវផ្លាស់ប្ដូរជាញឹកញាប់ (នៅដំណាច់ឆ្នាំជាប់ពន្ធ ការទិញប្រភេទនេះមិនត្រូវបានធ្វើនិយ័តកម្មដោយគណនីស្តុកទេ ប៉ុន្តែត្រូវធ្វើដោយគណនីចំណាយបានពិនិត្យកត់ត្រាមុន)។

គ- ការទិញសេវាដែលជាទឹកប្រាក់បានចាយឱ្យអ្នកទទួលម៉ៅការបន្តសម្រាប់ការផលិត ការបំប្លែង ការរក្សាផលិតផលទុកឱ្យបានយូរ ឬការជួសជុល ថែទាំ...។ អ្នកទទួលម៉ៅការបន្ត អាចជាអ្នកផលិតយកតែថ្លៃឈ្នួលពលកម្ម (អ្នកទិញជាអ្នកផ្តល់វត្ថុធាតុដើមឱ្យ) អ្នកទទួលម៉ៅការបន្តខាងឧស្សាហកម្ម ឬអ្នកទទួលម៉ៅការបន្តសម្រាប់ការផ្គត់ផ្គង់ទំនិញឬសេវា (តាមធម្មតាគឺមានការងារខាងសាធារណការ ការងារសាងសង់អគារ...)។

២-កំណត់ត្រានៃការទិញ៖ ការទិញត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យនាពេលទទួលវិក្កយបត្រ ទៅតាមបរិយាទានពិតនៃការទិញនោះ ដូចខាងក្រោម៖

ក- ចំពោះទ្រព្យសកម្មដែលទិញក្នុងស្រុក បរិយាទានទិញ គឺជាចំណាយពិតប្រាកដរបស់សហគ្រាសក្នុងការទិញដែលមានថ្លៃទិញ បូកចំណាយបន្ទាប់បន្សំដែលជាប់ទាក់ទិនដោយផ្ទាល់នឹងការទិញ មានជាអាទិ៍ ចំណាយដឹកជញ្ជូន ជានារ៉ាប់រង និងដកចេញនូវការបញ្ចុះថ្លៃផ្សេងៗដែលអ្នកផ្គត់ផ្គង់បានយល់ព្រមផ្តល់ឱ្យ។

ខ- ចំពោះទ្រព្យសកម្មរយៈពេលវែងដែលនាំចូល បរិយាទានទិញ មានជាអាទិ៍៖

- ថ្លៃទិញ
- ចំណាយដឹកជញ្ជូន
- ចំណាយធានារ៉ាប់រង ដែលបានចាយនៅក្រៅប្រទេស
- ពន្ធគយ ឬអាករដែលមិនអាចស្នើសុំវិញបាន
- ចំណាយឆ្លងកាត់ កម្រៃជើងសា និងជើងសាជំនួញ ដែលត្រូវបង់ឱ្យសហគ្រាសនានា ដែលស្ថិតនៅបរទេស (គិតរួមបញ្ចូលទាំងកម្រៃជើងសាធនាគារ ចំណាយសំណុំរឿងនិងចំណាយនៃការទូទាត់)
- ចំណាយផ្សេងៗក្រោយការបញ្ចូលទ្រព្យសកម្មមកក្នុងប្រទេស មានជាអាទិ៍ ចំណាយឆ្លងកាត់ កម្រៃជើងសា និងជើងសាជំនួញ ដែលត្រូវបង់ឱ្យសហគ្រាសក្នុងស្រុក ចំណាយដឹកជញ្ជូន និងចំណាយធានារ៉ាប់រងពីព្រំដែនមកដល់ឃ្លាំង។

៣-កំណត់ត្រាពន្ធគយ៖ ពន្ធគយលើទំនិញនាំចេញ-នាំចូល ត្រូវកត់ត្រាក្នុងគណនីពន្ធគយ និងមិនត្រូវកត់ត្រានៅក្នុងគណនីទិញទំនិញទេ។

៤- កំណត់ត្រាអាករលើតម្លៃបន្ថែម ត្រូវអនុវត្តដូចខាងក្រោម៖

ក- ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់មិនជាប់អាករ ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងកថាខណ្ឌទី៥ នៃប្រការនេះ។

ខ- ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ៖

- ចំពោះអាករលើធាតុចូលដែលអាចសុំជាឥណទានបាន ត្រូវកត់ត្រាក្នុងគណនីត្រូវទទួល
- ចំពោះអាករលើធាតុចូលដែលមិនអាចសុំជាឥណទានបាន ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងកថាខណ្ឌទី៥ នៃប្រការនេះ
- ចំពោះអាករលើធាតុចូលដែលបានកត់ត្រាក្នុងគណនីត្រូវទទួលដូចមានចែងក្នុងអនុវាក្យខណ្ឌទី១ នៃវាក្យខណ្ឌនេះ ប៉ុន្តែក្រោយមកទៀតក្លាយជាឥណទានមិនអាចស្នើសុំបានដោយបទប្បញ្ញត្តិមិនអនុញ្ញាត សហគ្រាសត្រូវកត់ត្រាអាករលើធាតុចូលនេះ ក្នុងគណនីទ្រព្យសកម្មឬគណនីទិញដែលជាប់ទាក់ទិន។ ប៉ុន្តែ ប្រសិនបើអាករលើធាតុចូលនេះមិនអាចកត់បញ្ចូលទៅក្នុងគណនីទ្រព្យសកម្ម ឬគណនីទិញណាមួយបានទេ សហគ្រាសអាចកត់ត្រាអាករលើធាតុចូលនេះ ជាចំណាយក្នុងឆ្នាំជាប់ពន្ធដែលឥណទានមិនត្រូវបានអនុញ្ញាត។

៥- កំណត់ត្រាអាករផ្សេងៗ៖ មានជាអាទិ៍ អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ អាករទាំងនេះមិនត្រូវកាត់ចេញពីបរិយាទានទិញទេ។ ប្រសិនបើអាករទាំងនេះមានឆ្លុះបញ្ចាំងក្នុងវិក្កយបត្រនៃការទិញទ្រព្យសកម្ម ឬសេវា អាករទាំងនេះត្រូវបូកបន្ថែមលើថ្លៃទិញ និងត្រូវកត់ត្រាក្នុងគណនីចំណាយ ឬគណនីទ្រព្យសកម្មដែលទាក់ទិន។

៦-ការដកយកទំនិញឬសេវាមកប្រើប្រាស់សម្រាប់ប្រកបអាជីវកម្ម៖ ការដកយកទំនិញឬសេវាមកប្រើប្រាស់សម្រាប់ប្រកបអាជីវកម្មមិនត្រូវចាត់ទុកថាបានលក់ទេ ប៉ុន្តែត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់។

៧-កំណត់ត្រាការទិញ និងការធ្វើនិយ័តកម្មការទិញ ស្តុកនិងបំណុលអ្នកផ្គត់ផ្គង់៖ ដូចចំណាយផ្សេងទៀតដែរ ការទិញត្រូវកត់ត្រាបញ្ចូលក្នុងឆ្នាំជាប់ពន្ធដែលការទិញបានកើតឡើង។ ផ្អែកតាមគោលការណ៍នៃការកត់ត្រាការទិញនាថ្ងៃទទួលវិក្កយបត្រ នាំឱ្យមានចន្លោះពេលមួយនាថ្ងៃបញ្ចប់ឆ្នាំជាប់ពន្ធ គឺការកើតឡើងមុនក្រោយគ្នារវាងការទទួលវិក្កយបត្រ ការទទួលទំនិញ និងការកត់ត្រាគណនេយ្យ។ ក្នុងករណីនេះ ត្រូវធ្វើនិយ័តកម្មនាឱកាសធ្វើសារពើភណ្ឌតាមវិធីដូចខាងក្រោម៖

- ក- ប្រសិនបើវិក្កយបត្រមិនទាន់បានទទួល ប៉ុន្តែទំនិញបានប្រគល់ទទួលរួចហើយ បំណុលដែលមានទឹកប្រាក់ប៉ាន់ស្មានមួយត្រូវបានកត់ត្រាក្នុងគណនីត្រូវសង (អ្នកផ្គត់ផ្គង់-វិក្កយបត្រមិនទាន់មកដល់) ដោយកត់ត្រាខាងឥណពន្ធនៃគណនីការទិញ។
- ខ- ប្រសិនបើវិក្កយបត្រត្រូវបានកត់ត្រា ប៉ុន្តែទំនិញមិនទាន់បានទទួល ទំនិញនេះត្រូវកត់បញ្ចូលក្នុងសារពើភណ្ឌនៅដំណាច់ឆ្នាំជាប់ពន្ធ ដោយប្រើគណនីស្តុកកំពុងនៅតាមផ្លូវ។

**ប្រការ២៥** .- ចំណាយសេវាខាងក្រៅ

១- ការជួល មានជាអាទិ៍៖

- ក- ការជួលអចលនទ្រព្យឬចលនទ្រព្យសម្រាប់បម្រើអាជីវកម្ម៖ ក្នុងនេះអាចមានការបង់ប្រាក់ផ្សេងៗដូចខាងក្រោម៖
  - ប្រាក់ឈ្នួល និងចំណាយផ្សេងៗនៃការជួលអចលនទ្រព្យឬចលនទ្រព្យសម្រាប់បម្រើអាជីវកម្ម (រួមទាំងអ្វីដែលបានបង់ក្នុងក្របខ័ណ្ឌកិច្ចសន្យានៃភតិសន្យាហិរញ្ញវត្ថុ) អាចកាត់កងបាននៅក្នុងឆ្នាំជាប់ពន្ធដែលត្រូវសងនូវប្រាក់ឈ្នួលនិងចំណាយទាំងនេះ ទោះបីជាការបង់ប្រាក់ជាក់ស្តែងត្រូវបានធ្វើឡើងនៅថ្ងៃណាក៏ដោយ
  - ប្រាក់ឈ្នួលបង់មុន៖ ប្រាក់នេះត្រូវកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការទៅក្នុងគណនី ចំណាយបានកត់ត្រាមុន ដែលពុំមានផលប៉ះពាល់ដល់លទ្ធផលនៃឆ្នាំជាប់ពន្ធនៃការបង់ប្រាក់ឡើយ។ ទឹកប្រាក់នេះត្រូវបានកាត់ចេញតែពីលទ្ធផលនៃឆ្នាំជាប់ពន្ធដែលចំណាយជួលបានកើតឡើងប៉ុណ្ណោះ
  - ប្រាក់ធានា៖ ប្រាក់ដែលបានបង់ជាប្រាក់ធានា ត្រូវកត់ត្រានៅខាងទ្រព្យសកម្មនៃតារាងតុល្យការ។ ប្រាក់ធានាអាចមានឥទ្ធិពលតែលើលទ្ធផលនៃឆ្នាំជាប់ពន្ធដែលប្រាក់នេះ ត្រូវបានទទួលយ៉ាងពិតប្រាកដដោយម្ចាស់កម្មសិទ្ធិនៃទ្រព្យជួលតែប៉ុណ្ណោះ
  - សម្រាប់គោលដៅពន្ធដារ ប្រាក់ទឹកតែដែលសហគ្រាសបានបង់សម្រាប់ការជួលទ្រព្យ គឺជាចំណាយមិនអាចកាត់កងបាន។
- ខ- ការជួលកន្លែងស្នាក់នៅ៖ ប្រាក់ឈ្នួលកន្លែងស្នាក់នៅ អាចកាត់កងបានទៅតាមកម្មវត្ថុនៃការប្រើប្រាស់កន្លែងស្នាក់នៅ។ ចំពោះកន្លែងស្នាក់នៅដែលសម្រាប់បម្រើតម្រូវការរបស់និយោជិតសហគ្រាស ប្រាក់ឈ្នួលជាចំណាយដែលអាចកាត់កងបាន និងជាអត្ថប្រយោជន៍បន្ថែមដែលនិយោជិតទទួលបាន។ ចំពោះកន្លែងស្នាក់នៅសម្រាប់បម្រើតម្រូវការផ្សេងទៀត ប្រាក់ឈ្នួលគឺជាចំណាយមិនអាចកាត់កងបាន។

២-ការងារថែទាំនិងជួសជុល៖ ជាគោលការណ៍ ត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយចរន្តចំពោះតែការថែទាំជួសជុលណាមួយដែលអាចធ្វើឱ្យទ្រព្យសកម្មអាចដំណើរការឬប្រើប្រាស់បានជាប្រក្រតី ឬដំណើរការបានរហូតដល់ពេលបញ្ចប់នៃរយៈពេលរស់របស់វាប៉ុណ្ណោះ។ ដោយឡែក ចំពោះការកែលម្អណាមួយ ដែលជាការជួសជុលកែលម្អដើម្បីធ្វើឱ្យទ្រព្យសកម្មមានតម្លៃលើស ឬបង្កើនផលិតភាព ឬពន្យារអាយុកាលប្រើប្រាស់ឱ្យបានវែងជាងអាយុកាលដែលបានកំណត់ទុកពីដើមដំបូង ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មជាប់ទាក់ទិន។

៣- ចំណាយធានារ៉ាប់រង៖ ចំណាយដែលបានបង់លើកិច្ចសន្យាធានារ៉ាប់រងហានិភ័យចំពោះទ្រព្យសកម្ម (គ្រោះថ្នាក់ អគ្គិភ័យ ព្យុះ...) ឬកិច្ចសន្យាធានារ៉ាប់រងបន្ទុកជាយថាហេតុ (ការទទួលខុសត្រូវខាងពាណិជ្ជកម្ម ឬវិជ្ជាជីវៈ) ត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធដែលចំណាយនេះបានកើតឡើង (គឺត្រូវគណនាតាមចំនួនថ្ងៃដែលកិច្ចសន្យាធានារ៉ាប់រងត្រូវគ្របដណ្តប់នៅក្នុងឆ្នាំជាប់ពន្ធ)។

៤- កម្រៃជើងសា និងលាភការខាងក្រៅ៖

ក- កម្រៃជើងសា និងលាភការផ្សេងៗបានបង់៖ ចំនួនប្រាក់បង់ថ្លៃសេវាដែលបានផ្តល់ឱ្យដល់សហគ្រាស ត្រូវបានអនុញ្ញាតឱ្យកាត់កងតែក្នុងករណីដែលភាពពិតនិងប្រយោជន៍របស់សេវាទាំងនេះត្រូវបានបង្ហាញ ហើយចំនួនទឹកប្រាក់មិនត្រូវបានបំផ្លើស។

ខ- សួយសារចំពោះសម្បទាន ប្រកាសនីយបត្រតក្កកម្ម ម៉ាកឬពាណិជ្ជនាម សិទ្ធិអាជីវកម្ម សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល៖ សួយសារប្រភេទនេះអាចកាត់កងបាន ក្នុងករណីដែលមិនមែនជាចំណាយលើការទិញទ្រព្យសកម្មណាមួយ ហើយចំនួនទឹកប្រាក់មិនត្រូវបានបំផ្លើស។

៥- បេសកកម្ម៖ ចំណាយបេសកកម្មអាចអនុញ្ញាតឱ្យកាត់កងបាន ប្រសិនបើបេសកកម្មនេះបម្រើអាជីវកម្មយ៉ាងពិតប្រាកដ ហើយចំនួនទឹកប្រាក់ក៏មិនច្រើនហួសហេតុធៀបទៅនឹងប្រភេទនិងទំហំរបស់អាជីវកម្ម ឬធៀបទៅនឹងប្រាក់ចំណូលសុទ្ធដែលសម្រេចបាន។ ចំពោះចំណាយចម្រុះ (មានជាអាទិ៍ ចំណាយធ្វើដំណើរនិងបេសកកម្មដែលមានលក្ខណៈបម្រើអាជីវកម្មផង និងធ្វើទេសចរណ៍កម្សាន្តផង) ត្រូវបានអនុញ្ញាតឱ្យកាត់កងតែចំពោះចំណែកណាដែលបម្រើអាជីវកម្មតែប៉ុណ្ណោះ។ ចំណាយធ្វើដំណើរនិងបេសកកម្មទៅបរទេស ឬការទៅចូលរួមឬការរៀបចំសន្និសីទ សិក្ខាសាលា ប្រជុំ... អាចអនុញ្ញាតឱ្យកាត់កងបាន ប្រសិនបើប្រយោជន៍សម្រាប់សហគ្រាសនៃការចំណាយទាំងនេះត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ និងមានការជាប់ទាក់ទិនដោយផ្ទាល់ទៅនឹងអាជីវកម្មរបស់សហគ្រាស។

៦- ការទទួលភ្ញៀវ ការកម្សាន្ត ឬការសម្រាកលំហែ៖ មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេនូវចំណាយលើសកម្មភាពទទួលភ្ញៀវ កម្សាន្ត ឬសម្រាកលំហែ មានជាអាទិ៍ ការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់នៅ ឬបដិសណ្ឋារកិច្ចណាមួយ។

**ប្រការ២៦** ._ ពន្ធអាករ

១- ពន្ធអាករដែលបានបង់ក្នុងឆ្នាំជាប់ពន្ធ៖

ក- ពន្ធអាករណាមួយដែលត្រូវបានបង់តាមវិធីដាក់លិខិតប្រកាសសារពើពន្ធ និងជាប្រភេទពន្ធអាករដែលអាចកាត់កងបាន ត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធដែលពន្ធអាករទាំងនេះត្រូវបានបង់ ឬត្រូវបង់។

ខ- ចំពោះពន្ធអាករដែលបានបង់ដោយមិនដាក់លិខិតប្រកាសសារពើពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធដែលពន្ធអាករទាំងនេះបំពេញបាននូវលក្ខខណ្ឌនានានៃចំណាយអាចកាត់កងបាន។

២- ពន្ធអាករអាចកាត់កងបាន៖ សហគ្រាសអាចកាត់កងបាននូវពន្ធអាករទាំងឡាយដែលសហគ្រាសបានបង់រួមមាន ពន្ធប៉ាតង់ ពន្ធអាករដែលពាក់ព័ន្ធនឹងការនាំចូលឬនាំចេញ អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ អាករលើជាតុចូលដែលមិនអនុញ្ញាតជាឥណទាន ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធលើមធ្យោបាយដឹកជញ្ជូន។

៣- ពន្ធអាករដែលមិនអាចកាត់កងបាន៖ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា និងពន្ធអាករនានាដែលមិនមែនជាបន្ទុករបស់សហគ្រាស (ពន្ធកាត់ទុកទូទៅ ពន្ធលើប្រាក់បៀវត្ស)។

**ប្រការ២៧** ._ សំវិធានធន

១- ការកាត់កងចំណាយណាមួយស្របតាមមាត្រា៦ នៃច្បាប់ស្តីពីសារពើពន្ធ អាចធ្វើទៅបានលុះណាតែហេតុការណ៍បញ្ជាក់បន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។ ដូច្នេះ ក្រៅតែពីធនាគារក្នុងស្រុក សំវិធានធនដែលធ្វើឡើងដោយសហគ្រាសផ្សេងទៀត សម្រាប់រ៉ាប់រងបន្ទុកចំណាយ ឬការខាតបង់នានាដែលមិនទាន់កើត

មានឡើងជាក់ស្តែង មិនត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយឡើយ ទោះបីលទ្ធភាពនៃការកើតមានបន្ទុកចំណាយ ឬការខាតបង់ទាំងនេះមានកម្រិតខ្ពស់ ឬជាក់លាក់យ៉ាងណាក៏ដោយ។

២-ចំពោះធនាគារក្នុងស្រុក សំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យត្រូវបានកំណត់ដូចក្នុងតារាងខាងក្រោម៖

| ល.រ | ចំណាត់ថ្នាក់ហានិភ័យឥណទាន | សំវិធានធនដែលបានអនុញ្ញាត |
|---|---|---|
| ១ | ធម្មតា | 0% |
| ២ | ឃ្លាំមើល | 0% |
| ៣ | ក្រោមស្តង់ដា | អនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ |
| ៤ | សង្ស័យ | អនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ |
| ៥ | បាត់បង់ | អនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ |

៣-សំវិធានធនដែលបានអនុញ្ញាតក្នុងប្រការនេះ មិនអនុវត្តចំពោះប្រតិបត្តិការកតិសន្យាហិរញ្ញវត្ថុទេ។

៤-ធនាគារក្នុងស្រុក ត្រូវបញ្ចូលមកជាប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធវិញនូវចំនួនទឹកប្រាក់ឥណទានដែលបានអនុញ្ញាតឱ្យកាត់កងជាសំវិធានធនចំពោះឥណទេយ្យជាប់សង្ស័យរួមទាំងការប្រាក់និងចំណាយផ្សេងៗ នៅពេលដែលបានទទួលការបង់សងមកវិញនូវឥណទេយ្យដែលជាប់សង្ស័យទាំងនោះ។

**ប្រការ២៨ ._** បៀវត្ស និងចំណាយប្រហាក់ប្រហែល

១-លក្ខខណ្ឌនៃការកាត់កង៖ ប្រាក់បៀវត្សនិងអត្ថប្រយោជន៍បន្ថែមអាចអនុញ្ញាតឱ្យកាត់កងបានក្នុងករណីដែលទឹកប្រាក់ទាំងនេះមានលក្ខណៈសមស្របនិងជាប់ទាក់ទិននឹងការងារពិតប្រាកដរបស់និយោជិត។

២-ចំណាយដែលត្រូវកត់ត្រាក្នុងឆ្នាំជាប់ពន្ធ៖ ប្រាក់បៀវត្សនិងអត្ថប្រយោជន៍បន្ថែម គឺជាចំណាយប្រចាំឆ្នាំសម្រាប់អាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យកាត់កងតែក្នុងឆ្នាំជាប់ពន្ធ ដែលទទួលរងដោយពិតប្រាកដនូវចំណាយនេះតែប៉ុណ្ណោះ។ ដោយឡែក នៅដំណាច់ឆ្នាំជាប់ពន្ធ អាចមានប្រាក់បៀវត្សខ្លះត្រូវបានបើកមុន ឬមិនទាន់បានបើកឱ្យនិយោជិត ដែលបានកត់ត្រាក្នុងគណនីចំណាយកត់ត្រាមុន ឬគណនីត្រូវសង។

៣-លាភការផ្សេងៗ ជាទឹកប្រាក់ដែលទទួលបានពីការបំពេញការងារក្នុងរយៈពេលកំណត់ណាមួយ មានជាអាទិ៍៖

ក- លាភការនៃបុគ្គលិកទទួលបៀវត្សដែលមិនមែនជាអ្នកគ្រប់គ្រងដែលមានចែងលម្អិតនៅក្នុងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស។

ខ- លាភការនៃសមាជិកសហគ្រាសសហកម្មសិទ្ធិនិងម្ចាស់សហគ្រាសឯកបុគ្គល៖ ដោយសារសមាជិកសហគ្រាសសហកម្មសិទ្ធិ ឬម្ចាស់សហគ្រាសឯកបុគ្គល មានសកម្មភាពបំពេញការងារនៅក្នុងសហគ្រាស និងដោយហេតុថាប្រាក់ចំណូលរបស់សហគ្រាសជាកម្មសិទ្ធិទាំងស្រុងរបស់សមាជិកឬម្ចាស់សហគ្រាស ដូច្នេះចំណាយលើលាភការដល់សមាជិកឬម្ចាស់សហគ្រាស មិនត្រូវបានអនុញ្ញាតឱ្យកាត់កង ហើយក៏មិនចាត់ទុកជាការបែងចែកភាគលាភទេ។ ប៉ុន្តែក្នុងករណីដែលរដ្ឋបាលសារពើពន្ធមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាការដកយកជាមុននូវទឹកប្រាក់ណាមួយចេញពីប្រាក់ចំណូលអាចធ្វើឱ្យមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចតម្រូវឱ្យអ្នកជាប់ពន្ធបង់ពន្ធភ្លាម។

គ- លាភការផ្តល់ឱ្យសមាជិកផ្សេងទៀតនៃក្រុមគ្រួសាររបស់ម្ចាស់សហគ្រាសឯកបុគ្គល៖ លាភការដែលផ្តល់ឱ្យកូន កូនប្រសារ និងញាតិពន្ធនានារបស់ម្ចាស់សហគ្រាស គឺអាចកាត់កងបានដរាបណាវាជាថ្នូរនៃការងារពិតប្រាកដ មានចំនួនទឹកប្រាក់មិនបំផ្លើស និងពិតជាបានទូទាត់ឱ្យជាក់ស្តែងមែន។



k

ឃ-លាភការរបស់អ្នកគ្រប់គ្រងសហគ្រាសនីតិបុគ្គលៈ ដោយហេតុថាអ្នកគ្រប់គ្រងទាំងនេះមានសិទ្ធិត្រួតពិនិត្យ និងសិទ្ធិសម្រេច លាភការដែលពួកគេបានទទួលអាចមានលក្ខណៈបំផ្លើស។ លក្ខណវិនិច្ឆ័យដូចតទៅ អាចប្រើប្រាស់បានសម្រាប់បញ្ជាក់បង្ហាញ និងកំណត់ចំនួននៃការបំផ្លើសនេះ (ភាគនៃលាភការដែលត្រូវបានចាត់ទុកថាជាការបំផ្លើស គឺជាចំណាយមិនអាចកាត់កងបាន)៖

- សារប្រយោជន៍នៃសកម្មភាពដែលបានបំពេញដោយអ្នកគ្រប់គ្រង និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ឱ្យអ្នកគ្រប់គ្រងនោះ
- ការវិវត្តនៃប្រាក់ចំណូលរបស់សហគ្រាស
- ទំហំសហគ្រាស
- ការប្រៀបធៀបលាភការនេះជាមួយនឹងលាភការដែលបានផ្តល់ឱ្យអ្នកគ្រប់គ្រងសហគ្រាសដែលមានការងារស្រដៀងគ្នានៅក្នុងសហគ្រាសមានអាជីវកម្មប្រហាក់ប្រហែលគ្នានៅក្នុងតំបន់ ឬជាមួយនឹងលាភការដែលបានផ្តល់ឱ្យនិយោជិតដែលមានឋានៈនិងតួនាទីនៅក្នុងសហគ្រាស
- ការប្រៀបធៀបរវាងលាភការសរុបដែលបានផ្តល់ឱ្យទៅអ្នកគ្រប់គ្រង និងបៀវត្សដែលបានផ្តល់ឱ្យបុគ្គលិកទាំងអស់ដែលត្រូវទទួលបៀវត្ស។

៤- ត្រូវបានចាត់ទុកថាបានចាយក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើមានការកត់ត្រាខាងឥណពន្ធនៃគណនីចំណាយ និងកត់ត្រាខាងឥណទាននៃគណនីសមាគត (អ្នកចូលហ៊ុន) ឬគណនីបុគ្គលទាក់ទិន។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ឥណទាននិងឥណទានបានកត់ត្រា សំដៅដល់ ហេតុការណ៍ដែលសហគ្រាសបានកត់ត្រាជាមុននូវបំណុលសម្រាប់ទូទាត់ឱ្យម្ចាស់បំណុលអនិវាសនជន ដែលក្នុងនោះមាន៖

ក- ការទូទាត់ប្រាក់ទៅឱ្យអ្នកឱ្យជួលឬភ្នាក់ងារតាមរយៈគណនីធនាគារក្នុងនាមម្ចាស់សហគ្រាសជាអនិវាសនជន។

ខ- ការទូទាត់ការប្រាក់ទៅក្នុងគណនីសន្សំរបស់អ្នកជាប់ពន្ធអនិវាសនជន។

គ- ការតម្កល់ប្រាក់សោធននិវត្តន៍ឬប្រាក់បំណាច់ប្រចាំឆ្នាំរបស់ក្រុមហ៊ុនធានារ៉ាប់រងឬក្រុមហ៊ុនបរធនបាលទៅក្នុងគណនីធនាគាររបស់អ្នកជាប់ពន្ធអនិវាសនជន។

ឃ-ការកាត់កងទឹកប្រាក់ដែលត្រូវទូទាត់ដោយអ្នកជាប់ពន្ធនិវាសនជន (ឬអ្នកដែលត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធនិវាសនជន) នូវទឹកប្រាក់ដែលអ្នកជាប់ពន្ធអនិវាសនជនជំពាក់។

ង- ចំនួនទឹកប្រាក់ដែលបានកត់ត្រាជាឥណទានទៅក្នុងគណនីសមាគត។

៥- ចំណាយខាងសង្គមកិច្ចទាំងឡាយណាដែលបានបញ្ញត្តនៅក្នុងច្បាប់ស្តីពីការងារ គឺអាចកាត់កងបាន។

**ប្រការ២៩**._ ការប្រាក់

ការប្រាក់ សំដៅដល់ ទឹកប្រាក់ដែលជាកាតព្វកិច្ចបំណុលដែលកូនបំណុលត្រូវបង់ឱ្យម្ចាស់បំណុល រួមបញ្ចូលទាំងប្រាក់ចុះថ្លៃ បុព្វលាភ ឬការទូទាត់ប្រហាក់ប្រហែលទាក់ទិននឹងការខ្ចីប្រាក់ លើកលែងតែការបង្វិលសងប្រាក់ដើម។ ការប្រាក់អាចជាតម្លៃនៃការយល់ព្រមមិនតាមទារឥណទានដែលបានផ្តល់ឱ្យជាទំនិញឬសេវាដែលកូនបំណុលត្រូវសងម្ចាស់បំណុល។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ កាតព្វកិច្ចបំណុល សំដៅដល់ កាតព្វកិច្ចទូទាត់សងជាសាច់ប្រាក់ឬជាវត្ថុទៅឱ្យបុគ្គលម្នាក់ទៀត រួមបញ្ចូលទាំងកាតព្វកិច្ចរបស់ធនាគារ ចំពោះប្រាក់បញ្ញើ កាតព្វកិច្ចចំពោះសមតុល្យក្នុងគណនីត្រូវសង រូបិយាណត្តិ និងសញ្ញាបណ្ណ។ ការប្រាក់ មានជាអាទិ៍៖

១- ការប្រាក់នៃប្រាក់ខ្ចីពីតតិយជន៖

ក- ការប្រាក់នៃប្រាក់ដែលសហគ្រាសខ្ចីពីតតិយជនសម្រាប់បម្រើតម្រូវការក្នុងអាជីវកម្ម ត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធដែលការប្រាក់ក្លាយជាបំណុលត្រូវសង។ ក្នុងនេះសហគ្រាសត្រូវបង្ហាញឱ្យឃើញនូវភាពពិតនៃប្រាក់ខ្ចីដោយត្រូវមានភស្តុតាងអាចត្រួតពិនិត្យបាន ដូចជា កិច្ចសន្យាខ្ចីប្រាក់ដែលមានកាលបរិច្ឆេទជាក់លាក់ និងដែលមានកំណត់ច្បាស់លាស់នូវបែបបទនៃការសងប្រាក់ដើមនិងការប្រាក់។



4

ខ- ការប្រាក់នៃប្រាក់ខ្ចីពីតតិយជនសម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។ ចំពោះសហគ្រាសឯកបុគ្គល ស្ថានភាពនេះកើតមានឡើងកាលបើគណនីម្ចាស់សហគ្រាសមានសមតុល្យឥណពន្ធ (សមតុល្យចុងគ្រានៃគណនីម្ចាស់សហគ្រាសនៃឆ្នាំជាប់ពន្ធណាមួយ គឺត្រូវស្មើនឹងសមតុល្យដើមគ្រានៃឆ្នាំជាប់ពន្ធនោះ ដកចេញនូវការបន្ថែមដើមទុននិងចំណេញក្នុងឆ្នាំជាប់ពន្ធ ហើយបូកបញ្ចូលនូវការខាតនៅក្នុងឆ្នាំជាប់ពន្ធនិងការដកយកទៅប្រើប្រាស់មុនរបស់ម្ចាស់សហគ្រាស)។ ក្នុងស្ថានភាពនេះសហគ្រាសអាចត្រូវធ្វើការខ្ចីបុល ដើម្បីទប់ទល់នឹងកង្វះខាតសាច់ប្រាក់ដែលបណ្តាលមកពីការដកយកមកប្រើប្រាស់ជាមុនរបស់ម្ចាស់សហគ្រាសនូវទឹកប្រាក់លើសពីចំនួន ដែលសហគ្រាសចំណេញ ឬសហគ្រាសមានការខាតបង់ក្នុងឆ្នាំជាប់ពន្ធ។ក្នុងករណីនេះ ការប្រាក់អាចកាត់កងបាន គឺកម្រិតត្រឹមតែការប្រាក់ដែលទាក់ទិននឹងចំណែកនៃការខ្ចីដែលលើសពីតួលេខសមតុល្យឥណពន្ធខ្ពស់បំផុតក្នុងឆ្នាំជាប់ពន្ធ នៃគណនីម្ចាស់សហគ្រាសតែប៉ុណ្ណោះ។

២- ទឹកប្រាក់នានាដែលបានទូទាត់ឱ្យសម្រាប់ជាលាភការនៃដើមទុនផ្ទាល់របស់សហគ្រាស ឬការប្រាក់សងឱ្យគណនីម្ចាស់សហគ្រាសឯកបុគ្គល មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

៣- កំហិតលើការកាត់កងការប្រាក់៖ កំហិតលើការកាត់កងការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ គឺជាចំនួនទឹកប្រាក់ការប្រាក់អតិបរមាដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និងត្រូវគណនាតាមរូបមន្ត ក + ខ ដែល៖

ក = ចំណូលការប្រាក់ដែលបានទទួល ឬត្រូវបានទទួលនៅក្នុងឆ្នាំជាប់ពន្ធ។

ខ = ៥០ (ហាសិប) ភាគរយ នៃប្រាក់ចំណូលសុទ្ធដោយមិនគិតពីចំណូលការប្រាក់និងចំណាយការប្រាក់។

ការប្រាក់អនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនានៅដំណាច់ឆ្នាំជាប់ពន្ធនោះ។ ចំណាយការប្រាក់ដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធចរន្ត អាចយោងជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតនៅក្នុងកំហិតដូចគ្នារហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយគិតតាមលំដាប់ឆ្នាំដែលការប្រាក់បានកើតឡើង។

**ប្រការ៣០ .-** ចំណាយពិសេស

១- ទណ្ឌកម្មនានា រួមមាន ពន្ធបន្ថែម ការប្រាក់ ការផាកពិន័យជាប្រាក់ និងប្រាក់ពិន័យផ្សេងៗ ដែលសហគ្រាសបានទទួលរងដោយសារការមិនអនុវត្តត្រឹមត្រូវតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។ ទណ្ឌកម្មទាំងនោះ មានជាអាទិ៍៖

ក- ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ ពីការមិនបំពេញកាតព្វកិច្ចសារពើពន្ធ។

ខ- ប្រាក់ពិន័យខាងគយ។

គ- ប្រាក់ពិន័យពីការល្មើសបទប្បញ្ញត្តិច្បាប់ស្តីពីថ្លៃ ឬបទប្បញ្ញត្តិខាងសេដ្ឋកិច្ច។

ឃ- ប្រាក់ពិន័យអនុវត្តលើបទល្មើសផ្ទាល់ខ្លួនរបស់បុគ្គល។

ង- ប្រាក់ពិន័យដែលជាការដាក់ទោសចំពោះការល្មើសនឹងបទប្បញ្ញត្តិសាធារណៈឬបទល្មើសព្រហ្មទណ្ឌ។

២- អំណោយ៖ អំណោយដែលសហគ្រាសបានធ្វើឡើងជាចំណាយមិនអាចកាត់កងបាន។

៣- ឧបត្ថម្ភធនផ្សេងៗ៖ ឧបត្ថម្ភធន សំដៅដល់ ប្រាក់ប៉ះប៉ូវសម្រាប់បំពេញថ្លៃសម្រាលបន្ទុកអាជីវកម្មជានាលំនឹងអាជីវកម្មដែលសហគ្រាសបានធ្វើទោះបីក្នុងគោលដៅបែបណាក៏ដោយមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

៤- ខាតលើឥណទេយ្យ៖ គឺជាការទទួលស្គាល់ជាចំណាយរបស់សហគ្រាសចំពោះបំណុលមិនអាចទារបាន។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ចំណាយនេះអាចអនុញ្ញាតឱ្យកាត់កងបានតែក្នុងករណីដែលភាពមិនអាចទារបាននៃបំណុលនេះត្រូវបានបញ្ជាក់បង្ហាញដោយជាក់ស្តែង (ការព្យាយាមបង្ហាញឯកសារប្រមូលបំណុល ឬមានភស្តុតាងច្បាស់លាស់នៃការខិតខំព្យាយាមក្នុងការប្រមូល ឬទទួលបានទឹកប្រាក់ដែលជំពាក់ដោយអសារធនភាពជាស្ថាពររបស់កូនបំណុល) ហើយបំណុលនោះត្រូវបានលុបចេញពីបញ្ជីគណនេយ្យរបស់សហគ្រាស។ ជាទូទៅ ការបោះបង់ចោលនូវបំណុលជាទង្វើមិនប្រក្រតីនៃការគ្រប់គ្រងដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។



4

៥- ចំណាយពិសេសផ្សេងៗ៖ ការបាត់បង់ផ្សេងៗនិងចំណាយដទៃទៀតតាមធម្មតា គឺអាចកាត់កងបានតែក្នុងករណីដែលការបាត់បង់ និងចំណាយទាំងនេះ កើតមានឡើងក្នុងក្របខ័ណ្ឌនៃដំណើរការអាជីវកម្មធម្មតារបស់សហគ្រាស។ម្យ៉ាងវិញទៀត ត្រូវជានាថាការបាត់បង់និងចំណាយទាំងនេះ មិនត្រូវបានកាត់កងរួចហើយតាមរបៀបណាមួយផ្សេងទៀតនោះទេ។ ឧទាហរណ៍៖ ការបាត់បង់ទំនិញដោយសារចោរកម្មឬគ្រោះមហន្តរាយ ពុំត្រូវមានការកាត់កងអ្វីដោយឡែកនោះទេ ពីព្រោះការបាត់បង់នេះត្រូវបានគិតបញ្ចូលមកកាត់កងជាស្វ័យប្រវត្តិតាមយន្តការនៃការធ្វើគណនេយ្យកម្ម ការទិញការលក់ និងស្តុក។ ដោយឡែកចំពោះការបាត់បង់និងចំណាយណាមួយដែលទាក់ទិននឹងទង្វើមិនធម្មតានៃការគ្រប់គ្រងគឺមិនអាចកាត់កងបានទេ។

**ប្រការ៣១** ._ វិភាគទានសប្បុរសធម៌

១-សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល វិភាគទានសប្បុរសធម៌ សំដៅដល់ វិភាគទានជាសាច់ប្រាក់ឬជាវត្ថុឱ្យដល់សកម្មភាពមិនស្វែងរកចំណេញដូចខាងក្រោម៖

ក- អង្គការណាមួយ ដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនាសប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

ខ- សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់សមាគមទាំងនោះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល។

២-កម្រិតនៃការអនុញ្ញាតឱ្យកាត់កងវិភាគទានសប្បុរសធម៌ ត្រូវអនុវត្តដូចខាងក្រោម៖

ក- ចំនួនទឹកប្រាក់វិភាគទានសប្បុរសធម៌ដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធណាមួយ មិនត្រូវឱ្យលើសពី ៥ (ប្រាំ) ភាគរយ នៃប្រាក់ចំណូលសុទ្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌។

ខ- ចំពោះទឹកប្រាក់វិភាគទានសប្បុរសធម៌ដែលនៅសល់ពីការកាត់កងដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី២ នេះ មិនត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងនៅឆ្នាំជាប់ពន្ធណាមួយផ្សេងទៀតបានទេ គឺត្រូវក្លាយជាចំណាយមិនអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធដែលទឹកប្រាក់នេះបានកើតឡើង។

## ផ្នែកទី៦
## វិធានទូទៅស្តីពីរំលស់

**ប្រការ៣២** ._ រំលស់ និងលក្ខខណ្ឌរំលស់

រំលស់ និងលក្ខខណ្ឌរំលស់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- លទ្ធកម្ម (ការទិញ ការទទួលបាន ការបញ្ចូល...) នៃទ្រព្យសកម្មរយៈពេលវែងពុំបណ្តាលឱ្យមានការថយចុះនៃទ្រព្យសកម្មសុទ្ធទេ ពីព្រោះការចំណាយត្រូវបានជាថ្នូរបញ្ចូលមកវិញនៅក្នុងទ្រព្យសកម្មរបស់សហគ្រាសនូវទ្រព្យសកម្មថ្មីមួយដែលពុំមានឥទ្ធិពលដល់លទ្ធផលជាប់ពន្ធឡើយ។ ទ្រព្យសកម្មរយៈពេលវែងតែងតែត្រូវសឹករេចដោយការប្រើប្រាស់និងដោយអាយុកាលឬភាពហួសសម័យ ហើយការសឹករេចនេះគឺជាចំណាយពិតប្រាកដមួយដែលត្រូវអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធរបស់សហគ្រាសតាមរយៈការធ្វើរំលស់។

២-រំលស់ គឺជាការកត់ត្រាអំពីការសឹករេចនៃទ្រព្យសកម្មដែលបណ្តាលមកពីការប្រើប្រាស់ ពេលវេលាប្រើប្រាស់ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬពីមូលហេតុផ្សេងទៀត ដោយធ្វើការបែងចែកបរិយាទាននៃទ្រព្យសកម្មទៅតាមរយៈពេលគ្រោងទុកនៃការប្រើប្រាស់ (អាយុកាលប្រើប្រាស់) ដែលផ្អែកតាមផែនការរំលស់មួយ។ រាល់ការកែប្រែធំដុំក្នុងលក្ខខណ្ឌនៃការប្រើប្រាស់ទ្រព្យសកម្មតម្រូវឱ្យមានការសើរើផែនការរំលស់ដែលកំពុងអនុវត្ត។

៣- សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល រំលស់ដែលអាចកាត់កងបាន ត្រូវបំពេញលក្ខខណ្ឌប្រាំដូចខាងក្រោម៖

ក- រំលស់ត្រូវធ្វើតែលើទ្រព្យសកម្មរយៈពេលវែងដែលបានកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់សហគ្រាស។

ខ- រំលស់ត្រូវធ្វើតែលើទ្រព្យសកម្មរយៈពេលវែងដែលទទួលរងការសឹករេច។

គ- រំលស់ត្រូវធ្វើលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម។



ꟷ

ឃ-រំលស់ត្រូវគណនាតាមវិធីដូចមានចែងក្នុងប្រការ៣៣ ដល់ប្រការ៣៧ នៃប្រកាសនេះ។

ង- រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស។

ដោយឡែក ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ។

៤- ក្នុងការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់កងរំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យសកម្មរូបី ឬអ្នកជួលទ្រព្យសកម្មរូបីក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ឬការខូចខាតនៃទ្រព្យ។ ជាធម្មតា ចំពោះភតិសន្យាហិរញ្ញវត្ថុ ភតិកៈជាអ្នកទទួលរងនូវហានិភ័យខាងលើ។

**ប្រការ៣៣** .- ទ្រព្យសកម្មរយៈពេលវែងដែលអនុញ្ញាតឱ្យធ្វើរំលស់

១- សហគ្រាសត្រូវធ្វើរំលស់តែលើទ្រព្យសកម្មរយៈពេលវែងដែលកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់ខ្លួន។ ទ្រព្យសកម្មរយៈពេលវែង គឺជាចំណែក (ឬសមាសភាគ) នៃទ្រព្យសកម្ម សម្រាប់ប្រើប្រាស់យូរអង្វែងនៅក្នុងសកម្មភាពអាជីវកម្មនិងរក្សាបាននូវរូបរាងដើមដដែលចាប់ពីពេលដាក់ប្រើប្រាស់រហូតដល់ពេលឈប់ប្រើការ។ អាចចាត់ទុកទ្រព្យសកម្មណាមួយជាទ្រព្យសកម្មរយៈពេលវែង ប្រសិនបើទ្រព្យសកម្មនោះមានលក្ខណៈស្របតាមលក្ខណវិនិច្ឆ័យទាំងពីរដូចខាងក្រោម៖

ក- គោលដៅ៖ ទ្រព្យសកម្មគ្រប់ប្រភេទ (ទ្រព្យសកម្មអរូបី ឬទ្រព្យសកម្មរូបី) ដែលសហគ្រាសបានទិញឬបានផលិត មិនមែនសម្រាប់បំប្លែងភាពដើម្បីលក់ឬមិនមែនសម្រាប់លក់ ប៉ុន្តែសម្រាប់ប្រើប្រាស់យូរអង្វែង (រថយន្តដែលសហគ្រាសលក់រថយន្តទិញមកសម្រាប់លក់ទៅវិញ គឺជាចំណែកមួយនៃការទិញនិងស្តុករីឯរថយន្តសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាស គឺជាទ្រព្យសកម្មរយៈពេលវែង)។ ទ្រព្យសកម្មទាំងនេះអាចលក់ទៅវិញបានតែក្នុងករណីនៅក្រោយពេលបានប្រើប្រាស់រួចហើយ។

ខ- រយៈពេល៖ ការរក្សាទុកទ្រព្យសកម្មនៅក្នុងអង្គភាពអាជីវកម្មត្រូវបានកំណត់ថាជាប់លាប់ ប្រសិនបើមានរយៈពេលលើសពី ១ឆ្នាំ ដោយគិតចាប់តាំងពីពេលដាក់ប្រើប្រាស់ដំបូង។

២-ភាពខុសគ្នារវាងទ្រព្យសកម្មរយៈពេលវែងនិងចំណាយ៖ ចំណាយដែលមានថ្នូរជាការបញ្ចូលនូវចំណែកថ្មីមួយទៅក្នុងទ្រព្យសកម្មនៃសហគ្រាស គឺជាទ្រព្យសកម្មរយៈពេលវែង។ ចំពោះចំណាយទាក់ទិននឹងទ្រព្យសកម្មដែលបានកត់ត្រារួចហើយនៅក្នុងតារាងតុល្យការ សហគ្រាសត្រូវអនុវត្តតាមកថាខណ្ឌទី២ នៃប្រការ២៥ នៃប្រកាសនេះ។

៣-ទ្រព្យសកម្មរយៈពេលវែងត្រូវបានបែងចែកដូចខាងក្រោម៖

ក- ទ្រព្យសកម្មអរូបី៖

ទ្រព្យកម្មអរូបីដែលអាចរំលស់បាន មានជាអាទិ៍៖

- ចំណាយបង្កើតសហគ្រាស
- ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍៖ គឺជាចំណាយនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលសហគ្រាសបានធ្វើឡើងសម្រាប់បម្រើការងារអាជីវកម្ម។ ដូចគ្នានឹងចំណាយបង្កើតសហគ្រាសដែរ ចំណាយនេះគឺជាចំណាយគ្មានថ្នូរមកវិញនៅក្នុងទ្រព្យសកម្មរបស់សហគ្រាសទេ។ គណនីទាំងឡាយដែលសម្រាប់កត់ត្រានូវចំណាយទាំងនេះ គឺជាគណនីទ្រព្យសកម្មដែលគ្មានតម្លៃពិតប្រាកដ។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ចំណាយនេះអាចកាត់ចេញទាំងស្រុងបានពីលទ្ធផលនៃការិយបរិច្ឆេទដែលចំណាយបានកើតឡើង។ ក្នុងករណីកត់ត្រាជាទ្រព្យសកម្មរយៈពេលវែងនូវគម្រោងការស្រាវជ្រាវនិងអភិវឌ្ឍន៍ណាមួយ គម្រោងការនោះត្រូវអាចសម្គាល់និងញែកដាច់តែឯងបាន និងត្រូវមានរំពឹងយ៉ាងមុតមាំក្នុងការទទួលផលខាងពាណិជ្ជកម្ម
- ប្រកាសនីយបត្រតក្កកម្ម ម៉ាកឬពាណិជ្ជនាម សិទ្ធិអាជីវកម្ម សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលសម្បទាន កម្មវិធីកុំព្យូទ័រ (ចំណែកដែលមានច្បាប់ការពារ)
- មូលនិធិពាណិជ្ជកម្ម
- ទ្រព្យសកម្មរយៈពេលវែងអរូបីផ្សេងទៀត។

ទ្រព្យសកម្មអរូបីដែលមិនអាចរំលស់បាន មានជាអាទិ៍៖ មូលបត្រ ភាគកម្ម ទ្រព្យសកម្មរយៈពេលវែងហិរញ្ញវត្ថុផ្សេងៗ និងសិទ្ធិប្រើប្រាស់ដីធ្លី...។



ᥰ

ខ- ទ្រព្យសកម្មរូបី៖ ទ្រព្យសកម្មរូបីត្រូវបានបែងចែកជាបួនថ្នាក់ដូចខាងក្រោម៖

- ទ្រព្យថ្នាក់១៖ រួមមាន សំណង់នានា រួមបញ្ចូលទាំងអគារ និងរចនាសម្ព័ន្ធរបស់អគារ សំណង់ដែលជាសមាសភាគរបស់អគារ ផ្លូវថ្នល់ ផ្លូវដែក និងនាវាដឹកជញ្ជូន
- ទ្រព្យថ្នាក់២៖ រួមមាន កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឧបករណ៍អេឡិចត្រូនិក និងបរិក្ខារទុកដាក់ទិន្នន័យ
- ទ្រព្យថ្នាក់៣៖ រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារិម និងបរិក្ខារការិយាល័យ
- ទ្រព្យថ្នាក់៤៖ រួមមាន រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗទៀត ក្រៅពីទ្រព្យក្នុងថ្នាក់១ ថ្នាក់២ និងថ្នាក់៣។

ក្នុងករណីទ្រព្យសកម្មរូបីណាមួយដែលមានលក្ខណៈពិសេស អគ្គនាយកដ្ឋានពន្ធដារអាចកំណត់វិធីរំលស់ដោយឡែកបាន។

**ប្រការ៣៤.**_ វិធីកត់ត្រាទ្រព្យសកម្មរយៈពេលវែង

១- ចំពោះទ្រព្យសកម្មអរូបី និងទ្រព្យសកម្មនៅក្នុងថ្នាក់១៖ សហគ្រាសត្រូវកត់ត្រាដោយឡែកតាមគណនីទ្រព្យសកម្មនីមួយៗ នូវទឹកប្រាក់ដែលជាប់ទាក់ទិននឹងទ្រព្យសកម្មនោះ (ថ្លៃទិញ ទឹកប្រាក់កាត់បន្ថយ ទឹកប្រាក់បង្វិលសងវិញ ការកែលម្អជាប់លាប់...)។

២- ចំពោះទ្រព្យសកម្មរូបីក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤៖ សហគ្រាសត្រូវកត់ត្រាក្នុងគណនីទ្រព្យសកម្មរួមសម្រាប់ថ្នាក់នីមួយៗ ហើយត្រូវកត់ត្រាចូលនូវចំនួនទឹកប្រាក់ដែលមិនទាន់បានធ្វើរំលស់ ចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងលទ្ធកម្មបន្ថែមនូវទ្រព្យសកម្ម (ការទិញបន្ថែម ការទទួលបន្ថែម ការបញ្ចូលបន្ថែម...) និងចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងការបញ្ចេញទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ។

៣-ធនធានធម្មជាតិ៖ ចំណាយនានាក្នុងការស្វែងរុករកនិងអភិវឌ្ឍន៍ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការស្វែងរុករកនិងអភិវឌ្ឍន៍ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីធនធានធម្មជាតិ។

៤- កសិកម្មរយៈពេលវែង (ទ្រព្យសកម្មជីវសាស្ត្រ)៖

ក- ដំណាំកសិកម្ម៖ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការដាំដុះ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍនិងការដាំដុះ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការដាំដុះ។

ខ- ការចិញ្ចឹមសត្វ៖ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការចិញ្ចឹមសត្វ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍនិងការចិញ្ចឹមសត្វ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការចិញ្ចឹមសត្វ។

៥- ក្នុងករណីទ្រព្យសកម្មរយៈពេលវែងត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មផង និងប្រើប្រាស់ក្រៅអាជីវកម្មផង សហគ្រាស ត្រូវអនុវត្តដូចខាងក្រោម៖

ក- ការប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែងសម្រាប់បម្រើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស ឬផ្តល់ឱ្យនិយោជិតឬតតិយជនត្រូវចាត់ទុកថាបានផ្គត់ផ្គង់សេវាតាមតម្លៃទីផ្សារ (កត់ត្រាចូលក្នុងចំណូលបន្ទាប់បន្សំ)។ ក្នុងករណីនេះ ការផ្តល់ឱ្យនិយោជិតត្រូវបានអនុញ្ញាតជាចំណាយកាត់កងបាននិងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។

ខ- ចំពោះសហគ្រាសឯកបុគ្គលឬសហគ្រាសសហកម្មសិទ្ធិ ការប្រើប្រាស់ដីនិងអគារផ្ទាល់ខ្លួនសម្រាប់ធ្វើអាជីវកម្ម សហគ្រាសមិនត្រូវកត់ត្រាចូលក្នុងតារាងតុល្យការ ហើយក៏មិនត្រូវបានចាត់ទុកជាការជួលដែរ។ ក្នុងករណីសហគ្រាសបានកត់ត្រាចូលក្នុងតារាងតុល្យការ ចំណាយរំលស់មិនត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធឡើយ ហើយមិនត្រូវចាត់ទុកថាបានលក់ទេនៅពេលឈប់ប្រើប្រាស់ក្នុងអាជីវកម្ម។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ ម្ចាស់ដីនិងអគារ រួមបញ្ចូលបុគ្គលទាំងឡាយដែលមានឈ្មោះក្នុងសៀវភៅគ្រួសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

គ- ចំពោះសហគ្រាសដែលបានអនុវត្តតាមវិធានដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ការប្រើប្រាស់ចម្រុះនូវទ្រព្យសកម្មរយៈពេលវែងកត់ត្រាក្នុងតារាងតុល្យការ ពុំមានផលប៉ះពាល់អ្វីដល់ការធ្វើរំលស់ទេ។



ዞ

**ប្រការ៣៥** .- រំលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម

១-រំលស់ត្រូវធ្វើលើមូលដ្ឋាននៃថ្លៃដើមនៃទ្រព្យសកម្មដែលត្រូវរំលស់។ ទឹកប្រាក់បូកយោងនៃរំលស់ទ្រព្យសកម្មណាមួយមិនអាចលើសពីថ្លៃដើមនៃទ្រព្យសកម្មនោះបានទេ ទោះបីការវាយតម្លៃឡើងវិញធំជាងថ្លៃដើមក៏ដោយ។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ថ្លៃដើម សំដៅដល់ តម្លៃពីដំបូងនៃទ្រព្យសកម្មនៅពេលនិងនៅទីកន្លែងដែលទ្រព្យសកម្មនោះត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យបញ្ចូលទៅក្នុងទ្រព្យរបស់សហគ្រាស។ ថ្លៃដើមនៃទ្រព្យសកម្មហៅថា បរិយាទានប្រវត្តិសាស្ត្រដែលជាគោលការណ៍មិនអាចកែប្រែបានឡើយ។

២-ថ្លៃដើមឬបរិយាទានប្រវត្តិសាស្ត្រនៃទ្រព្យសកម្មដែលត្រូវបញ្ចូលជាទ្រព្យរបស់សហគ្រាស ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ចំពោះទ្រព្យសកម្មដែលសហគ្រាសបានទិញ ត្រូវកំណត់តាមថ្លៃទ្រព្យដែលបានទិញដោយ៖

- ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យនូវថ្លៃទិញ ដកចេញនូវការបញ្ចុះថ្លៃ បូកបញ្ចូលនូវចំណាយបន្ទាប់បន្សំផ្សេងៗ (ពន្ធគយនិងចំណាយជាប់ទាក់ទិន ការដឹកជញ្ជូន ចំណាយឆ្លងកាត់និងឃ្លាំងស្តុក ចំណាយទទួលទ្រព្យសកម្មរយៈពេលវែង មានការលើកដាក់ ធានារ៉ាប់រងលើការដឹកជញ្ជូន...) និងចំណាយផ្គុំដំឡើងដែលចាំបាច់ក្នុងការដាក់ទ្រព្យសកម្មឱ្យដំណើរការ
- ចំណាយទូទៅ និងចំណាយហិរញ្ញវត្ថុទាក់ទិននឹងទ្រព្យសកម្មរយៈពេលវែង មិនត្រូវគិតបញ្ចូលក្នុងថ្លៃដើមនៃការទិញទេ
- ក្នុងករណីមានការពន្យារពេលទូទាត់ តម្លៃទ្រព្យសកម្មដែលត្រូវកត់ត្រា ត្រូវផ្អែកលើថ្លៃព្រមព្រៀង ដូច្នេះគឺពុំទាក់ទិនទៅនឹងបែបបទនៃការទូទាត់នៅថ្ងៃក្រោយឡើយ ទោះបីតម្លៃត្រូវសងកើនឡើងឬថយចុះក៏ដោយ។

ខ- ចំពោះទ្រព្យសកម្មដែលសហគ្រាសបានផលិត ត្រូវកំណត់តាមថ្លៃដើមផលិតកម្មដោយ៖

- ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យតាមតម្លៃពិតនៃផលិតកម្ម ដែលជាថ្លៃដើមនៃការទិញវត្ថុធាតុនិងសម្ភារផ្គត់ផ្គង់ដែលបានប្រើប្រាស់ បូកបន្ថែមនូវចំណាយផ្ទាល់ទាំងអស់ (ចំណាយពលកម្ម ចំណាយសេវាខាងក្រៅ) និងចំណាយប្រយោលនៃផលិតកម្មក្នុងលក្ខណៈដែលចំណាយទាំងនោះអាចកំណត់បាននិងសមហេតុសមផលទៅក្នុងថ្លៃដើមផលិតកម្មនៃទ្រព្យសកម្មនោះ។ ថ្លៃដើមនៃផលិតកម្ម ត្រូវបានគណនាតាមគណនេយ្យថ្លៃដើម ឬប្រសិនបើគ្មានគណនេយ្យថ្លៃដើមទេ ត្រូវគណនាតាមវិធីគណនាស្ថិតិ
- ថ្លៃដើមផលិតកម្មមិនត្រូវរួមបញ្ចូលទេនូវចំណាយលើការស្តុក ការលក់និងការគ្រប់គ្រងទូទៅ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងចំណាយហិរញ្ញវត្ថុ។ ដោយឡែក ចំពោះថ្លៃដើមផលិតកម្មនៃទ្រព្យសកម្មធំៗ ដូចជាការសាងសង់រោងចក្រឧស្សាហកម្ម ការដាំដំណាំឬការចិញ្ចឹមសត្វរយៈពេលវែង ការប្រាក់នៃបំណុលនានាដែលបានផ្តល់ទុនក្នុងការសាងសង់ ការដាំដុះឬការចិញ្ចឹមទាំងនេះ ត្រូវបានអនុញ្ញាតឱ្យបូកបញ្ចូលចាប់ពីពេលខ្ចីបុលដំបូងរហូតដល់ពេលធ្វើផលិតកម្មប៉ុណ្ណោះ។

គ- ចំពោះទ្រព្យសកម្មដែលសហគ្រាសទទួលបានពីរដ្ឋ សមូហភាពសាធារណៈ ឬអ្នកវិនិយោគឯកជន ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យតាមតម្លៃឧបហារិត ដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនៃឧបហារិត។

ឃ-ចំពោះទ្រព្យសកម្មដែលសហគ្រាសបានមកដោយគ្មានបង់ថ្លៃ ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យតាមតម្លៃទីផ្សារ ឬថ្លៃដែលសហគ្រាសឯករាជ្យធ្វើប្រតិបត្តិការជាមួយគ្នា។

៣-អាករលើតម្លៃបន្ថែមដែលបានបង់លើការទិញឬការផលិតទ្រព្យសកម្មដែលមិនអនុញ្ញាតជាឥណទានអាករលើធាតុចូល ត្រូវបានអនុញ្ញាតឱ្យបូកបញ្ចូលក្នុងថ្លៃដើមនៃទ្រព្យនោះ។

**ប្រការ៣៦** .- វិធីរំលស់ធម្មតា

វិធីរំលស់ធម្មតានៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានកំណត់ដូចខាងក្រោម៖

១-ទ្រព្យសកម្មអរូបី៖ ទ្រព្យសកម្មអរូបីទាំងអស់ត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគទៅតាមអាយុកាលប្រើប្រាស់នៃទ្រព្យទាំងនោះ ឬ ១០ (ដប់) ភាគរយ ក្នុងមួយឆ្នាំ ប្រសិនបើមិនអាចកំណត់អាយុកាលប្រើប្រាស់បាន។

២-ទ្រព្យសកម្មរូបី៖

ក- ទ្រព្យសកម្មថ្នាក់១៖ ត្រូវធ្វើរំលស់ដោយឡែកពីគ្នា តាមវិធីរំលស់ស្មើភាគតាមអត្រា ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំនៃបរិយាទានលទ្ធកម្ម (ថ្លៃដើម)។ ចំពោះអគារដែលមានលក្ខណៈជាអគារមិនមែនបេតុង រំលស់ត្រូវធ្វើឡើងតាមអត្រា ១០ (ដប់) ភាគរយ ក្នុងមួយឆ្នាំ។

ខ- ទ្រព្យសកម្មថ្នាក់២៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ៥០ (ហាសិប) ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ។

គ- ទ្រព្យសកម្មថ្នាក់៣៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ២៥ (ម្ភៃប្រាំ) ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ។

ឃ-ទ្រព្យសកម្មថ្នាក់៤៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ២០ (ម្ភៃ) ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ។

៣-ធនធានធម្មជាតិ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវបានគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិ ទៅគុណនឹងផលចែករវាងបរិមាណដែលផលិតបាននៅក្នុងឆ្នាំជាប់ពន្ធ និងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ។

៤-កសិកម្មរយៈពេលវែង៖

ក- ដំណាំកៅស៊ូ៖ អនុញ្ញាតឱ្យធ្វើរំលស់ក្នុងរយៈពេល ២០ឆ្នាំ ទៅតាមអត្រាដែលបានកំណត់ដូចខាងក្រោម៖

| ឆ្នាំទទួលផល | អត្រារំលស់ |
|---|---|
| ឆ្នាំទី១ និង ឆ្នាំទី២ | ៣% |
| ឆ្នាំទី៣ និង ឆ្នាំទី៤ | ៤% |
| ឆ្នាំទី៥ ដល់ ឆ្នាំទី១០ | ៥% |
| ឆ្នាំទី១១ និង ឆ្នាំទី១២ | ៧% |
| ឆ្នាំទី១៣ ដល់ ឆ្នាំទី១៥ | ៦% |
| ឆ្នាំទី១៦ ដល់ ឆ្នាំទី១៩ | ៥% |
| ឆ្នាំទី២០ | សមតុល្យនៅសល់ |

ខ- ដំណាំកសិកម្មក្រៅពីកៅស៊ូ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាតាមវិធីរំលស់ស្មើភាគតាមអាយុកាលនៃការទទួលផល ឬ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំដោយជ្រើសរើសជម្រើសណាមួយដែលឆាប់ជាង។

គ- ការចិញ្ចឹមសត្វ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាតាមវិធីរំលស់ស្មើភាគតាមអាយុកាលនៃការទទួលផល ឬ ១០ (ដប់) ភាគរយ ក្នុងមួយឆ្នាំដោយជ្រើសរើសជម្រើសណាមួយដែលឆាប់ជាង។

**ប្រការ៣៧** .- ពេលចាប់ផ្តើមធ្វើរំលស់

១-រំលស់ទ្រព្យសកម្មតាមវិធីរំលស់ស្មើភាគ ត្រូវអនុវត្តដូចខាងក្រោម៖

ក- រំលស់ត្រូវធ្វើឡើងចាប់ពីពេលដែលទ្រព្យសកម្មត្រូវបានដាក់ប្រើប្រាស់ និងបញ្ចប់នៅពេលដែលទ្រព្យសកម្មត្រូវបានរំលស់អស់ (នៅពេលនោះទឹកប្រាក់រំលស់បូកយោងត្រូវស្មើនឹងថ្លៃដើមនៃទ្រព្យសកម្ម)។ ចំណុចបញ្ចប់ក៏អាចកើតមានឡើងមុនកាលបរិច្ឆេទរំលស់អស់ ដូចក្នុងករណីនៃការបញ្ចេញទ្រព្យសកម្មរបស់សហគ្រាសដោយការលក់ ការដាក់ឱ្យទៅជាកាកសំណល់ឬបំផ្លាញចោលដែរ។ ទ្រព្យសកម្មដែលបានដាក់ឱ្យប្រើប្រាស់ក្នុងអំឡុងពេលណាមួយនៃឆ្នាំជាប់ពន្ធ ត្រូវអនុញ្ញាតឱ្យគិតរំលស់ពេញមួយឆ្នាំ។



4-

ខ- ចំពោះឆ្នាំបញ្ចប់រំលស់៖

- ក្នុងករណីទ្រព្យសកម្មត្រូវបានបញ្ចេញពីសហគ្រាស ទឹកប្រាក់រំលស់ត្រូវស្មើនឹងសូន្យ
- ក្នុងករណីទ្រព្យសកម្មណាមួយបានបញ្ចប់អាយុកាលប្រើប្រាស់របស់វា ទឹកប្រាក់រំលស់ត្រូវស្មើនឹងសមតុល្យមិនទាន់រំលស់នៃគណនីទ្រព្យសកម្មនៃទ្រព្យនោះ។ ប៉ុន្តែប្រសិនបើសមតុល្យនេះធំជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ (មានការកែលម្អជាប់លាប់) ទ្រព្យសកម្មជាប់ទាក់ទិនត្រូវបានចាត់ទុកថាបានកើនអាយុកាលប្រើប្រាស់ និងត្រូវបានធ្វើរំលស់ជាបន្តទៀតរហូតដល់សមតុល្យនេះតូចជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ ទើបធ្វើរំលស់ឱ្យអស់ដើម្បីបញ្ចប់រំលស់តែម្តង។

២-រំលស់ទ្រព្យសកម្មតាមវិធីរំលស់ថយចុះជាលំដាប់ ត្រូវអនុវត្តដូចខាងក្រោម៖

ក- រំលស់ត្រូវធ្វើឡើងចាប់ពីពេលដែលទ្រព្យសកម្មត្រូវបានដាក់ឱ្យប្រើប្រាស់។ ទ្រព្យសកម្មដែលបានដាក់ប្រើប្រាស់ក្នុងអំឡុងពេលណាមួយនៃឆ្នាំជាប់ពន្ធ ត្រូវអនុញ្ញាតឱ្យគិតរំលស់ពេញមួយឆ្នាំ។

ខ- ទឹកប្រាក់រំលស់ដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ថ្នាក់នីមួយៗ ស្មើនឹងមូលដ្ឋានរំលស់គុណនឹងអត្រារំលស់សម្រាប់ថ្នាក់នីមួយៗ។

គ- មូលដ្ឋានរំលស់សម្រាប់ឆ្នាំទី១ នៃអាជីវកម្ម គឺស្មើនឹងចំនួនសរុបនៃថ្លៃដើមនៃទ្រព្យសកម្មក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាតាមថ្នាក់នីមួយៗដែលបានដាក់ប្រើប្រាស់។

ឃ-ចំពោះឆ្នាំជាប់ពន្ធបន្តបន្ទាប់ មូលដ្ឋានរំលស់ស្មើនឹងសមតុល្យដើមគ្រានៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាបូកនឹងថ្លៃដើមទ្រព្យសកម្មដាក់ប្រើប្រាស់ក្នុងឆ្នាំជាប់ពន្ធ ដកថ្លៃលក់ទ្រព្យសកម្មដែលបានដកចេញក្នុងឆ្នាំជាប់ពន្ធ។

ង- នៅក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើទ្រព្យណាមួយនៅក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវបានដកចេញឬលក់ពីអាជីវកម្ម សហគ្រាសត្រូវដកចេញពីមូលដ្ឋានរំលស់នៃទ្រព្យសកម្មរួមបញ្ចូលគ្នានូវតម្លៃទ្រព្យដែលបានដកចេញឬលក់នោះ៖

- ប្រសិនបើការកត់ត្រាបែបនេះធ្វើឱ្យសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាក្លាយជាអវិជ្ជមាន សហគ្រាសត្រូវកត់ត្រាជាប្រាក់ចំណូលជាប់ពន្ធនូវទឹកប្រាក់ស្មើនឹងសមតុល្យអវិជ្ជមាននេះ ហើយសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវកែតម្រូវមកសូន្យវិញ
- នៅចុងឆ្នាំជាប់ពន្ធ ប្រសិនបើក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាណាមួយ ជាក់ស្តែងគ្មាននៅសល់ទ្រព្យសកម្មអ្វីទៀតទេនោះ សមតុល្យវិជ្ជមាននៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នានោះ ត្រូវបានកត់ត្រាជាការខាតបង់អាចកាត់កងបាន ហើយសមតុល្យនៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវបានកែតម្រូវមកសូន្យវិញ។

៣-រំលស់ធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង៖ សហគ្រាសត្រូវចាប់ផ្តើមធ្វើរំលស់ធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែងនៅឆ្នាំដែលចាប់ផ្តើមធ្វើផលិតកម្ម។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ឆ្នាំចាប់ផ្តើមធ្វើផលិតកម្ម សំដៅដល់ឆ្នាំដែលសហគ្រាសបានទទួលចំណូលពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង។ ចំពោះទ្រព្យសកម្មរយៈពេលវែងដែលបានទិញឬបានបង្កើតក្រោយឆ្នាំចាប់ផ្តើមធ្វើផលិតកម្ម សហគ្រាសត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់តាមវិធីដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការ៣៦ នៃប្រកាសនេះ។ ប្រសិនបើអាជីវកម្មលើធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង ត្រូវបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយនៅក្នុងឆ្នាំជាប់ពន្ធនូវតម្លៃទ្រព្យសកម្មដែលនៅសេសសល់ទាំងអស់រួមបញ្ចូលទាំងចំណាយស្វែងរុករក ចំណាយអភិវឌ្ឍន៍ ចំណាយដាំដុះ និងចំណាយចិញ្ចឹមសត្វ។

**ប្រការ៣៨ ._** រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស

១-នៅក្នុងឆ្នាំជាប់ពន្ធនីមួយៗ សហគ្រាសត្រូវតែធ្វើរំលស់សម្រាប់ធានាការសឹករេចដើម្បីកាត់កងក្នុងឆ្នាំជាប់ពន្ធនោះ ទោះបីមានប្រាក់ចំណូលជាប់ពន្ធគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់សម្រាប់ការកាត់កងក៏ដោយ។ រំលស់ត្រូវធ្វើយ៉ាងពិតប្រាកដដោយសហគ្រាសក្រោមមូលដ្ឋានបរិយាទានប្រវត្តិសាស្ត្រ។ ក្នុងករណីនៅដំណាច់ឆ្នាំជាប់ពន្ធណាមួយ សហគ្រាសធ្វើការវាយតម្លៃទៅតាមតម្លៃពិតបច្ចុប្បន្ននូវទ្រព្យសកម្មរបស់ខ្លួន (ធ្វើសារពើភណ្ឌលម្អិត) សហគ្រាសត្រូវជូនដំណឹងមករដ្ឋបាលសារពើពន្ធអំពីលទ្ធផលនៃការវាយតម្លៃនោះ។ សម្រាប់គោលដៅពន្ធដារ ប្រសិនបើលទ្ធផលនៃការវាយតម្លៃធ្វើឱ្យ



4

មានការប្រែប្រួលតម្លៃពិតនៃទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ លម្អៀងលើសនៃការវាយតម្លៃឡើងវិញត្រូវចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធ និងជាមូលដ្ឋានបន្ថែមសម្រាប់រំលស់បន្ត។

២- ទឹកប្រាក់រំលស់ដែលអាចកាត់កងបាន ត្រូវតែគណនាតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកនេះនិងបានកត់ត្រាក្នុងតារាងគណនារំលស់នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនៃឆ្នាំជាប់ពន្ធនីមួយៗ។

៣- សហគ្រាសមិនត្រូវបានអនុញ្ញាតឱ្យលើកពេលរំលស់ទ្រព្យសកម្មណាមួយទេ។

៤- ទឹកប្រាក់រំលស់ឬចំណែកណាមួយនៃទឹកប្រាក់រំលស់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ដែលពុំបានកត់ត្រាក្នុងតារាងគណនារំលស់នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យយកទៅកាត់កងក្នុងឆ្នាំជាប់ពន្ធផ្សេងទៀតបានឡើយ ។

៥- រំលស់ដែលត្រូវបានបដិសេធចេញពីចំណាយអាចកាត់កងបានដូចមានចែងក្នុងកថាខណ្ឌទី៤ នៃប្រការនេះ ត្រូវបានចាត់ទុកថាត្រូវបានធ្វើឡើងជាប្រក្រតីសម្រាប់ការគណនាតម្លៃលើស ឬតម្លៃខ្វះនៃការលក់។

**ឧទាហរណ៍ទី៧៖**

ក- សហគ្រាសមួយបានទិញឃ្លាំងមួយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៤ ដែលមានថ្លៃដើម ៤០០ ០០០ ០០០ រៀល។

ខ- សហគ្រាសបានធ្វើរំលស់ឃ្លាំងនោះជាទៀងទាត់តាមវិធីរំលស់ស្មើភាគតាមអត្រា ៥% សម្រាប់អាយុកាលប្រើប្រាស់ ២០ឆ្នាំ លើកលែងតែនៅឆ្នាំ២០០៦ ដោយសារតែនៅឆ្នាំជាប់ពន្ធនោះ សហគ្រាសមានការខាតបង់ធ្ងន់ធ្ងរ។

គ- ឃ្លាំងត្រូវបានលក់ចេញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨ បានប្រាក់ ១៥០ ០០០ ០០០ រៀល។

ឃ-ស្ថានភាពទាក់ទិននឹងការគណនារំលស់ តម្លៃលើសឬតម្លៃខ្វះ នៃឃ្លាំងនេះមានដូចខាងក្រោម៖

- អត្រារំលស់៖ ៥% ( ឃ្លាំងមានអាយុកាលប្រើប្រាស់ ២០ឆ្នាំ ជាទ្រព្យសកម្មរូបីថ្នាក់១ )
- រំលស់ត្រូវបានកត់ត្រាជាចំណាយសម្រាប់ឆ្នាំនីមួយៗ៖

| | |
|---|---|
| - រំលស់ឆ្នាំ២០០៤ | = ៤០០ ០០០ ០០០ រៀល x ៥% |
| | = ២០ ០០០ ០០០ រៀល (ឆ្នាំចាប់ផ្តើមរំលស់គិតស្មើនឹងរំលស់ប្រចាំឆ្នាំ) |
| - រំលស់ឆ្នាំ២០០៥ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០០៦ | = ០ រៀល |
| - រំលស់ឆ្នាំ២០០៧ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០០៨ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០០៩ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១០ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១១ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១២ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១៣ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១៤ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១៥ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១៦ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១៧ | = ២០ ០០០ ០០០ រៀល |
| - រំលស់ឆ្នាំ២០១៨ | = ០ រៀល (ឆ្នាំបញ្ចេញទ្រព្យសកម្ម រំលស់គិតស្មើសូន្យ)។ |
| **តម្លៃនៅសល់មិនទាន់រំលស់** | **= ថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) - តម្លៃរំលស់បូកយោង** |
| - ថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) | = ៤០០ ០០០ ០០០ រៀល |
| - តម្លៃរំលស់បូកយោង | = ២៦០ ០០០ ០០០ រៀល |
| - តម្លៃនៅសល់មិនទាន់រំលស់ | = ១៤០ ០០០ ០០០ រៀល។ |



4

**តម្លៃលើស = ថ្លៃលក់ - តម្លៃនៅសល់មិនទាន់រំលស់**

- ថ្លៃលក់ = ១៥០ ០០០ ០០០ រៀល
- តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល
- តម្លៃលើស = ១០ ០០០ ០០០ រៀល។

ង- សម្រាប់គោលដៅពន្ធដារ តម្លៃលើសនេះត្រូវតែបន្ថែមទឹកប្រាក់រំលស់លើកពេលចំនួន ២០ ០០០ ០០០ រៀល នៅឆ្នាំ២០០៦។ ដូច្នេះតម្លៃលើសជាប់ពន្ធ គឺ ៣០ ០០០ ០០០ (១០ ០០០ ០០០ + ២០ ០០០ ០០០) រៀល។

ច- ករណីនៃតម្លៃខ្វះ៖

ប្រសិនបើឃ្លាំងលក់បានថ្លៃ ១១០ ០០០ ០០០ រៀលវិញ តម្លៃខ្វះ គឺ៖

- ថ្លៃលក់ = ១១០ ០០០ ០០០ រៀល
- តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល
- តម្លៃខ្វះ (ខាត) = ៣០ ០០០ ០០០ រៀល។

តម្លៃខ្វះ (ខាត) ដែលអាចកាត់កងបានសម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល គឺមានតែ ១០ ០០០ ០០០ រៀល ប៉ុណ្ណោះ គឺតម្លៃដែលកត់ត្រាខាត ៣០ ០០០ ០០០ រៀល ត្រូវបានកាត់បន្ថយតម្លៃរំលស់លើកពេល ក្នុងឆ្នាំ២០០៦ ចំនួន ២០ ០០០ ០០០ រៀល។

៦- ការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូល៖

ក- ឆ្លងតាមឧទាហរណ៍ទី៧ ឃើញថាសហគ្រាសត្រូវជាប់ពន្ធលើប្រាក់ចំណូល ចំពោះទឹកប្រាក់រំលស់ដែលបានលើកពេល។ សម្រាប់ការអនុវត្តជាក់ស្តែង សហគ្រាសត្រូវធ្វើការកែតម្រូវគណនីរំលស់ទ្រព្យសកម្មនៃឆ្នាំជាប់ពន្ធដែលមានកំហុស ដោយគិតបញ្ចូលមកវិញនូវទឹកប្រាក់រំលស់លើកពេល។

ខ- ចំពោះទឹកប្រាក់រំលស់ឬទឹកប្រាក់សំវិធានធនដែលបង្កើតឡើងដោយខុសគោលការណ៍ ឬដែលមានទឹកប្រាក់លើសពីកម្រិតអនុញ្ញាត សហគ្រាសត្រូវកែតម្រូវទឹកប្រាក់រំលស់ឬសំវិធានធនដែលខុសនេះ សម្រាប់ឆ្នាំជាប់ពន្ធដែលមានកំហុស។

គ- សម្រាប់ករណីដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ សហគ្រាសត្រូវដាក់លិខិតប្រកាសកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ។

ឃ-នៅក្រោយពេលដែលសហគ្រាសបានអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃកថាខណ្ឌនេះរួចហើយ សហគ្រាសអាចធ្វើរំលស់ឬសំវិធានធនជាបន្តទៀតទៅតាមគោលការណ៍ដែលច្បាប់ស្តីពីសារពើពន្ធបានអនុញ្ញាត។

**ប្រការ៣៩** .- រំលស់ពិសេស

រំលស់ពិសេសត្រូវបានកំណត់ដូចខាងក្រោម៖

១-រំលស់ពិសេស ត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំទី១ នៃការទិញ ឬនាពេលក្រោយមកទៀតនៅឆ្នាំទី១ នៃការដាក់ប្រើប្រាស់ទ្រព្យសកម្មរូបី។ ចំនួនដែលអនុញ្ញាតឱ្យកាត់កងនេះ ស្មើនឹង ៤០ (សែសិប) ភាគរយ នៃតម្លៃមូលធននៃទ្រព្យសកម្មរូបីថ្មី ឬទ្រព្យសកម្មរូបីប្រើប្រាស់រួច ដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្មឬការកែច្នៃ។ ក្នុងឆ្នាំជាប់ពន្ធដដែល តម្លៃមូលធននៃទ្រព្យសកម្មរូបីដែលនៅសល់ត្រូវបានអនុញ្ញាតឱ្យធ្វើរំលស់តាមវិធីរំលស់ធម្មតាដូចមានចែងក្នុងប្រការ៣៦ នៃប្រកាសនេះ។

២-រំលស់ពិសេសនៃទ្រព្យសកម្មរូបី នឹងត្រូវបានយកមកកាត់កងដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ឆ្នាំជាប់ពន្ធ ប្រសិនបើអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធដូចមានចែងក្នុងកថាខណ្ឌទី៣ នៃប្រការ៤៩ នៃប្រកាសនេះ។



ᐯ

៣-ទ្រព្យសកម្មរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេស ត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤ឆ្នាំជាប់ពន្ធ បន្ទាប់ពីឆ្នាំជាប់ពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង។ ប្រសិនបើទ្រព្យសកម្មរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កង កាត់បន្ថយដោយចំនួនមួយស្មើនឹង ២ (ពីរ) ភាគរយ នៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ប្រើប្រាស់។ ចំនួននេះនឹងមិនប៉ះពាល់ដល់តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មរូបីសម្រាប់ការកំណត់ប្រាក់ចំណេញមូលធនតាមមាត្រា៧ នៃច្បាប់ស្តីពីសារពើពន្ធទេ។

**ឧទាហរណ៍ទី៨៖**

សហគ្រាសវិនិយោគមួយចាប់ផ្តើមប្រកបអាជីវកម្មនៅដើមឆ្នាំជាប់ពន្ធ ២០២១ មានម៉ាស៊ីន ៣គ្រឿង សម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល ម៉ាស៊ីនស្ថិតក្នុងទ្រព្យសកម្មថ្នាក់៤ ដែលបានកត់ត្រាក្នុងតារាងរំលស់មានតម្លៃ ២៦ ០០០ ០០០ រៀល (ម៉ាស៊ីនទី១៖ ១០ ០០០ ០០០ រៀល ម៉ាស៊ីនទី២៖ ១០ ០០០ ០០០ រៀល និងម៉ាស៊ីនទី៣៖ ៦ ០០០ ០០០ រៀល)។ នៅឆ្នាំ២០២២ សហគ្រាសបានលក់ម៉ាស៊ីនទី៣ ទៅឱ្យសហគ្រាសផ្សេងក្នុងតម្លៃ ៥ ០០០ ០០០ រៀល ហើយបានទិញម៉ាស៊ីនគំរូថ្មីមួយគ្រឿងមកវិញមានតម្លៃ ២០ ០០០ ០០០ រៀល។ សហគ្រាសបានជ្រើសយកវិធីរំលស់ពិសេសសម្រាប់ដំណើរការវិនិយោគ។ រំលស់ ត្រូវបានគណនាដូចខាងក្រោម៖

ក- រំលស់ម៉ាស៊ីនទាំង ៣គ្រឿង សម្រាប់ឆ្នាំ២០២១៖

- រំលស់ពិសេស (២៦ ០០០ ០០០ x ៤០%) = ១០ ៤០០ ០០០ រៀល
- មូលដ្ឋានរំលស់ធម្មតា (២៦ ០០០ ០០០ - ១០ ៤០០ ០០០) = ១៥ ៦០០ ០០០ រៀល
- រំលស់ធម្មតា (១៥ ៦០០ ០០០ x ២០%) = ៣ ១២០ ០០០ រៀល
- សរុបរំលស់សម្រាប់ឆ្នាំ២០២១ (១០ ៤០០ ០០០ + ៣ ១២០ ០០០) = ១៣ ៥២០ ០០០ រៀល
- មូលដ្ឋានរំលស់យោងទៅឆ្នាំ២០២២ (២៦ ០០០ ០០០ - ១៣ ៥២០ ០០០) = ១២ ៤៨០ ០០០ រៀល។

ខ- រំលស់សម្រាប់ឆ្នាំ២០២២៖

- រំលស់ពិសេសសម្រាប់ម៉ាស៊ីនទិញថ្មី (២០ ០០០ ០០០ x ៤០%) = ៨ ០០០ ០០០ រៀល
- មូលដ្ឋានរំលស់ធម្មតាសម្រាប់ម៉ាស៊ីនទិញថ្មី (២០ ០០០ ០០០ - ៨ ០០០ ០០០) = ១២ ០០០ ០០០ រៀល
- មូលដ្ឋានរំលស់ធម្មតាសម្រាប់ម៉ាស៊ីនទាំងអស់ (ចំណូលពីការលក់ម៉ាស៊ីនចាស់)
  (១២ ៤៨០ ០០០ + ១២ ០០០ ០០០ - ៥ ០០០ ០០០) = ១៩ ៤៨០ ០០០ រៀល
- ទឹកប្រាក់រំលស់ធម្មតា (១៩ ៤៨០ ០០០ x ២០%) = ៣ ៨៩៦ ០០០ រៀល
- សរុបទឹកប្រាក់រំលស់សម្រាប់ឆ្នាំ២០២២ (៨ ០០០ ០០០ + ៣ ៨៩៦ ០០០) = ១១ ៨៩៦ ០០០ រៀល
- មូលដ្ឋានរំលស់យោងទៅឆ្នាំ២០២៣
  (១២ ៤៨០ ០០០ + ២០ ០០០ ០០០ - ៥ ០០០ ០០០ - ១១ ៨៩៦ ០០០) = ១៥ ៥៨៤ ០០០ រៀល។

គ- ការកែតម្រូវពន្ធលើប្រាក់ចំណូលទាក់ទិនទៅនឹងការលក់ម៉ាស៊ីនក្នុងឆ្នាំ២០២២ (បន្ទាប់ពីដាក់ប្រើបាន ១៦ខែ)៖

ប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំ២០២២ ត្រូវបានកើនឡើងដោយសារការកែតម្រូវការកាត់កងរំលស់ពិសេសមកវិញនូវចំនួនទឹកប្រាក់ចំនួន ២% សម្រាប់ខែនីមួយៗដែលទ្រព្យសកម្មបានដាក់ប្រើ។ ប្រាក់ចំណូលជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសម្រាប់ឆ្នាំ២០២២ ត្រូវបានគណនាដូចខាងក្រោម៖

- រំលស់ពិសេស (៦ ០០០ ០០០ x ៤០%) = ២ ៤០០ ០០០ រៀល
- ដកចេញការកែតម្រូវសម្រាប់រយៈពេលដែលទ្រព្យសកម្មបានប្រើ
  (២ ៤០០ ០០០ x ២%) x ១៦ខែ = ៧៦៨ ០០០ រៀល
- ប្រាក់ចំណូលជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសម្រាប់ឆ្នាំ២០២២
  (២ ៤០០ ០០០ - ៧៦៨ ០០០) = ១ ៦៣២ ០០០ រៀល។

តម្លៃលើសឬខ្វះដែលបានមកពីការលក់ម៉ាស៊ីន ត្រូវអនុវត្តតាមផ្នែកទី៧ នៃជំពូកទី៣ នៃប្រកាសនេះ។

## ផ្នែកទី៧
## វិធានទូទៅស្តីពីតម្លៃលើស និងតម្លៃខ្វះនៃទ្រព្យសកម្ម

**ប្រការ៤០ ._** គោលការណ៍ទូទៅនៃតម្លៃលើស និងតម្លៃខ្វះ

១- អនុលោមតាមមាត្រា៧ នៃច្បាប់ស្តីពីសារពើពន្ធ តម្លៃលើសដែលបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្ម ក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្មជាចំណែកមួយនៃប្រាក់ចំណូលជាប់ពន្ធ។

២- តម្លៃលើសឬតម្លៃខ្វះកើតឡើងអំពីលម្អៀងរវាងថ្លៃលក់និងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យសកម្ម ឬកើតឡើងអំពីការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម។

៣- តម្លៃលើសឬតម្លៃខ្វះ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- តម្លៃលើសឬតម្លៃខ្វះដែលសម្រេចបាន៖ តម្លៃនេះកើតមានឡើងតាមការបញ្ចេញទ្រព្យសកម្មរយៈពេលវែងណាមួយ។ ការបញ្ចេញនេះអាចជាការលក់ (ករណីភាគច្រើន) ការធ្វើឧបហារិតទៅក្នុងសហគ្រាសមួយទៀត ការដោះដូរ ការបែងចែក ការផ្តល់ជាអំណោយ ការយកវិញរបស់ម្ចាស់សហគ្រាសនាពេលកំពុងធ្វើអាជីវកម្ម ឬនាពេលបញ្ចប់អាជីវកម្ម ការរុះរើចេញ ការបំផ្លាញ ការឈប់ប្រើប្រាស់...។ ការបញ្ចេញនេះអាចជាអំពើដោយចេតនារបស់ម្ចាស់សហគ្រាសឬអ្នកគ្រប់គ្រងសហគ្រាស ឬជាវិបាកនៃការដកហូតតាមផ្លូវច្បាប់ ឬគ្រោះមហន្តរាយ...។

ខ- តម្លៃលើសបានកត់ត្រា៖ ការវាយតម្លៃឡើងវិញនូវទ្រព្យសកម្មដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យនូវតម្លៃបច្ចុប្បន្នរបស់ទ្រព្យទាំងនោះជំនួសឱ្យតម្លៃចាស់នាំឱ្យកើតឡើងនូវតម្លៃលើស។ តម្លៃលើសនេះជាតម្លៃគណនេយ្យសុទ្ធសាធ និងមិនមានឥទ្ធិពលលើប្រាក់ចំណូលជាប់ពន្ធឡើយ ក្នុងករណីដែលតម្លៃនេះមិនត្រូវបានប្រើប្រាស់ក្នុងគោលដៅរំលស់សារពើពន្ធ។

គ- តម្លៃខ្វះក្រោមរូបភាពជាសំវិធានធនមិនត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយទេ វៀរលែងតែតម្លៃខ្វះដែលសម្រេចបាន ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះប៉ុណ្ណោះ។

**ប្រការ៤១ ._** ការគណនាតម្លៃលើសឬតម្លៃខ្វះ

១- ការលក់ទ្រព្យសកម្មរយៈពេលវែងណាមួយបង្កើតបាននូវតម្លៃលើស កាលបើថ្លៃលក់មានតួលេខធំជាងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យដែលបានលក់នោះ។

២- តម្លៃនៅសល់មិនទាន់រំលស់៖

ក- ចំពោះទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានរំលស់តាមវិធីរំលស់ស្មើភាគ៖ តម្លៃនៅសល់មិនទាន់រំលស់ស្មើនឹងបរិយាទានប្រវត្តិសាស្ត្រនៃទ្រព្យសកម្មរយៈពេលវែងជាប់ទាក់ទិនណាមួយ បូកការកែលម្អជាប់លាប់ដកទឹកប្រាក់រំលស់បូកយោងដែលបានអនុវត្តចំពោះទ្រព្យនោះ។

ខ- ចំពោះទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានរំលស់តាមវិធីរំលស់ថយចុះជាលំដាប់៖ ចំពោះការបញ្ចេញទ្រព្យសកម្មរយៈពេលវែងប្រភេទនេះណាមួយ សហគ្រាសមិនត្រូវគណនាតម្លៃលើសឬតម្លៃខ្វះ សម្រាប់ទ្រព្យនោះដោយផ្ទាល់ទេ។ សហគ្រាសត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ៣៧ នៃប្រកាសនេះ ហើយតម្លៃលើសឬតម្លៃខ្វះនឹងត្រូវស្តែងចេញសម្រាប់គណនីទ្រព្យសកម្មរួមបញ្ចូលគ្នាក្នុងថ្នាក់នីមួយៗតែម្តង។

**ឧទាហរណ៍ទី៩៖**

ក- សហគ្រាសបានទិញនិងដាក់ឱ្យប្រើប្រាស់ទ្រព្យសកម្មថ្នាក់១ ចំនួនមួយមានតម្លៃ ២៥០ ០០០ ០០០ រៀល។ នៅឆ្នាំទី៣ សហគ្រាសបានធ្វើការកែលម្អជាប់លាប់ចំនួន ៥០ ០០០ ០០០ រៀល នៅឆ្នាំទី៥ សហគ្រាសបានលក់ទ្រព្យសកម្មនោះចេញវិញក្នុងតម្លៃ ៣៥០ ០០០ ០០០ រៀល។

ខ- ការគណនារំលស់៖

- អត្រារំលស់៖ ៥% (ទ្រព្យសកម្មរូបីថ្នាក់១)
- រំលស់ត្រូវបានកត់ត្រាជាចំណាយសម្រាប់ឆ្នាំនីមួយៗ៖

- រំលស់ឆ្នាំទី១៖ ២៥០ ០០០ ០០០ x ៥% = ១២ ៥០០ ០០០ រៀល
- រំលស់ឆ្នាំទី២៖ ២៥០ ០០០ ០០០ x ៥% = ១២ ៥០០ ០០០ រៀល
- រំលស់ឆ្នាំទី៣៖ (២៥០ ០០០ ០០០ + ៥០ ០០០ ០០០) x ៥% = ១៥ ០០០ ០០០ រៀល
- រំលស់ឆ្នាំទី៤៖ (២៥០ ០០០ ០០០ + ៥០ ០០០ ០០០) x ៥% = ១៥ ០០០ ០០០ រៀល
- សរុបទឹកប្រាក់រំលស់បូកយោង = ៥៥ ០០០ ០០០ រៀល។

គ- តម្លៃលើសឬតម្លៃខ្វះ៖

- បរិយាទានប្រវត្តិសាស្ត្រ = ២៥០ ០០០ ០០០ រៀល
- ការកែលម្អជាប់លាប់ = ៥០ ០០០ ០០០ រៀល
- រំលស់បូកយោង = ៥៥ ០០០ ០០០ រៀល
- តម្លៃនៅសល់មិនទាន់រំលស់ = ២៤៥ ០០០ ០០០ រៀល
- ថ្លៃលក់ = ៣៥០ ០០០ ០០០ រៀល
- តម្លៃលើស (៣៥០ ០០០ ០០០ - ២៤៥ ០០០ ០០០) = ១០៥ ០០០ ០០០ រៀល។

**ប្រការ៤២** .- ករណីពិសេស

ករណីពិសេសមួយចំនួនទាក់ទិននឹងតម្លៃលើសឬតម្លៃខ្វះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការខាតបង់ពីការលក់ ឬដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ឬដោយប្រយោលក្តីក្នុងចំណោមបុគ្គលទាក់ទិន ដែលមិនអនុវត្តតាមគោលការណ៍ជំហោងដៃ ជាចំណាយមិនអាចកាត់កងបាន។

២- ចំពោះឧបហារិតចូលក្រុមហ៊ុន តម្លៃលើសឬតម្លៃខ្វះត្រូវគណនាតាមតម្លៃពិតនៃបណ្ណភាគហ៊ុនឬភាគហ៊ុនដែលបានប្រគល់សម្រាប់ជាថ្នូរនៃឧបហារិត។ ជាធម្មតា តម្លៃពិតនៃបណ្ណភាគហ៊ុនឬភាគហ៊ុន ត្រូវស្មើនឹងតម្លៃប៉ាន់ស្មាននៃទ្រព្យសកម្មដែលបានយកមកបញ្ចូលដោយឧបហារិតទៅក្នុងបញ្ជីគណនេយ្យរបស់សហគ្រាសដែលទទួលឧបហារិត។

៣- ចំពោះការដោះដូរ ទោះបីមានឬគ្មានការបន្ថែមប្រាក់ក៏ដោយ ត្រូវបានចាត់ទុកជាប្រតិបត្តិការលក់ និងប្រតិបត្តិការទិញជាធម្មតា។ តម្លៃលើសឬតម្លៃខ្វះ គឺស្មើនឹងទឹកប្រាក់លម្អៀងរវាងតម្លៃទីផ្សារនៃទ្រព្យសកម្មដែលបានទទួល ក្នុងការដោះដូរ និងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យសកម្មដែលបានដោះដូរ។ ការដោះដូរត្រូវជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធដែលកើតមានការដោះដូរនេះ។

៤- ចំពោះការធ្វើអំណោយ ឬការដកយកវិញនូវទ្រព្យពីទ្រព្យសកម្មរបស់សហគ្រាស ឬការបញ្ឈប់សកម្មភាពអាជីវកម្ម តម្លៃលើសឬតម្លៃខ្វះនៃអំណោយឬទ្រព្យ ត្រូវគណនាតាមតម្លៃទីផ្សារនាថ្ងៃធ្វើអំណោយ ឬថ្ងៃដកយកវិញ ឬថ្ងៃបញ្ឈប់សកម្មភាព។

## ផ្នែកទី៨
## ពន្ធកាត់ទុក

**ប្រការ៤៣** .- គោលការណ៍ទូទៅនៃពន្ធកាត់ទុក

១- ស្របតាមមាត្រា២៥ មាត្រា២៦ និងមាត្រា៣១ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុឱ្យទៅបុគ្គលនិវាសជនឬអនិវាសនជន ត្រូវធ្វើការកាត់ទុកប្រាក់ពន្ធនាពេលទូទាត់ដើម្បីបង់ជូនរដ្ឋបាលសារពើពន្ធ។ សម្រាប់គោលដៅនៃពន្ធកាត់ទុក អ្នកជាប់ពន្ធត្រូវកត់ត្រាចំណាយបង្គរជារៀងរាល់ខែទៅតាមលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងខ្ទង់ចំណាយនោះបានកើតឡើង ទោះបីខ្ទង់ចំណាយនោះត្រូវបានទូទាត់ ឬមិនទាន់ទូទាត់ក្តី។ ប្រតិបត្តិការណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុក ដែលបានឬត្រូវកត់ត្រា ត្រូវចាត់ទុកថាបានទូទាត់។

២- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬបុគ្គលណាមួយដូចមានចែងក្នុងមាត្រា៣១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការកាត់ទុកនិងបង់ប្រាក់ពន្ធក្នុងនាមនៃតតិយជន ត្រូវបានកំណត់ថាជាភ្នាក់ងារកាត់ទុក។

**ប្រការ៤៤** ._ ពន្ធកាត់ទុកលើការទូទាត់ឱ្យទៅបុគ្គលនិវាសនជន

ភ្នាក់ងារកាត់ទុកដែលធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុឱ្យទៅបុគ្គលនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖

១- អត្រា ១៥ (ដប់ប្រាំ) ភាគរយ ចំពោះ៖

ក- ការទូទាត់ចំពោះការបំពេញសេវានានា រួមទាំងការគ្រប់គ្រងឬការពិគ្រោះយោបល់ឬសេវាប្រហាក់ប្រហែលឱ្យទៅបុគ្គលនិវាសជនដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ ប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រងឬការពិគ្រោះយោបល់ឬសេវាប្រហាក់ប្រហែល សំដៅដល់ ប្រាក់ចំណូលពីរាល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ក្រៅពីការផលិតនិងការលក់ទំនិញ ភតិសន្យា ការជួល ការលក់ទ្រព្យ និងក្រៅពីសកម្មភាពបម្រើការងារដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស។ ដោយមិនកំណត់ត្រឹមតែដូចតទៅនេះ ប្រាក់ចំណូលពីការបំពេញសេវា មានជាអាទិ៍ កម្រៃជើងសាឬជើងសាជំនួញ ប្រាក់ចំណូលពីសកម្មភាពដឹកជញ្ជូន ជួសជុល សាងសង់ គ្រប់គ្រង ពិគ្រោះយោបល់ ប្រាក់ចំណូលពីសេវាប្រហាក់ប្រហែល ដូចជា សេវាបច្ចេកទេស វិទ្យាសាស្ត្រ សិល្បៈ អប់រំសិក្សាធិការ វេជ្ជសាស្ត្រ ទន្តសាស្ត្រ នីតិសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម ការសិក្សា ស្រាវជ្រាវ គណនេយ្យ...។

ខ- ការទូទាត់ឱ្យទៅបុគ្គលនិវាសជននូវចំណូលពីសួយសារចំពោះទ្រព្យសកម្មអរូបី និងការទូទាត់រាល់អត្ថប្រយោជន៍ផ្សេងៗពីភាគកម្មក្នុងធនធានរ៉ែ ក្រៅពីប្រាក់ចំណូលសុទ្ធបានមកពីអាជីវកម្មលើធនធាននេះ និងភាគលាភដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិដោយឡែក។

គ- ការទូទាត់ការប្រាក់ដែលអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលមិនមែនជាធនាគារក្នុងស្រុកឱ្យទៅអ្នកជាប់ពន្ធនិវាសនជន។

២-អត្រា ១០ (ដប់) ភាគរយ ចំពោះការទូទាត់ប្រាក់ចំណូលពីការជួលចលនទ្រព្យឬអចលនទ្រព្យ។ សម្រាប់គោលដៅនៃពន្ធកាត់ទុក ប្រាក់ចំណូលពីការជួលចលនទ្រព្យឬអចលនទ្រព្យ សំដៅដល់ សាច់ប្រាក់ឬវត្ថុដែលអ្នកទទួលជួលបានបង់សម្រាប់ជាថ្នូរនៃការប្រើប្រាស់ចលនទ្រព្យ ដូចជា បរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម បច្ចេកទេស វិទ្យាសាស្ត្រ មធ្យោបាយដឹកជញ្ជូន... និងអចលនទ្រព្យ ដូចជា ដីធ្លី អគារ សំណង់ផ្សេងៗ...។ ក្នុងន័យនេះ អចលនទ្រព្យ ត្រូវរួមបញ្ចូលទាំងទ្រព្យបន្ទាប់បន្សំនៃអចលនទ្រព្យនោះ ព្រមទាំងសិទ្ធិអនុវត្តទៅតាមច្បាប់ដែលចែងពីកម្មសិទ្ធិដីធ្លី សិទ្ធិកាន់កាប់ សិទ្ធិអាស្រ័យផលលើអចលនទ្រព្យ និងសិទ្ធិនានាដែលបង្កឱ្យមានការទូទាត់ជាប្រាក់ ឬជាវត្ថុតាមចំនួនផ្សេងៗ ឬតាមចំនួនកំណត់។

៣-អត្រា ៦ (ប្រាំមួយ) ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់។

៤-អត្រា ៤ (បួន) ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ទៅឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើគ្មានកាលកំណត់។

**ប្រការ៤៥** ._ ពន្ធកាត់ទុកលើការទូទាត់ឱ្យទៅបុគ្គលអនិវាសនជន

វៀរលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីពន្ធដារ ភ្នាក់ងារកាត់ទុកដែលធ្វើការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ១៤ (ដប់បួន) ភាគរយ នៃទឹកប្រាក់ដែលត្រូវទូទាត់។

**ប្រការ៤៦** ._ ការលើកលែងការកាត់ទុកប្រាក់ពន្ធ

១- ការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុចំពោះករណីដូចខាងក្រោម មិនតម្រូវឱ្យធ្វើការកាត់ទុកប្រាក់ពន្ធទេ៖

ក- ការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុក និងការទូទាត់ប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។



4

ខ- ការទូទាត់ទៅឱ្យរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាលនូវសួយសារ ឬប្រាក់ថ្លៃឈ្នួលលើចលនទ្រព្យឬអចលនទ្រព្យ ដែលបំពេញបាននូវលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

- ត្រូវទាក់ទិននឹងចលនទ្រព្យឬអចលនទ្រព្យបានកត់ត្រាជាទ្រព្យសម្បត្តិរដ្ឋនៅក្នុងបញ្ជីសារពើភណ្ឌដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថាជាចំណូលបង់ចូលថវិការដ្ឋ។

គ- ការទូទាត់ប្រាក់ចំណូលរបស់រូបវន្តបុគ្គលដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ឬពន្ធលើអត្ថប្រយោជន៍បន្ថែមដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស។

ឃ-ការទូទាត់នូវការប្រាក់ដោយរាជរដ្ឋាភិបាលឬស្ថាប័នរាជរដ្ឋាភិបាល ទៅឱ្យបុគ្គលអនិវាសនជនចំពោះប្រាក់ខ្ចីដែលរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទទួលស្គាល់និងយល់ព្រម។

ង- ការទូទាត់ប្រាក់ចំពោះការផ្គត់ផ្គង់សេវាណាមួយដែលមានតម្លៃក្រោម ៥០ ០០០ (ប្រាំម៉ឺន) រៀល។

២- ការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានលើកលែងពីពន្ធកាត់ទុកចំពោះករណីដូចខាងក្រោម៖

ក- ប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល។

ខ- ប្រាក់ចំណូលពីការផ្គត់ផ្គង់៖

- កញ្ចប់សុសវែរដែលអនុញ្ញាតឱ្យប្រើប្រាស់ដោយភ្ជាប់លក្ខខណ្ឌ (Shrink-wrap Software)
- សុសវែរសម្រាប់ប្រើប្រាស់ដោយអង្គភាពមានការកំណត់ (Site License)
- សុសវែរដែលអាចទាញយកមកប្រើប្រាស់ (Downloadable Software)
- សុសវែរដែលភ្ជាប់ជាមួយកុំព្យូទ័រ (Software Bundled with Computer Hardware)។

គ- ប្រាក់ចំណូលពីការជួលចលនទ្រព្យឬអចលនទ្រព្យ។

សម្រាប់ករណីដូចមានចែងក្នុងកថាខណ្ឌនេះ ការទូទាត់ណាមួយដែលត្រូវបានអនុញ្ញាតឱ្យលើកលែងពន្ធកាត់ទុកលុះណាតែចំនួនទឹកប្រាក់នោះត្រូវបានកត់ត្រាក្នុងវិក្កយបត្រ ដែលបានចេញយ៉ាងត្រឹមត្រូវដោយភាគីអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសម្ខាងទៀត។

**ប្រការ៤៧** .- មូលដ្ឋានសម្រាប់គណនាទឹកប្រាក់ពន្ធកាត់ទុក

១- មូលដ្ឋានសម្រាប់គណនាប្រាក់ពន្ធកាត់ទុក គឺជាចំនួនទឹកប្រាក់ដែលត្រូវទូទាត់ឱ្យបុគ្គលណាមួយនៅមុនពេលកាត់ទុកប្រាក់ពន្ធ។

២- ចំពោះការទូទាត់ប្រាក់ឱ្យអនិវាសនជនដែលទាក់ទិនទៅនឹងការផ្គត់ផ្គង់សម្ភារបរិក្ខារផងនិងសេវាផង ដូចជាការទូទាត់ចំណាយទិញគ្រឿងម៉ាស៊ីនពីក្រៅប្រទេស ដែលរួមមានថ្លៃទិញគ្រឿងម៉ាស៊ីននិងថ្លៃសេវាផ្គុំដំឡើងដោយអ្នកបច្ចេកទេសជាបុគ្គលអនិវាសនជនសម្រាប់ដំណើរការដំបូងនៃគ្រឿងម៉ាស៊ីន មូលដ្ឋានសម្រាប់គណនាពន្ធកាត់ទុកគឺជាចំណែកប្រាក់ដែលទាក់ទិននឹងសេវាផ្គុំដំឡើងតែប៉ុណ្ណោះ។

**ប្រការ៤៨** .- កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភ្នាក់ងារកាត់ទុក

១- ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក តាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- ភ្នាក់ងារកាត់ទុកដែលមានកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ ប៉ុន្តែមិនបានធ្វើការកាត់ទុកនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ត្រូវទទួលខុសត្រូវចំពោះប្រាក់ពន្ធដែលមិនបានកាត់ទុកនោះ ព្រមទាំងទណ្ឌកម្មផ្សេងៗដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

## ផ្នែកទី៩
## ការគណនាពន្ធលើប្រាក់ចំណូល

**ប្រការ៤៩** ._ អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវបានកំណត់ដូចខាងក្រោម៖

១- អត្រា ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។

២- អត្រា ៣០ (សាមសិប) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា។

៣- អត្រា ០ (សូន្យ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ។

៤- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គលសហគ្រាសឯកបុគ្គល និងសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គលដូចខាងក្រោម៖

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ (គិតជារៀល) | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ | ដល់ | ១៨ ០០០ ០០០ | ០% |
| ពី | ១៨ ០០០ ០០១ | ដល់ | ២៤ ០០០ ០០០ | ៥% |
| ពី | ២៤ ០០០ ០០១ | ដល់ | ១០២ ០០០ ០០០ | ១០% |
| ពី | ១០២ ០០០ ០០១ | ដល់ | ១៥០ ០០០ ០០០ | ១៥% |
| | | លើសពី | ១៥០ ០០០ ០០០ | ២០% |

**ប្រការ៥០** ._ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសរួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា ១ (មួយ) ភាគរយ នៃផលរបរ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

**ប្រការ៥១** ._ ពន្ធអប្បបរមា

១- ពន្ធអប្បបរមាត្រូវបានកំណត់តាមអត្រា ១ (មួយ) ភាគរយ នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានបង់ជាក់ស្តែងតាមវិធានដូចមានចែងក្នុងមាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីសារពើពន្ធ។ សហគ្រាសដែលទទួលបាននូវការវិនិច្ឆ័យថាបានកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ ត្រូវរួចផុតពីការបង់ពន្ធអប្បបរមា។ ដោយឡែក សហគ្រាសដែលត្រូវបានចាត់ទុកថាមិនបានកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ ត្រូវមានកាតព្វកិច្ចបង់ពន្ធអប្បបរមា។

២- គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលមានរបាយការណ៍សវនកម្មឯករាជ្យ ត្រូវទទួលបានការលើកលែងពន្ធអប្បបរមា។

**ប្រការ៥២** ._ ពន្ធបង់មុនលើការបែងចែកភាគលាភ

១- អនុលោមតាមមាត្រា២៣ នៃច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើសហគ្រាសណាមួយបែងចែកភាគលាភចេញពីប្រាក់ចំណូលមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅឱ្យអ្នកចូលហ៊ុនក្នុងស្រុកឬអ្នកចូលហ៊ុនបរទេស សហគ្រាសនោះត្រូវបង់ពន្ធបង់មុនលើការបែងចែកភាគលាភដែលមានចំនួនស្មើនឹងផលគុណនៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធលើប្រាក់ចំណូល គុណនឹងអត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចមានចែងក្នុងប្រការ៤៩ នៃប្រកាសនេះ។



Ƚ-

២- ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងប្រការនេះ មិនអនុវត្តទេចំពោះ៖

ក- ប្រាក់ចំណូលពីបុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា២១ នៃច្បាប់ស្តីពីសារពើពន្ធ។

ខ- គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ រួមទាំងប្រាក់ចំណូលប្រចាំឆ្នាំរក្សាទុកដែលបានបង្គរដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានមុនឆ្នាំ២០២០។

៣- ប្រាក់ពន្ធដែលបានបង់តាមកថាខណ្ឌទី១ នៃប្រការនេះ ត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ ប្រសិនបើឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យយោងទៅមុខសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលនៃឆ្នាំជាប់ពន្ធបន្តបន្ទាប់។

៤- ភាគលាភដែលបានបង់ពន្ធតាមកថាខណ្ឌទី១ នៃប្រការនេះ នៅពេលបែងចែកបន្ត មិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភទៀតទេ។

៥- នៅក្នុងឆ្នាំជាប់ពន្ធចរន្ត ក្នុងករណីសហគ្រាសមានការបែងចែកភាគលាភ ដែលភាគលាភទាំងនោះយកចេញពីប្រាក់ចំណូលផ្សេងៗគ្នា រួមមានប្រាក់ចំណូលដែលបានបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអត្រា ២០ (ម្ភៃ) ភាគរយ ឬអត្រា ៣០ (សាមសិប) ភាគរយ រួច និង/ឬប្រាក់ចំណេញក្នុងឆ្នាំចរន្ត សហគ្រាសនោះត្រូវអនុវត្តដូចខាងក្រោម៖

ក- ជំហានទី១៖ ត្រូវយកចេញពីប្រាក់ចំណូលរក្សាទុកក្រោយការបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអត្រា ២០ (ម្ភៃ) ភាគរយ ឬអត្រា ៣០ (សាមសិប) ភាគរយ។

ខ- ជំហានទី២៖ ត្រូវយកចេញពីប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធចរន្តមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

**ឧទាហរណ៍ទី១០៖**

ក្នុងខែតុលា ឆ្នាំ២០២៣ សហគ្រាសមួយដែលត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០% បានបែងចែកប្រាក់ចំណូលនៃឆ្នាំចរន្តចំនួន ៤០ ០០០ ០០០ រៀល ទៅឱ្យភាគហ៊ុនិកនៃសហគ្រាសនោះ។ ដូចនេះ សហគ្រាសត្រូវប្រកាសបង់ពន្ធបង់មុនលើការបែងចែកភាគលាភសម្រាប់រយៈពេលជាប់ពន្ធខែតុលា ឆ្នាំ២០២៣ ដូចខាងក្រោម៖

រូបមន្តបំប៉ោងសម្រាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០%

$$\text{ភាគលាភមុនបង់ពន្ធ} = \frac{\text{ភាគលាភដែលទទួលបាន}}{\text{១ – អត្រាពន្ធ (២០\%)}} = \frac{\text{ភាគលាភដែលបានទទួល}}{\text{០,៨}}$$

$$= \frac{\text{៤០ ០០០ ០០០}}{\text{០,៨}} = \text{៥០ ០០០ ០០០ រៀល}$$

ពន្ធបង់មុនលើការបែងចែកភាគលាភ = ៥០ ០០០ ០០០ x ២០% = ១០ ០០០ ០០០ រៀល។

**ប្រការ៥៣ ._** ឥណទានពន្ធបរទេស

១- អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណូលដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា។

២- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលជាប់ពន្ធដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

៣- ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធ និងសម្រាប់ប្រាក់ពន្ធដែលបានបង់នៅប្រទេសក្រៅណាមួយ គឺចំនួនដែលទាបជាងគេក្នុងចំណោម៖

ក- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ។

ខ- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណូលជាប់ពន្ធសរុបពីគ្រប់ប្រភពសម្រាប់រយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាពន្ធដូចមានចែងក្នុងប្រការ៤៩ នៃប្រកាសនេះ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលជាប់ពន្ធដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលជាប់ពន្ធសរុបពីគ្រប់ប្រភព។

៤- ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេសនិងរដ្ឋបាលសារពើពន្ធបរទេសនោះ។

**ប្រការ៥៤** .- ការគណនាប្រាក់ចំណូលជាប់ពន្ធ

១- ការបញ្ចូលមកវិញនិងការកាត់ចេញផ្សេងៗ៖ ជាទូទៅច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារមិនស្របគ្នាទាំងស្រុងទៅនឹងវិធានគណនេយ្យទេ។ ភាពមិនស្របគ្នាទាំងនេះនាំឱ្យប្រាក់ចំណូលជាប់ពន្ធអាចមិនស្មើគ្នានឹងប្រាក់ចំណេញគណនេយ្យ។ ដូច្នេះ ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវយកលទ្ធផលគណនេយ្យមុនបង់ពន្ធនៃឆ្នាំជាប់ពន្ធនោះ មកធ្វើការកែតម្រូវដូចខាងក្រោម៖

ក- បូកបញ្ចូលមកវិញនូវចំណាយមិនអនុញ្ញាតឱ្យកាត់កងដូចខាងក្រោម៖

- ចំណាយរំលស់គណនេយ្យ
- ចំណាយលើការទទួលភ្ញៀវ ការកម្សាន្ត និងការសម្រាកលំហែ
- ការកើនឡើងនូវសំវិធានធន
- អំណោយនិងឧបត្ថម្ភធនផ្សេងៗ
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ
- ចំណាយដែលមិនអនុញ្ញាតឱ្យកាត់កងផ្សេងទៀត។

ខ- បូកបញ្ចូលមកវិញនូវចំណូលជាប់ពន្ធដែលមិនត្រូវបានកត់ត្រាជាចំណូលក្នុងបញ្ជីគណនេយ្យដូចខាងក្រោម៖

- ការផ្គត់ផ្គង់ទំនិញនិងសេវាដោយឥតគិតថ្លៃ
- អំណោយនិងឧបត្ថម្ភធនផ្សេងៗ
- តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល
- ចំណូលជាប់ពន្ធផ្សេងទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ។

គ- ដកចេញវិញនូវចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណាយអាចកាត់កងបានក្នុងឆ្នាំ៖

- រំលស់អនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធ
- រំលស់ពិសេសអនុញ្ញាតតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល
- ការថយចុះនូវសំវិធានធន
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល
- ចំណាយផ្សេងៗទៀតដែលអនុញ្ញាតឱ្យកាត់កងបាន។

ឃ-ដកចេញវិញនូវចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ៖

- ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន
- ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ
- ចំណូលផ្សេងៗដែលបានកត់ត្រាក្នុងបញ្ជីតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។

២- ក្រោយពីបានធ្វើការកែតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ សហគ្រាសត្រូវគណនាវិភាគទានសប្បុរសធម៌ដែលអាចកាត់កងបានតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធ ដោយត្រូវអនុវត្តដូចខាងក្រោម៖

ក- គណនាមូលដ្ឋានសម្រាប់គិតវិភាគទានសប្បុរសធម៌ ដោយត្រូវយកវិភាគទានសប្បុរសធម៌ដែលបានចំណាយនៅក្នុងឆ្នាំជាប់ពន្ធទៅបូកនឹងលទ្ធផលក្រោយការកែតម្រូវដែលបានគណនាតាមកថាខណ្ឌទី១នៃប្រការនេះ។

ខ- គណនាវិភាគទានសប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលដែលបានគណនាក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ទៅគុណនឹង ៥ (ប្រាំ) ភាគរយ។

គ- វិភាគទានសប្បុរសធម៌ដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ៖

- ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធតិចជាង ឬស្មើនឹងវិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ គ្មានការកែតម្រូវចំណាយវិភាគទានសប្បុរសធម៌ទេ
- ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធច្រើនជាង វិភាគទានសប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ ទឹកប្រាក់លម្អៀងត្រូវចាត់ទុកជាចំណាយមិនអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ។ ទឹកប្រាក់លម្អៀងនេះ ត្រូវបូកបញ្ចូលវិញទៅក្នុងលទ្ធផលក្រោយការកែតម្រូវដែលបានគណនាតាមកថាខណ្ឌទី១ នៃប្រការនេះ ដើម្បីរកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌។

៣-បន្ទាប់មកសហគ្រាសត្រូវគណនារកលទ្ធផលក្រោយការកែតម្រូវការប្រាក់ ដោយ៖

ក- គណនាប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ ដោយយកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌ទៅបូកនឹងចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ រួចដកនឹងចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធ។

ខ- គណនាចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ទៅបូកនឹង ៥០ (ហាសិប) ភាគរយ នៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ដូចបានគណនាក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ។

គ- ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធច្រើនជាងចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវគណនាចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធដកចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធដែលបានគណនាក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ។ ចំណាយការប្រាក់ដែលនៅសល់ពីការកាត់កងនេះត្រូវបានចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី៥ តាមលំដាប់ឆ្នាំដែលចំណាយការប្រាក់បានកើតឡើងតាមវិធីដូចមានចែងក្នុងកថាខណ្ឌនេះ។

ឃ-ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធស្មើនឹងចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ត្រូវបានអនុញ្ញាតទាំងស្រុងដោយមិនមានការកែតម្រូវទេ។

ង- ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធតិចជាងចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធអាចកាត់កងបានទាំងអស់សម្រាប់ឆ្នាំជាប់ពន្ធ។ ប្រសិនបើសហគ្រាសមានចំណាយការប្រាក់ដែលនៅសល់យោងពីឆ្នាំមុន សហគ្រាសអាចយកមកកាត់កងបាន ប៉ុន្តែចំនួនដែលត្រូវបានអនុញ្ញាតឱ្យកាត់កងសរុប មិនត្រូវឱ្យលើសពីចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធទេ។ ក្នុងករណីនេះ ការប្រាក់យោងពីឆ្នាំមុនដែលអនុញ្ញាតឱ្យកាត់កងត្រូវដកចេញពីចំណូលជាប់ពន្ធ។

ច- គណនាលទ្ធផលក្រោយការកែតម្រូវការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌ បូកចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធដូចមានចែងក្នុងវាក្យខណ្ឌ គ នៃកថាខណ្ឌនេះ ឬដកចំណាយការប្រាក់យោងពីឆ្នាំមុនដូចមានចែងក្នុងវាក្យខណ្ឌ ង នៃកថាខណ្ឌនេះ។

៤-គណនាប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកែតម្រូវការប្រាក់ក្នុងឆ្នាំជាប់ពន្ធដូចមានចែងក្នុងវាក្យខណ្ឌ ច នៃកថាខណ្ឌទី៣ នៃប្រការនេះ ដកការខាតបង់ពីឆ្នាំមុនៗដែលបានអនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធប្រសិនបើមាន។

**ប្រការ៥៥ .-** ការគណនាពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល ត្រូវបានគណនាដូចខាងក្រោម៖

១- គណនាពន្ធលើប្រាក់ចំណូលដោយយកប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធ ដូចបានគណនាក្នុងប្រការ៥៤ នៃប្រកាសនេះ ទៅគុណនឹងអត្រាពន្ធដូចមានចែងក្នុងប្រការ៤៩ នៃប្រកាសនេះ។

២-ដកឥណទានពន្ធបរទេសដូចមានចែងក្នុងប្រការ៥៣ នៃប្រកាសនេះ ចំពោះសហគ្រាសនិវាសនជនដែលមានប្រាក់ចំណូលប្រភពបរទេស ប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះទេ។

៣-ដកប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភដែលបានបង់ដោយសហគ្រាសដូចមានចែងក្នុងប្រការ៥២ នៃប្រកាសនេះ ប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើប្រាក់ចំណូលបន្ទាប់ពីកាត់កងឥណទានពន្ធបរទេសដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការនេះទេ។ ការដកពន្ធបង់មុនលើការបែងចែកភាគលាភក្នុងកថាខណ្ឌនេះ កម្រិតត្រឹមតែពន្ធបង់មុនលើការបែងចែកភាគលាភណាមួយចេញពីប្រាក់ចំណូលដែលកើតឡើងក្នុងឆ្នាំជាប់ពន្ធប៉ុណ្ណោះ។

**ប្រការ៥៦** ._ ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ពន្ធលើប្រាក់ចំណូលត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ក្នុងករណីដែលលទ្ធផលគណនាដូចមានចែងក្នុងប្រការ៥៥ នៃប្រកាសនេះ មានចំនួនច្រើនជាងផលបូកនៃឥណទានពន្ធកាត់ទុកតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៨ នៃជំពូកទី៣ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធដូចមានចែងក្នុងប្រការ៥០ នៃប្រកាសនេះ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀងនោះជូនរដ្ឋបាលសារពើពន្ធ។

២-ប្រសិនបើលទ្ធផលគណនាដូចមានចែងក្នុងប្រការ៥៥ នៃប្រកាសនេះ មានចំនួនតិចជាងផលបូកនៃឥណទានពន្ធកាត់ទុកតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៨ នៃជំពូកទី៣ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធដូចមានចែងក្នុងប្រការ៥០ នៃប្រកាសនេះ សហគ្រាសអាចប្រើប្រាស់ចំនួនលម្អៀងជាឥណទានសម្រាប់កាត់កងទៅនឹងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល នៅក្នុងខែបន្ទាប់ពីខែដែលបានដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ឬពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំបន្ទាប់។

៣-មុននឹងធ្វើការទូទាត់ប្រាក់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ឬយោងទៅប្រើជាប្រាក់រំដោះពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការនេះ សហគ្រាសត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមាក្នុងករណីដែលសហគ្រាសត្រូវជាប់ពន្ធអប្បបរមា។

**ប្រការ៥៧** ._ ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ពន្ធអប្បបរមាដូចមានចែងក្នុងប្រការ៥១ នៃប្រកាសនេះ ត្រូវបង់នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយអាចត្រូវបានកាត់បន្ថយ ដោយពន្ធលើប្រាក់ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ។

២-ក្នុងករណីដែលពន្ធលើប្រាក់ចំណូលដែលបានគណនាក្នុងប្រការ៥៥ នៃប្រកាសនេះ លើសពីពន្ធអប្បបរមា សហគ្រាសគ្មានទឹកប្រាក់ពន្ធអប្បបរមាត្រូវបង់ទេ ហើយសហគ្រាសត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការ៥៦ នៃប្រកាសនេះ នៅពេលដាក់លិខិតប្រកាសសារពើពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

៣-ក្នុងករណីដែលពន្ធអប្បបរមាលើសពីពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមាត្រូវបានកាត់បន្ថយដោយឥណទានពន្ធរបស់សហគ្រាសដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ៥៦ នៃប្រកាសនេះ (គឺផលបូកនៃចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលសហគ្រាសបានបង់សម្រាប់ឆ្នាំជាប់ពន្ធដូចមានចែងក្នុងប្រការ៥០ នៃប្រកាសនេះ និងប្រាក់ពន្ធដែលសហគ្រាសដទៃបានកាត់ទុកតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៨ នៃជំពូកទី៣ នៃប្រកាសនេះ និងឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុនប្រសិនបើមាន) ក្នុងនោះ៖

- ក- ប្រសិនបើពន្ធអប្បបរមាច្រើនជាងឥណទានពន្ធដូចមានចែងក្នុងកថាខណ្ឌទី៣ នៃប្រការនេះ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀង។
- ខ- ប្រសិនបើឥណទានពន្ធដូចមានចែងក្នុងកថាខណ្ឌទី៣ នៃប្រការនេះ ច្រើនជាងពន្ធអប្បបរមា ចំនួនលម្អៀងត្រូវបានអនុញ្ញាតឱ្យយោងទៅប្រើប្រាស់ជាឥណទានពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ (ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ឬពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ)។

**ប្រការ៥៨ ._** វិធានស្ដីពីការយោងការខាតបង់

១- ការយោងការខាតបង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ការខាតបង់កើតឡើងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវបានចាត់ជាបន្ទុកនិងត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីប្រាក់ចំណូលសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់ (ឆ្នាំជាប់ពន្ធទី១ នៃការយោងការខាតបង់)។ ប្រសិនបើប្រាក់ចំណូលនេះមិនគ្រប់គ្រាន់សម្រាប់ការទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។

ខ- ចំនួនកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវស្មើនឹងចំនួនប្រាក់ចំណូលដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធនោះដោយមិនត្រូវរក្សាទុកចំណែកណាមួយនៃការខាតបង់សម្រាប់យោងទៅឆ្នាំបន្ទាប់ទៀតឡើយ។

គ- នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ បទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ឆ្នាំដែលការខាតបង់បានកើតឡើង។

២- លក្ខខណ្ឌនៃការអនុញ្ញាតការខាតបង់៖

ក- ភស្តុតាងបញ្ជាក់ពីការខាតបង់៖

- ដើម្បីអាចកាត់កងបាន សហគ្រាសត្រូវគណនាការខាតបង់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ ហើយការខាតបង់នោះបានបំពេញក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដែលបានដាក់ជូនរដ្ឋបាលសារពើពន្ធ
- សហគ្រាសដែលត្រូវទទួលរងការកំណត់ពន្ធជាឯកតោភាគីរបស់រដ្ឋបាលសារពើពន្ធក្នុងឆ្នាំជាប់ពន្ធណាមួយ មិនត្រូវបានអនុញ្ញាតឱ្យយោងការខាតបង់ពីឆ្នាំជាប់ពន្ធមុន មកកាត់កងក្នុងឆ្នាំជាប់ពន្ធដែលមានការកំណត់ពន្ធជាឯកតោភាគី ឬយោងការខាតបង់ក្នុងឆ្នាំដែលមានការកំណត់ពន្ធជាឯកតោភាគីទៅកាត់កងទៅឆ្នាំជាប់ពន្ធបន្ទាប់បានទេ។ ចំពោះការខាតបង់ដែលកើតមានមុនឆ្នាំជាប់ពន្ធដែលមានការកំណត់ពន្ធជាឯកតោភាគី ត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងនៅឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមានការកំណត់ពន្ធជាឯកតោភាគីបាន ប្រសិនបើមិនទាន់ហួសអាយុកាលយោងខាតចំនួន ៥ឆ្នាំ
- ការខាតបង់ដែលត្រូវបានអនុញ្ញាតឱ្យយកមកកាត់កង ត្រូវមានការបញ្ជាក់អះអាងដោយឯកសារនិងបញ្ជីគណនេយ្យស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងដែលបានធ្វើនិយ័តកម្មស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ។

ខ- ការប្ដូរសកម្មភាពអាជីវកម្មរបស់សហគ្រាស៖

- ការខាតបង់របស់សហគ្រាសណាមួយអាចអនុញ្ញាតឱ្យយោងបាន សម្រាប់តែសហគ្រាសនោះប៉ុណ្ណោះ
- ក្នុងករណីផ្លាស់ប្ដូរសកម្មភាពអាជីវកម្មដែលក្នុងនោះជាការបញ្ឈប់សកម្មភាពចាស់ហើយចាប់ផ្ដើមសកម្មភាពថ្មីផ្សេងទៀត ការខាតបង់ដែលសហគ្រាសបានទទួលរងក្នុងសកម្មភាពចាស់របស់ខ្លួន មិនត្រូវបានអនុញ្ញាតឱ្យយកមកកាត់ចេញពីប្រាក់ចំណូលដែលសហគ្រាសសម្រេចបានក្នុងសកម្មភាពថ្មីរបស់ខ្លួនទេ។

គ- ឆ្នាំជាប់ពន្ធដែលត្រូវអនុវត្តការយោងការខាតបង់៖

- ការខាតបង់ក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវយោងមកកាត់កងជាដាច់ខាតពីលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្តបន្ទាប់ ដោយមិនអនុញ្ញាតឱ្យរំលងឆ្នាំជាប់ពន្ធដែលមានលទ្ធផលចំណេញណាមួយទេ
- ប្រសិនបើដោយមូលហេតុណាមួយ សហគ្រាសមិនបានយោងការខាតបង់ទាំងអស់ ឬយោងតែចំណែកណាមួយទៅកាត់កងនឹងលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ណាមួយ ដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារបានអនុញ្ញាតឱ្យកាត់កង ការខាតបង់នេះមិនអាចយោងទៅកាត់កងពីលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ៗទៀតបានទេ
- ការយោងការខាតបង់ត្រូវអនុវត្តរៀងៗគ្នាទៅតាមលំដាប់ឆ្នាំដែលការខាតបង់បានកើតឡើងដោយមិនឱ្យលើសពី ៥ឆ្នាំ។



ᛕ

# ផ្នែកទី១០
# បញ្ជីគណនេយ្យ

**ប្រការ៥៩ .–** កាតព្វកិច្ចគណនេយ្យ

១- ការកាន់បញ្ជីគណនេយ្យ៖

ក- សហគ្រាសត្រូវកាន់កត់ត្រាបញ្ជីគណនេយ្យ តាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ខ- គោលការណ៍សំខាន់ៗក្នុងការកត់ត្រាបញ្ជីគណនេយ្យ មានជាអាទិ៍៖

- ត្រូវប្រើប្រាស់ប្រព័ន្ធគណនេយ្យទ្វេភាគ ដោយផ្អែកលើមូលដ្ឋានគណនេយ្យបង្គរ
- រាល់ប្រតិបត្តិការត្រូវកត់ត្រាជាប្រាក់រៀល ឬរូបិយបណ្ណបរទេសណាមួយដែលមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច
- ត្រូវចេញវិក្កយបត្រលើរាល់ប្រតិបត្តិការជាមួយបុគ្គលដទៃទៀត។ វិក្កយបត្រត្រូវមានលេខរៀង និងនិទ្ទេសត្រឹមត្រូវតាមការកំណត់
- ត្រូវកត់ត្រាសេចក្តីរាយលម្អិតនៃវិក្កយបត្រឱ្យបានត្រឹមត្រូវចូលក្នុងទិនានុប្បវត្តិ
- លិខិតយុត្តិការត្រូវមានចុះថ្ងៃខែឆ្នាំ និងរៀបចំទុកដាក់តាមលំដាប់ច្បាស់លាស់
- ត្រូវកត់ត្រាចូលបញ្ជីគណនេយ្យនូវរាល់ប្រតិបត្តិការតាមលំដាប់ថ្ងៃខែដែលប្រតិបត្តិការទាំងនោះបានកើតឡើង
- កំណត់ត្រាគណនេយ្យនីមួយៗត្រូវបង្ហាញអំពីប្រភព ខ្លឹមសារ ខ្ទង់គណនី លក្ខណៈសង្ខេបនៃប្រតិបត្តិការ និងឯកសារយោងជាសំអាង
- រាល់ការកែតម្រូវ ត្រូវរក្សាទុកនូវភស្តុតាងបញ្ជាក់ពីការកែតម្រូវនោះ ដើម្បីអាចរកឃើញឡើងវិញបាននូវទឹកប្រាក់ពិតប្រាកដនៃចលនាសាច់ប្រាក់នៅក្នុងគណនី
- បញ្ជីគណនេយ្យត្រូវធ្វើជាភាសាខ្មែរ ដោយប្រើលេខខ្មែរ ឬលេខឡាតាំង ប៉ុន្តែអាចកាន់បញ្ជីគណនេយ្យជំនួយជាភាសាផ្សេងបាន។

២- ការបង្ហាញឯកសារគណនេយ្យ៖ សហគ្រាសត្រូវមានភស្តុតាងបញ្ជាក់នូវរាល់ចំណូលចំណាយដែលបានប្រកាស។ នៅពេលរដ្ឋបាលសារពើពន្ធស្នើសុំឱ្យបង្ហាញភស្តុតាង សហគ្រាសត្រូវបង្ហាញនូវរាល់ឯកសារគណនេយ្យ បញ្ជីសារពើភណ្ឌ បណ្ណចំណូល បណ្ណចំណាយ... ដើម្បីបញ្ជាក់អះអាងនូវភាពពិតប្រាកដនៃព័ត៌មានដែលបានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធ។

៣- ការរក្សាទុកឯកសារគណនេយ្យ៖ ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា២០១ នៃច្បាប់ស្តីពីសារពើពន្ធ បុគ្គលដែលត្រូវកាន់កត់ត្រា ឬរក្សាទុកបញ្ជីឯកសារនានា ឬទិនានុប្បវត្តិ ដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជីឬឯកសារទាំងនេះក្នុងរយៈពេល ១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធដែលបញ្ជីឬឯកសារទាំងនេះបានកត់ត្រានូវព័ត៌មានផ្សេងៗលើប្រតិបត្តិការរបស់សហគ្រាស។

៤- សហគ្រាសដែលបានប្រព្រឹត្តដូចខាងក្រោម ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ៖

ក- ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

ខ- ការមិនបានចេញវិក្កយបត្រ។

គ- ការមិនផ្តល់ព័ត៌មានឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។

ឃ-ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជិកាគណនេយ្យឬឯកសារផ្សេងៗ។

ង- ការមិនបានរក្សាបញ្ជិកាគណនេយ្យនិងឯកសារផ្សេងទៀត។

ច- ការព្យាយាមរារាំងការកំណត់និងការប្រមូលពន្ធ។

ឆ- ការកសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

ជ- ការលាក់ទុកឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

ឈ-ការចេញវិក្កយបត្រក្លែងបន្លំ។

ញ-ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។



ሁ

**ប្រការ៦០ ._** បន្ទុកភស្តុតាង

១-នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ឬមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមាន។ ក្នុងករណីមិនយល់ស្របចំពោះការកំណត់ពន្ធរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា ការកំណត់ពន្ធនោះមិនត្រឹមត្រូវ។

២-នៅពេលដែលប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធ មានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានា ដែលធ្វើឱ្យឃើញចំណាយស្តុកស្តម្ភរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធ ដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មាន សមស្របទៅនឹងទំហំនៃចំណាយដែលបានទិញទ្រព្យសកម្មឬវត្ថុនានាដែលលេចធ្លោនោះ។ ក្នុងករណីមិនយល់ស្របចំពោះការកំណត់ពន្ធរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា ការកំណត់ពន្ធនោះមិនត្រឹមត្រូវ។

## ជំពូកទី៤
## ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស

**ប្រការ៦១ ._** សាខាក្រុមហ៊ុនបរទេស

សម្រាប់គោលដៅនៃប្រកាសនេះ សាខាក្រុមហ៊ុនបរទេស សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបរទេសដែលក្នុងនោះទ្រព្យសកម្មផ្សេងៗគឺជារបស់ក្រុមហ៊ុនដើមនៅបរទេស។

**ប្រការ៦២ ._** ប្រាក់ចំណូលជាប់ពន្ធរបស់សាខាក្រុមហ៊ុនបរទេស

សាខាក្រុមហ៊ុនបរទេស ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលបានមកពីការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាត់កងនូវចំណាយនានាដូចមានចែងក្នុងផ្នែកទី៥ នៃជំពូកទី៣ នៃប្រកាសនេះ។

**ប្រការ៦៣ ._** ការគណនាពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស

ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានគណនាដោយយកប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធនោះ ទៅគុណនឹងអត្រាពន្ធដូចមានចែងក្នុងប្រការ៤៩ នៃប្រកាសនេះ។

**ប្រការ៦៤ ._** ពន្ធបង់មុនលើការបែងចែកភាគលាភសម្រាប់សាខាក្រុមហ៊ុនបរទេស

ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធចរន្ត សាខាក្រុមហ៊ុនបរទេសណាមួយធ្វើការផ្ទេរប្រាក់ចំណូលប្រភពកម្ពុជាទៅក្រៅប្រទេស ប្រាក់ចំណូលនោះ៖

១-មិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងប្រការ៥២ នៃប្រកាសនេះទេ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងប្រការ៦៣ នៃប្រកាសនេះ។

២-ត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងប្រការ៥២ នៃប្រកាសនេះ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងប្រការ៦៣ នៃប្រកាសនេះ។

**ប្រការ៦៥ ._** ពន្ធកាត់ទុកលើប្រាក់ចំណូលប្រភពកម្ពុជា

ក្រៅពីពន្ធកាត់ទុកលើការទូទាត់ដល់បុគ្គលនិវាសនជនដូចមានចែងក្នុងប្រការ៤៤ នៃប្រកាសនេះ សាខាក្រុមហ៊ុនបរទេស ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធចំនួន ១៤ (ដប់បួន) ភាគរយ ដូចមានចែងក្នុងប្រការ៤៥ នៃប្រកាសនេះ នៅពេលធ្វើការផ្ទេរប្រាក់ចំណូលក្រោយការបង់ពន្ធដូចមានចែងក្នុងប្រការ៦៣ និងប្រការ៦៤ នៃប្រកាសនេះ ទៅឱ្យក្រុមហ៊ុនដើមនៅបរទេស ឬការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាទៅឱ្យបុគ្គលអនិវាសនជនដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ វៀរលែងតែជានាវ៉ាប់រងបន្តចំពោះទ្រព្យសម្បត្តិឬហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ៦៦ ._** និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦៧ ._** ការអនុវត្ត

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៦៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ